ក្រសួងកិច្ចការនារី
MINISTRY OF WOMEN'S AFFAIRS

# របាយការណ៍
# ស្តីពី
# ការវិភាគទិន្នន័យលើបទពិសោធន៍របស់ស្ត្រី ដែលរងអំពើហិង្សាក្នុងគ្រួសារ និងទម្រង់អំពើហិង្សាផ្សេងៗ

ខែកញ្ញា ឆ្នាំ២០១៦

# អារម្ភកថា

របាយការណ៍“ការវិភាគទិន្នន័យលើបទពិសោធន៍របស់ស្ត្រីដែលរងអំពើហិង្សាក្នុងគ្រួសារ និងទម្រង់អំពើហិង្សាផ្សេងៗ ”នេះត្រូវបានរៀបចំឡើងដោយមានកិច្ចសហការជាមួយវិទ្យាស្ថានជាតិស្ថិតិនៃក្រសួងផែនការ និងក្រសួងសុខាភិបាល ផ្អែកលើទិន្នន័យដែលមានស្រាប់ នៅក្នុងឯកសារ ***“ការអង្កេតប្រជាសាស្ត្រ និងសុខភាពកម្ពុជា (អ.ប.ស.ក) ឆ្នាំ២000 ២00៥ និង ២0១៤”*** រួមទាំងទិន្នន័យនៅក្នុងឯកសារ***“ការសិក្សាស្រាវជ្រាវថ្នាក់ជាតិស្តីពីសុខភាព និងបទពិសោធន៍ក្នុងជីវិតរបស់ស្ត្រីក្នុងប្រទេសកម្ពុជាឆ្នាំ២0១៥”*** របស់អង្គការសុខភាពពិភពលោក ក្នុងគោលបំណងពិនិត្យមើលលើអំពើហិង្សាដែលកើតមានកន្លងមក និងដើម្បីធ្វើការប្រៀបធៀបលទ្ធផលនៃការសិក្សាស្រាវជ្រាវផ្សេងៗទៀត។ របាយការណ៍នេះបានវិភាគបន្ថែមយ៉ាងលម្អិត និងស៊ីជម្រៅលើរបកគំហើញ ដែលបង្ហាញក្នុងឯកសារ ***“ការអង្កេតប្រជាសាស្ត្រ និងសុខភាពកម្ពុជាឆ្នាំ២0១៤”*** ដើម្បីរួមចំណែកផ្តល់ការយល់ដឹងបន្ថែមទៀត ពីទិន្នន័យដែលអាចជួយដល់ការរៀបចំគោលនយោ បាយក្នុងការទប់ស្កាត់អំពើហិង្សាលើស្ត្រីនៅក្នុងព្រះរាជាណាចក្រកម្ពុជា។

ផ្អែកលើនិយមន័យដែលបានកំណត់ដោយអង្គការសហប្រជាជាតិ អំពើហិង្សាលើស្ត្រីគឺជា សកម្មភាពទាំងឡាយណានៃអំពើហិង្សាទាក់ទងនឹងយេនឌ័រ ដែលបង្ករឬអាចបណ្តាលឱ្យមានផលប៉ះពាល់ ឬការឈឺចាប់ដល់រាងកាយ ផ្លូវភេទ និងផ្លូវចិត្តរបស់ស្ត្រី រួមទាំងការគំរាមកំហែង ការបង្ខិតបង្ខំ ឬការដកហូតសេរីភាព ទោះបីជាកើតឡើងក្នុងជីវិតឯកជន ឬសាធារណៈ នៅពេលដែលមានអំពើហិង្សាលើស្ត្រីកើតឡើងនៅក្នុងនិងក្រៅផ្ទះ ភាគច្រើននៃអំពើហិង្សាលើស្ត្រី គឺប្រព្រឹត្តិដោយដៃគូស្និទ្ធស្នាលរបស់ពួកគេ (ដៃគូស្និទ្ធស្នាលបច្ចុប្បន្ន ឬអតីតដៃគូស្និទ្ធស្នាល និងមិត្តប្រុស)។

ការសិក្សាពីប្រេវ៉ាឡង់ថ្នាក់ជាតិបានប៉ាន់ប្រមាណអំពីទំហំនៃអំពើហិង្សាលើស្ត្រីបង្ករដោយដៃគូស្និទ្ធស្នាល ដើម្បីកំណត់ក្រុមដែលមានហានិភ័យខ្ពស់ និងបានយល់ពីកត្តាហានិភ័យទាំងនោះ។ ការត្រួតពិនិត្យលើប្រេវ៉ាឡង់ថ្នាក់ជាតិត្រូវធ្វើយ៉ាងទៀងទាត់ដើម្បីឱ្យដឹងថាតើសកម្មភាពទប់ស្កាត់អំពើហិង្សាមានប្រសិទ្ធភាពកំរិតណា ក្នុងការកាត់បន្ថយអំពើហិង្សាលើស្ត្រីនៅក្នុងគ្រួសារ។ ការប្រើវិធីសាស្ត្រប្រមូលចងក្រងទិន្នន័យនៅក្នុងការអង្កេតនីមួយៗបានបង្ហាញពីបទពិសោធន៍ និងការកើនឡើង ឬថយចុះនៃអំពើហិង្សាលើស្ត្រី ដែលប្រព្រឹត្តិដោយដៃគូស្និទ្ធស្នាល និងអ្នកក្រៅពីដៃគូនៅក្នុងព្រះរាជាណាចក្រកម្ពុជា។

របកគំហើញក្នុងរបាយការណ៍នេះ នឹងជួយពង្រឹងការយល់ដឹងអំពីបញ្ហាគន្លឹះទាក់ទង នឹងអំពើហិង្សាលើស្ត្រី និងការរៀបចំគោលនយោបាយ ព្រមទាំងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ ផ្សេងៗទៀត ដើម្បីទប់ស្កាត់អំពើហិង្សាលើស្ត្រីប្រកបដោយប្រសិទ្ធភាពខ្ពស់។

រាជធានីភ្នំពេញ, ថ្ងៃទី 27 ខែកញ្ញា ឆ្នាំ២០១៦

**រដ្ឋមន្ត្រី**

**លោកជំទាវវេជ្ជ. អ៊ឹង កន្ថាផាវី**

# សេចក្តីថ្លែងអំណរគុណ

របាយការណ៍ស្តីពី ***"ការវិភាគទិន្នន័យលើបទពិសោធន៍របស់ស្ត្រីដែលរងអំពើហិង្សាក្នុងគ្រួសារ និងទម្រង់អំពើហិង្សាផ្សេងៗ"*** បានរៀបចំឡើងក្រោមកិច្ចខិតខំប្រឹងប្រែងយ៉ាងសកម្មរវាងក្រសួងកិច្ចការនារីសហការជាមួយវិទ្យាស្ថានជាតិស្ថិតិនៃក្រសួងផែនការ និងក្រសួងសុខាភិបាល ព្រមទាំងដៃគូអភិវឌ្ឍន៍ មានជាអាទិ៍ មូលនិធិសហប្រជាជាតិសម្រាប់ប្រជាជន (UNFPA) និងជំនួយរបស់រដ្ឋាភិបាលអូស្ត្រាលី (Australian Aid) ដោយផ្អែកលើលទ្ធផលនៃការអង្កេតប្រជាសាស្ត្រ និងសុខភាពកម្ពុជា និងការសិក្សាស្រាវជ្រាវថ្នាក់ជាតិរបស់អង្គការសុខភាពពិភពលោកឆ្នាំ២០១៥។ របាយការណ៍នេះបានបង្ហាញនូវទិន្នន័យលម្អិតដែលជាឯកសារមូលដ្ឋានមួយសម្រាប់ជួយក្នុងការរៀបចំគោលនយោបាយ និងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ផ្សេងៗទៀត ដើម្បីទប់ស្កាត់អំពើហិង្សាលើស្ត្រីប្រកបដោយប្រសិទ្ធភាពខ្ពស់។

ក្រសួងកិច្ចការនារី សូមថ្លែងអំណរគុណដល់ក្រុមការងារបច្ចេកទេសពីវិទ្យាស្ថានជាតិស្ថិតិនៃក្រសួងផែនការ និងក្រសួងសុខាភិបាល ព្រមទាំងក្រុមការងារនៃក្រសួងកិច្ចការនារី រួមមាន **លោកជំទាវ នាង ឆាយយ៉ាណា** អនុរដ្ឋលេខាធិការ និង**លោកជំទាវ ញាណា សុចិត្រា** អគ្គនាយកនៃអគ្គនាយកដ្ឋានអភិវឌ្ឍន៍សង្គម នាយកដ្ឋានការពារផ្លូវច្បាប់ នាយកដ្ឋានស្ត្រីនិងសុខភាព និងនាយកដ្ឋានផែនការ ដែលបានចូលរួមពិនិត្យមើលខ្លឹមសារ និងផ្តល់អនុសាសន៍ក្នុងការរៀបចំចងក្រងរបាយការណ៍នេះ។

សូមថ្លែងអំណរគុណដល់ លោកស្រីបណ្ឌិត Henrica A.F.M. Jansen អ្នកស្រាវជ្រាវអន្តរជាតិផ្នែកអំពើហិង្សាលើស្ត្រីនៃមូលនិធិសហប្រជាជាតិសម្រាប់ប្រជាជនប្រចាំតំបន់អាស៊ី និងប៉ាស៊ីហ្វិក (UNFPA-APRO) និងលោកស្រី Pauline Gulliver ទីប្រឹក្សាអន្តរជាតិដែលបានផ្តល់នូវបច្ចេកទេសក្នុងការវិភាគទិន្នន័យ និងអរគុណដល់មូលនិធិសហប្រជាជាតិសម្រាប់ប្រជាជនប្រចាំនៅប្រទេសកម្ពុជា (UNFPA Cambodia) និងជំនួយរបស់រដ្ឋាភិបាលអូស្ត្រាលី (Australian Aid)សម្រាប់ការគាំទ្រផ្នែកហិរញ្ញវត្ថុ។

# មាតិកា


អារម្ភកថា ........ i

សេចក្តីថ្លែងអំណរគុណ ........ iii

បញ្ជីតារាង ........ vii

ឧបសម្ព័ន្ធតារាងស្ថិតិ ........ ix

បញ្ជីរូបភាព ........ xi

សន្ទានុក្រម ........ xiii

សេចក្តីសង្ខេប ........ xv

**ផ្នែកទី១** ........ ១

១.សេចក្តីផ្តើម ........ ១

១.១. លក្ខណៈសាវតា ........ ១

១.២. គោលបំណងនៃការអង្កេត ........ ៤

១.៣. រចនាសម្ព័ន្ធនៃរបាយការណ៍ ........ ៥

**ផ្នែកទី២** ........ ៦

២. វិធីសាស្ត្រអង្កេត ........ ៦

២.១.សំណាកគំរូដែលបានជ្រើសរើស ........ ៦

២.២. សន្ទានុក្រម និងនិយមន័យ ........ ៧

២.៣. ការវិភាគទិន្នន័យ ........ ១២

**ផ្នែកទី៣** ........ ១៥

៣. អំពើហិង្សាលើដៃគូស្និទ្ធស្នាល ........ ១៥

៣.១. បទពិសោធន៍នៃអំពើហិង្សាលើដៃគូស្និទ្ធស្នាល ........ ១៥

៣.២.បទពិសោធន៍អំពើហិង្សាតាមទម្រង់ផ្សេងទៀត ........ ៣០

**ផ្នែកទី៤** ........ ៣៧

៤. និន្នាការអំពើហិង្សាលើដៃគូស្និទ្ធស្នាលអំឡុងពេលកន្លងមក ........ ៣៧

៤.១. ភាពខុសគ្នានៃវិធីសាស្ត្រស្រាវជ្រាវ ........ ៣៧

៤.២. ភាពខុសគ្នានៃលក្ខណៈសំណាកគំរូកន្លងមក ........ ៤១

៤.៣. និន្នាការអំពើហិង្សាលើដៃគូស្និទ្ធស្នាលក្នុងរយៈពេលកន្លងមក ..... ៤២
៤.៤. សូចនាករ ..... ៤៥
**ផ្នែកទី៥** ..... ៤៧
៥. ការប្រៀបធៀបលទ្ធផលនៃអ.ប.ស.ក និងការស្រាវជ្រាវរបស់អង្គការសុខភាពពិភពលោកស្ដីពីអត្រាប្រេវ៉ាឡង់អំពើហិង្សាលើរាងកាយ ឬផ្លូវភេទលើដៃគូ ..... ៤៧
**ផ្នែកទី៦** ..... ៥៣
៦. យោបល់ និងអនុសាសន៍ទាក់ទងនឹងគោលនយោបាយ ..... ៥៣
តារាងឧបសម្ព័ន្ធស្ថិតិ ..... ៥៧
ឧបសម្ព័ន្ធ (ក) ៖ តារាងលម្អិតនៃអំពើហិង្សាលើដៃគូស្និទ្ធស្នាល..... ៥៧
ឧបសម្ព័ន្ធ (ខ)៖ តារាងលម្អិតនៃអំពើហិង្សាផ្សេងទៀត..... ៧៥
ឧបសម្ព័ន្ធ (គ)៖ ការវិភាគលម្អិតលើការប្រៀបធៀបសំណាកគំរូនៃការអង្កេត អ.ប.ស.កទាំងបី..... ៨១
ឧបសម្ព័ន្ធ (ឃ)៖ តារាងសំណួរអំពើហិង្សាក្នុងគ្រួសារ ..... ៨៥

# បញ្ជីតារាង

**តារាង ៣.១**. សង្ខេបអត្រាប្រេវ៉ាឡង់អំពើហិង្សាក្នុងជីវិត និងអំឡុងពេល១២ខែកន្លងមក(ក្នុងកម្រិតគម្លាតជឿជាក់៩៥%) បែងចែកតាមប្រភេទអំពើហិង្សាក្នុងការអង្កេតអ.ប.ស.ក ដែលប្រព្រឹត្តដោយដៃគូស្និទ្ធស្នាលបច្ចុប្បន្ន ឬថ្មីបំផុតក្នុងចំណោមស្ត្រីដែលធ្លាប់មានដៃគូ (អ.ប.ស.ក ឆ្នាំ២០១៤)

**តារាង ៣.២**. របួសស្នាមលើរាងកាយក្នុងជីវិតបណ្តាលមកពីអំពើហិង្សាលើរាងកាយឬផ្លូវភេទដែលប្រព្រឹត្តដោយដៃគូស្និទ្ធស្នាលបច្ចុប្បន្ន ឬថ្មីបំផុតក្នុងចំណោមស្ត្រីធ្លាប់មានដៃគូដែលបានរាយការណ៍ថាធ្លាប់ទទួលរងអំពើហិង្សាលើរាងកាយ ឬផ្លូវភេទ(អ.ប.ស.ក ឆ្នាំ២០១៤)

**តារាង៣.៣**.ជនប្រព្រឹត្តអំពើហិង្សាលើរាងកាយអំឡុងពេលមានផ្ទៃពោះក្នុងចំណោមស្ត្រីធ្លាប់មានដៃគូ (អ.ប.ស.ក ឆ្នាំ ២០១៤)

**តារាង ៣.៤**. បទពិសោធន៍ស្តីពីទម្រង់ផ្សេងៗនៃអំពើហិង្សាក្នុងជីវិតដែលប្រព្រឹត្តដោយអ្នកក្រៅពីដៃគូក្នុងចំណោមស្ត្រីដែលបានចូលរួមការអង្កេតផ្នែកអំពើហិង្សាក្នុងគ្រួសារ បែងចែកតាមក្រុមអាយុ (អ.ប.ស.ក ឆ្នាំ២០១៤)

**តារាង ៣ .៥**. ជនប្រព្រឹត្តអំពើហិង្សាលើរាងកាយ ក្នុងចំណោមស្ត្រីដែលបានចូលរួមការអង្កេតផ្នែកអំពើហិង្សាក្នុងគ្រួសារ បែងចែកតាមស្ថានភាពអាពាហ៍ពិពាហ៍ (អ.ប.ស.ក ឆ្នាំ២០១៤)

**តារាង៣.៦**.ជនប្រព្រឹត្តអំពើហិង្សាដែលបង្ខំឱ្យស្ត្រីរួមភេទជាលើកដំបូងក្នុងជីវិតក្នុងចំណោមស្ត្រីដែលធ្លាប់មានអំពើហិង្សាក្នុងគ្រួសារ បែងចែកតាមស្ថានភាពអាពាហ៍ពិពាហ៍ (អ.ប.ស.ក ឆ្នាំ២០១៤)

**តារាង ៣.៧**. អាយុរបស់ស្ត្រីដែលរងការបង្ខំឱ្យរួមភេទលើកដំបូងក្នុងចំណោមស្ត្រីដែលធ្លាប់រងអំពើហិង្សាក្នុងគ្រួសារ បែងចែកតាមស្ថានភាពអាពាហ៍ពិពាហ៍ (អ.ប.ស.ក ឆ្នាំ២០១៤)

**តារាង ៣.៨**. ប្រភពស្វែងរកជំនួយរបស់ស្ត្រីដែលធ្លាប់ទទួលរងអំពើហិង្សាលើរាងកាយ ឬផ្លូវភេទពីដៃគូស្និទ្ធស្នាល ឬក្រៅពីដៃគូ បែងចែកតាមប្រភេទអំពើហិង្សា (តែលើរាងកាយ តែលើផ្លូវភេទ លើរាងកាយនិងផ្លូវភេទ លើរាងកាយ ឬលើផ្លូវភេទ) (អ.ប.ស.ក ឆ្នាំ២០១៤)

**តារាង ៤.១**. ការជ្រើសរើសសំណាកគំរូ និងលក្ខណៈសំណាកគំរូនៃការអង្កេត អ.ប.ស.ក ឆ្នាំ២០០០ ២០០៥ និង២០១៤ សម្រាប់ផ្នែកអំពើហិង្សាក្នុងគ្រួសារ

**តារាង ៤.២**. កម្រងសំណួរស្តីពីអំពើហិង្សាលើរាងកាយ ផ្លូវភេទ និងផ្លូវចិត្តនៃការអង្កេត អ.ប.ស.ក ឆ្នាំ២០០០ ២០០៥ និង២០១៤ សម្រាប់ផ្នែកអំពើហិង្សាក្នុងគ្រួសារ

**តារាង ៤.៣**. លក្ខណៈប្រជាសាស្ត្រនៃស្ត្រីធ្លាប់រៀបការដែលទទួលរងអំពើហិង្សាលើរាងកាយ ឬផ្លូវភេទអំឡុងពេល១២ខែកន្លងមកពីដៃគូបច្ចុប្បន្ន ឬថ្មីបំផុតនៃការអង្កេត អ.ប.ស.ក ឆ្នាំ២០០០ ២០០៥ និង២០១៤ សម្រាប់ផ្នែកអំពើហិង្សាក្នុងគ្រួសារ

**តារាង ៤.៤**.សមាមាត្រស្ត្រីដែលធ្លាប់មានដៃគូ និងក្មេងស្រីអាយុ១៥ឆ្នាំឡើងធ្លាប់ទទួលរងអំពើហិង្សា

លើរាងកាយ ផ្លូវភេទ ឬផ្លូវចិត្ត ប្រព្រឹត្តដោយដៃគូស្និទ្ធស្នាលបច្ចុប្បន្ន ឬអតីតអំឡុងពេល១២ខែកន្លងមក បែងចែកតាមប្រភេទអំពើហិង្សា និងក្រុមអាយុ

**តារាង ៥.១**. មូលហេតុស្វែងរកជំនួយ និងមិនស្វែងរកជំនួយរបស់ស្ត្រីដែលធ្លាប់ទទួលរងអំពើហិង្សាលើរាងកាយ ឬផ្លូវភេទដោយដៃគូស្និទ្ធស្នាលនៃការអង្កេតរបស់អង្គការសុខភាពពិភពលោក (WHO) ២០១៥[1]

[1] ក្រសួងកិច្ចការនារី, ឆ្នាំ២០១៥, ការស្រាវជ្រាវថ្នាក់ជាតិស្តីពីសុខភាព និងបទពិសោធន៍ក្នុងជីវិតរបស់ស្ត្រីក្នុងប្រទេសកម្ពុជាឆ្នាំ២០១៥" របស់អង្គការសុខភាពពិភពលោក អង្គការសហប្រជាជាតិដើម្បីស្ត្រី,រាជរដ្ឋាភិបាលកម្ពុជា ដកស្រង់ពី http://asiapacific.unwomen.org/en/digital-library/publications/2015/11/national-survey-on-women-s-health-and-life-experiences-in-cambodia#view ថ្ងៃទី១២ ខែកក្កដា ឆ្នាំ២០១៦។

# ឧបសម្ព័ន្ធតារាងស្ថិតិ

**តារាង ក១៖** អត្រាប្រេវ៉ាឡង់នៃអំពើហិង្សាលើរាងកាយ ផ្លូវភេទ ផ្លូវចិត្ត រាងកាយ ឬផ្លូវភេទ និងរាងកាយ ឬផ្លូវភេទឬផ្លូវចិត្តដោយដៃគូស្និទ្ធស្នាលបច្ចុប្បន្ន បែងចែកតាមលក្ខណៈប្រជាសាស្ត្រ

**តារាង ក២៖** អត្រាប្រេវ៉ាឡង់នៃអំពើហិង្សាលើរាងកាយ ផ្លូវភេទ ផ្លូវចិត្ត រាងកាយឬផ្លូវភេទ និងរាងកាយ ផ្លូវភេទឬផ្លូវចិត្តដោយដៃគូស្និទ្ធស្នាលបច្ចុប្បន្នអំឡុងពេល ១២ខែកន្លងមក បែងចែកតាមលក្ខណៈប្រជាសាស្ត្រ

**តារាង ក៣៖** ប្រភេទនៃអំពើហិង្សាលើដៃគូស្និទ្ធស្នាលចំពោះស្ត្រីដែលធ្លាប់មានដៃគូ បែងចែកតាមដៃគូបច្ចុប្បន្ន ឬថ្មីបំផុត (អ.ប.ស.ក ឆ្នាំ ២០១៤)

**តារាង ក៤៖** បទពិសោធន៍អំពើហិង្សាលើរាងកាយក្នុងជីវិត និងអំឡុងពេល១២ខែកន្លងមកពីដៃគូស្និទ្ធស្នាលបច្ចុប្បន្ន បែងចែកតាមលក្ខណៈសាវតា (អ.ប.ស.ក ឆ្នាំ ២០១៤)

**តារាង ក៥៖** បទពិសោធន៍អំពើហិង្សាលើផ្លូវភេទក្នុងជីវិត និងអំឡុងពេល ១២ខែកន្លងមកដោយដៃគូស្និទ្ធស្នាលបច្ចុប្បន្ន បែងចែកតាមលក្ខណៈសាវតា (អ.ប.ស.ក ឆ្នាំ ២០១៤)

**តារាង ក៦៖** បទពិសោធន៍អំពើហិង្សាលើផ្លូវចិត្តក្នុងជីវិត និងរយៈពេល ១២ខែកន្លងមកពីដៃគូស្និទ្ធស្នាលបច្ចុប្បន្ន បែងចែកតាមលក្ខណៈសាវតា (អ.ប.ស.ក ឆ្នាំ ២០១៤)

**តារាង ក៧៖** ប្រេវ៉ាឡង់នៃអំពើហិង្សាលើដៃគូស្និទ្ធស្នាលក្នុងចំណោមស្ត្រីធ្លាប់មានដៃគូ (អ.ប.ស.ក ឆ្នាំ ២០១៤)

**តារាង ក៨៖** ឥរិយាបថត្រួតត្រាប្រព្រឹត្តដោយដៃគូស្និទ្ធស្នាលបច្ចុប្បន្ន ឬថ្មីបំផុតក្នុងជីវិតក្នុងចំណោមស្ត្រីធ្លាប់មានដៃគូ (អ.ប.ស.ក ២០១៤)

**តារាង ក៩៖** ប្រេវ៉ាឡង់នៃអំពើហិង្សាលើរាងកាយ ផ្លូវភេទ និង ផ្លូវចិត្ត បង្កឡើងដោយដៃគូស្និទ្ធស្នាល (រួមបញ្ចូលប្រភេទផ្សេងៗ) បែងចែកតាមកត្តាហានិភ័យដែលបង្កដោយដៃគូស្និទ្ធស្នាល ប្តីប្រពន្ធនិងស្ត្រី (រួមទាំងសូចនាករពង្រឹងភាពអង់អាច) (អ.ប.ស.ក ឆ្នាំ ២០១៤)

**តារាង ក១០៖** អំពើហិង្សាប្រព្រឹត្តដោយស្ត្រីទៅលើប្តី/ដៃគូនៅពេលគ្មានការវាយដំពីដៃគូ (អ្នកធ្លាប់មានដៃគូបច្ចុប្បន្ន ឬថ្មីបំផុត) (អ.ប.ស.ក ឆ្នាំ២០១៤)

**តារាង ខ១.** បទពិសោធន៍អំពើហិង្សាលើរាងកាយក្នុងជីវិតប្រព្រឹត្តដោយអ្នកក្រៅពីដៃគូស្និទ្ធស្នាលក្នុងចំណោមស្ត្រីដែលបានចូលរួមការអង្កេតផ្នែកអំពើហិង្សាក្នុងគ្រួសារ បែងចែកតាមលក្ខណៈសាវតា (អ.ប.ស.ក ឆ្នាំ២០១៤)

**តារាង ខ២៖** បទពិសោធន៍ទទួលរងអំពើហិង្សាផ្លូវភេទក្នុងជីវិតប្រព្រឹត្តដោយអ្នកក្រៅពីដៃគូ ក្នុងចំណោមស្ត្រីដែលបានចូលរួមការអង្កេតផ្នែកអំពើហិង្សាក្នុងគ្រួសារ បែងចែកតាមលក្ខណៈ សាវតា (អ.ប.ស.ក ឆ្នាំ ២០១៤)

**តារាង ខ៣៖** ស្ត្រីរងអំពើហិង្សាអំឡុងពេលមានផ្ទៃពោះ

**តារាង ខ៤៖** ឥរិយាបថស្វែងរកជំនួយរបស់ស្ត្រីពេលជួបអំពើហិង្សាក្នុងចំណោមស្ត្រីដែលបានចូលរួមការអង្កេតផ្នែកអំពើហិង្សាក្នុងគ្រួសារ បែងចែកតាមលក្ខណៈសាវតា (អ.ប.ស.ក ឆ្នាំ ២០១៤)

**តារាង គ១៖** លក្ខណៈសាវតានៃអ្នកចូលរួមការអង្កេតផ្នែកអំពើហិង្សាក្នុងគ្រួសារ អ.ប.ស.កឆ្នាំ២០០០, ២០០៥ និង២០១៤

**តារាង គ២៖** បទពិសោធន៍អំពើហិង្សាលើរាងកាយ ឬផ្លូវភេទពីដៃគូស្និទ្ធស្នាលក្នុងជីវិត(ដៃគូបច្ចុប្បន្ន/ថ្មីបំផុត) បែងចែកតាមលក្ខណៈសាវតានៃ អ.ប.ស.កទាំងបី

# បញ្ជីរូបភាព

**រូបភាពទី ៣.១**. សមាមាត្រស្ត្រីធ្លាប់មានដៃគូបានរាយការណ៍អំពើហិង្សាក្នុងជីវិតលើរាងកាយ ផ្លូវភេទ ផ្លូវចិត្តនិង/ឬផ្នែកសេដ្ឋកិច្ចពីដៃគូស្និទ្ធស្នាល (អ.ប.ស.ក ឆ្នាំ២០១៨)

**រូបភាពទី ៣.២**. ភាពត្រួតគ្នានៃអំពើហិង្សាលើរាងកាយ និងផ្លូវភេទក្នុងជីវិតពីដៃគូស្និទ្ធស្នាល បច្ចុប្បន្ន ឬថ្មីបំផុតក្នុងចំណោមស្ត្រីធ្លាប់មានដៃគូ (អ.ប.ស.ក ឆ្នាំ២០១៨)

**រូបភាពទី ៣.៣**. ភាពត្រួតគ្នានៃអំពើហិង្សាលើរាងកាយ ផ្លូវភេទ និងផ្លូវចិត្តក្នុងជីវិតពីដៃគូស្និទ្ធស្នាល បច្ចុប្បន្ន ឬថ្មីបំផុតក្នុងចំណោមស្ត្រីធ្លាប់មានដៃគូ(អ.ប.ស.កឆ្នាំ២០១៨)

**រូបភាពទី ៣.៤**. ប្រេវ៉ាឡង់នៃអំពើហិង្សាលើរាងកាយអំឡុងពេល១២ខែកន្លងមក និងក្នុងជីវិតពីដៃគូស្និទ្ធស្នាលក្នុងចំណោមស្ត្រីធ្លាប់មានដៃគូបែងចែកតាមក្រុមអាយុ (អ.ប.ស.ក ឆ្នាំ២០១៨)

**រូបភាពទី ៣.៥**. សកម្មភាពជាក់លាក់នៃអំពើហិង្សាលើរាងកាយក្នុងជីវិតពីដៃគូស្និទ្ធស្នាលក្នុងចំណោមស្ត្រីធ្លាប់ មានដៃគូ (អ.ប.ស.ក ឆ្នាំ២០១៨)

**រូបភាពទី ៣.៦**. ប្រេវ៉ាឡង់អំពើហិង្សាលើផ្លូវភេទអំឡុងពេល១២ខែកន្លងមក និងក្នុងជីវិតពីដៃគូស្និទ្ធស្នាលក្នុងចំណោមស្ត្រីធ្លាប់មានដៃគូបែងចែកតាមក្រុមអាយុ (អ.ប.ស.កឆ្នាំ២០១៨)

**រូបភាពទី ៣.៧**. សកម្មភាពជាក់លាក់នៃអំពើហិង្សាលើផ្លូវភេទក្នុងជីវិតពីដៃគូស្និទ្ធស្នាលក្នុងចំណោមស្ត្រីធ្លាប់មានដៃគូ (អ.ប.ស.កឆ្នាំ២០១៨)

**រូបភាពទី ៣.៨**.សកម្មភាពជាក់លាក់នៃអំពើហិង្សាលើផ្លូវចិត្ត និងផ្នែកសេដ្ឋកិច្ចក្នុងជីវិតពីដៃគូស្និទ្ធស្នាលក្នុងចំណោមស្ត្រីធ្លាប់មានដៃគូ (អ.ប.ស.ក ឆ្នាំ២០១៨)

**រូបភាពទី ៣.៩**.សមាមាត្រស្ត្រីធ្លាប់ទទួលឥរិយាបថត្រួតត្រាជាក់លាក់ពីដៃគូស្និទ្ធស្នាលបច្ចុប្បន្ន ឬថ្មីបំផុត បែងចែកតាមស្ថានភាពអាពាហ៍ពិពាហ៍ក្នុងចំណោមស្ត្រីធ្លាប់មានដៃគូ(អ.ប.ស.កឆ្នាំ ២០១៨)

**រូបភាពទី ៣.១០**.សមាមាត្រស្ត្រីធ្លាប់ទទួលរងអំពើហិង្សាលើរាងកាយ ផ្លូវភេទ ផ្លូវចិត្តពីដៃគូស្និទ្ធស្នាលបច្ចុប្បន្ន ឬថ្មីបំផុត បែងចែកតាមកត្តាហានិភ័យ (អ.ប.ស.ក ឆ្នាំ២០១៨)

**រូបភាពទី ៣.១១**. ប្រេវ៉ាឡង់នៃអំពើហិង្សាអំឡុងពេលមានផ្ទៃពោះ បែងចែកតាមស្ថានភាពអាពាហ៍ពិពាហ៍ក្នុងចំណោមស្ត្រីធ្លាប់មានដៃគូ (អ.ប.ស.ក ឆ្នាំ២០១៨)

**រូបភាពទី ៣.១២**. ការប្រៀបធៀបសមាមាត្រនៃស្ត្រីដែលធ្លាប់ទទួលរងការវាយដំពីដៃគូស្និទ្ធស្នាលបច្ចុប្បន្ន ឬថ្មីបំផុត ជាមួយស្ត្រីធ្លាប់ទទួលរងអំពើហិង្សាលើរាងកាយពីដៃគូស្និទ្ធស្នាលក្នុងចំណោមស្ត្រីធ្លាប់មានដៃគូ (អ.ប.ស.ក ឆ្នាំ២០១៨)

**រូបភាពទី ៣.១៣**.ជនប្រព្រឹត្តអំពើហិង្សាលើរាងកាយក្នុងចំណោមស្ត្រីដែលបានចូលរួមការអង្កេតផ្នែកអំពើហិង្សាក្នុងគ្រួសារ បែងចែកតាមស្ថានភាពអាពាហ៍ពិពាហ៍ (អ.ប.ស.ក ឆ្នាំ២០១៨)

**រូបភាពទី ៣.១៤**. ភាគរយស្ត្រីធ្លាប់ទទួលរងអំពើហិង្សាពីដៃគូស្និទ្ធស្នាល ឬក្រៅពីដៃគូស្និទ្ធស្នាល បានស្វែងរកជំនួយ បែងចែកតាមចំនួនកូនរស់នៅក្នុងគ្រួសារ (អ.ប.ស.ក ឆ្នាំ២០១៤)

**រូបភាពទី ៤.១**. ប្រៀបធៀបប្រេវ៉ាឡង់អំពើហិង្សាក្នុងជីវិត និងអំឡុងពេល ១២ខែកន្លងមក សម្រាប់ស្ត្រីធ្លាប់មានដៃគូស្និទ្ធស្នាលបច្ចុប្បន្ន ឬដៃគូថ្មីបំផុតនៃអ.ប.ស.ក ឆ្នាំ២០០០ ២០០៥ និង២០១៤

**រូបភាពទី ៤.២**. ផលធៀបនៃសមាមាត្រស្ត្រីធ្លាប់មានដៃគូស្និទ្ធស្នាលទទួលរងអំពើហិង្សាលើរាងកាយ លើផ្លូវភេទ ឬ លើរាងកាយឬផ្លូវភេទអំឡុងពេល១២ខែកន្លងមក និងសមាមាត្រស្ត្រីធ្លាប់ទទួលរងអំពើហិង្សាក្នុងជីវិត អ.ប.ស.ក ឆ្នាំ២០០០ ២០០៥ និង ២០១៤

**រូបភាពទី ៥.១**. អត្រាប្រេវ៉ាឡង់អំពើហិង្សាលើរាងកាយ ឬផ្លូវភេទ៖ ប្រៀបធៀបលទ្ធផល អ.ប.ស.ក ឆ្នាំ២០១៤ និងការស្រាវជ្រាវប្រេវ៉ាឡង់ថ្នាក់ជាតិ (អង្គការសុខភាពពិភពលោក ឆ្នាំ២០១៥)

**រូបភាពទី ៥.២ ក**. ភាពត្រួតគ្នានៃអំពើហិង្សាលើរាងកាយ និងផ្លូវភេទក្នុងជីវិតពីដៃគូស្និទ្ធស្នាលក្នុងចំណោមស្ត្រីធ្លាប់មានដៃគូដែលបានរាយការណ៍ថាធ្លាប់ទទួលរងអំពើហិង្សាលើរាងកាយ និង/ឬផ្លូវភេទពីដៃគូស្និទ្ធស្នាល(អង្គការសុខភាពពិភពលោក ឆ្នាំ២០១៥)

**រូបភាពទី ៥.២ ខ**. ភាពត្រួតគ្នានៃអំពើហិង្សាលើរាងកាយ និងផ្លូវភេទពីដៃគូស្និទ្ធស្នាលក្នុងជីវិតក្នុងចំណោមស្ត្រីធ្លាប់មានដៃគូដែលបានរាយការណ៍ថាធ្លាប់ទទួលរងអំពើហិង្សាលើរាងកាយ និង/ឬផ្លូវភេទពីដៃគូស្និទ្ធស្នាល(អ.ប.ស.ក ឆ្នាំ២០១៤)

**រូបភាពទី ៥.៣** មូលហេតុស្វែងរក និងមិនស្វែងរកជំនួយរបស់ស្ត្រីដែលធ្លាប់ទទួលរងអំពើហិង្សាផ្លូវកាយ ឬផ្លូវចិត្តពីដៃគូស្និទ្ធស្នាល (អង្គការសុខភាពពិភពលោក ឆ្នាំ២០១៥)

# សទ្ទានុក្រម

| បណ្តុំពាក្យ | និយមន័យ |
|---|---|
| ឥរិយាបថត្រួតត្រា | រួមមាន ប្រច័ណ្ឌហួសហេតុ បង្ខាំង តាមដានរាល់សកម្មភាព គ្រប់ទីកន្លែង គ្រប់ការចូលរួមក្នុងសង្គម ទៅរកសេវាព្យាបាល និងការងារក្នុងគោលបំណងដើម្បីត្រួតត្រាឥរិយាបថលើដៃគូ[2] |
| អំពើហិង្សាក្នុងគ្រួសារ | ប្រព្រឹត្តដោយមនុស្សពេញវ័យ ឬមនុស្សវ័យជំទង់ទៅលើសមាជិកគ្រួសារ (បរិបទក្នុងគ្រួសារ) រួមបញ្ចូលរាល់ទម្រង់នៃការវាយដំ និងសម្តែងអាកប្បកិរិយាគំរាមកំហែង ។ អំពើហិង្សាក្នុងគ្រួសារភាគច្រើនប្រព្រឹត្តដោយដៃគូស្និទ្ធស្នាល [3] |
| អំពើហិង្សាផ្នែកសេដ្ឋកិច្ច | ការគ្រប់គ្រងថវិកា បដិសេធមិនឱ្យចូលរួមក្នុងការធ្វើសេចក្តីសម្រេចលើការចាយវាយថវិកា មិនផ្តល់លុយកាក់សម្រាប់ចាយវាយក្នុងគ្រួសារ ត្រួតត្រាលើការជ្រើសរើសការងារ/មុខរបរ ឬសកម្មភាពផ្សេងៗក្នុងការរកប្រាក់ចំណូល[4] |
| អំពើហិង្សាលើផ្លូវចិត្ត | សម្តែងភាពមិនស្មោះត្រង់ធ្វើឱ្យអាម៉ាស់មុខ សម្លុត បំភ័យ គំរាមកំហែង ឈ្លោះប្រកែក គំរាមប្រើអំពើហិង្សាក្នុងចេតនាញុះញង់ធ្វើឱ្យភ័យខ្លាច និងសម្តែងឥរិយាបថត្រួតត្រា[4] |
| ធ្លាប់មានដៃគូ | សំដៅលើស្ត្រីដែលធ្លាប់មានដៃគូស្និទ្ធស្នាល ។ ស្ត្រីធ្លាប់មានដៃគូអាចមិនស្ថិតក្នុងទំនាក់ទំនងភាពជាដៃគូស្និទ្ធស្នាលនាពេលបច្ចុប្បន្ន។ ស្ត្រីដែល "ធ្លាប់រៀបការ" ជាផ្នែកមួយនៃក្រុមទាំងនេះ |
| អំពើហិង្សាទាក់ទងនឹងយេនឌ័រ | ជាសកម្មភាពបង្កទុក្ខទោសដែលប្រព្រឹត្តប្រឆាំងនឹងបំណងរបស់បុគ្គលណាម្នាក់ ដោយយកហេតុផលផ្អែកលើផ្នត់គំនិតសង្គមជាប្រពៃណីទាក់ទងនឹងការកំណត់ភាពខុសគ្នានៃតួនាទីក្នុងសង្គមរវាងបុរសនិងស្ត្រី [5] |

[2]Breiding MJ, Basile KC, Smith SG, Black MC, Mahendra RR. ការឃ្លាំមើលអំពើហិង្សាលើប្តី/ដៃគូ៖ និយមន័យផ្លូវការ និងការផ្តល់អនុសាសន៍លើទិន្នន័យ បោះពុម្ពលើកទី 2.0. Atlanta (GA)៖ មជ្ឈមណ្ឌលជាតិត្រួតពិនិត្យ និងបង្ការរបួស និងមជ្ឈមណ្ឌលតាមដាន និងបង្ការជំងឺឆ្លងឆ្នាំ២០១៥

[3]អង្គការសហប្រជាជាតិដើម្បីស្ត្រី៖ និយមន័យអំពើហិង្សាក្នុងគ្រួសារ ដកស្រង់ពី http://www.endvawnow.org/en/articles/398-definition-of-domestic-violence.html ២៩ សីហា ឆ្នាំ២០១៦ ។

[4]អង្គការសហប្រជាជាតិដើម្បីស្ត្រី៖សទ្ទានុក្រមពីផ្នែកភាពសំខាន់នៃកម្មវិធី និងការតាមដានត្រួតពិនិត្យ និងវាយតម្លៃពី http://www.endvawnow.org/en/articles/347-glossary-of-terms-from-programming-essentials-and-monitoring-and-evaluation-sections.html ២៩ សីហា ឆ្នាំ២០១៦។

[5]មហាសន្និបាតអង្គការសហប្រជាជាតិ៖សេចក្តីប្រកាសស្តីពីការលុបបំបាត់អំពើហិង្សាលើស្ត្រី (A/RES/48/104). ឆ្នាំ១៩៩៣។

| | |
|---|---|
| ចំនួនករណី | ជាចំនួនព្រឹត្តិការណ៍ដែលកើតឡើងថ្មីៗក្នុងពេលវេលាជាក់លាក់ណាមួយដែលការវាស់វែងនេះ រាប់បញ្ចូលតែករណីដែលកើតឡើងថ្មីៗប៉ុណ្ណោះ [6] |
| ដៃគូស្និទ្ធស្នាល | សំដៅលើប្ដីបច្ចុប្បន្ន និងអតីត ដៃគួរួមភេទ សង្សារ ។ល។ ទោះមានឬគ្មានទំនាក់ទំនងផ្លូវភេទក្ដី។ មិនរាប់បញ្ចូលឪពុក អ្នកជិតខាង មិត្តភក្តិធម្មតាទេ។ល។ |
| អំពើហិង្សាពីដៃគូស្និទ្ធស្នាល | អំពើហិង្សាលើរាងកាយ ផ្លូវភេទ ផ្លូវចិត្ត ឬផ្នែកសេដ្ឋកិច្ចដែលប្រព្រឹត្តដោយដៃគូស្និទ្ធស្នាល ឬប្ដីបច្ចុប្បន្ន ឬអតីត[2] |
| ជនក្រៅពីដៃគូ | ស្ត្រីដែលមិនធ្លាប់មានទំនាក់ទំនងជាមួយដៃគូស្និទ្ធស្នាល |
| អំពើហិង្សាលើរាងកាយ | រួមមានសកម្មភាពដូចជា វាយ រុញ ទាញដៃ គប់អ្វីមួយ ទះ មួលដៃ ទាញសក់ ដាល់ ទាត់អូស ផ្ដួល ដុត វាយប្រហារដោយប្រើ កាំបិត កាំភ្លើង ឬអាវុធអ្វីមួយ[4] |
| ប្រេវ៉ាឡង់ | ជាសមាមាត្រនៃបុគ្គលដែលទទួលរងពីព្រឹត្តិការណ៍អ្វីមួយក្នុងពេលវេលាជាក់លាក់ រាប់បញ្ចូលព្រឹត្តិការណ៍ដែលបានកើតរួចហើយនិងកើតឡើងថ្មី (ស្ត្រីទើបទទួលរងអំពើហិង្សា និងស្ត្រីធ្លាប់ទទួលអំពើហិង្សា ច្រើនលើករួចមកហើយ)[6] |
| អំពើហិង្សាផ្លូវភេទ | ជាអំពើបង្ខិតបង្ខំដើម្បីរួមភេទ បៀតបៀនកេរ្តិ៍ខ្មាស ដោយប្រើប្រាស់កម្លាំងជាដើម[4] |
| អំពើហិង្សាលើស្ត្រី | ជាសកម្មភាពហិង្សាណាមួយទាក់ទងនឹងយេនឌ័រ បង្កឱ្យឈឺចាប់ផ្នែករាងកាយ ផ្លូវភេទ និងគំរាមកំហែងផ្លូវចិត្តស្ត្រី ដូចជា សកម្មភាពគំរាមបង្ខំ បិទសិទ្ធិសេរីភាពទោះនៅកន្លែងសាធារណៈ ឬជីវិតឯកជនក្ដី[5] |

[6] J. M. A វចនានុក្រមស្រាវជ្រាវបោះពុម្ពលើកទី 4th ចុងក្រោយ ញូវយ៉ក: សារព័ត៌មានសកលវិទ្យាល័យ Oxford ២០០១។

# សេចក្តីសង្ខេប

របាយការណ៍វិភាគលម្អិតនេះបានប្រើប្រាស់ទិន្នន័យដែលមានស្រាប់នៅក្នុងឯកសារការអង្កេតប្រជាសាស្ត្រ និងសុខភាពកម្ពុជា (**អ.ប.ស.ក**) ឆ្នាំ២០១៤ ផ្នែកអំពើហិង្សាក្នុងគ្រួសារ រួមទាំងនិន្នាការអំពើហិង្សាដោយដៃគូស្និទ្ធស្នាល ដោយប្រើទិន្នន័យ**អ.ប.ស.ក** ឆ្នាំ២០០០ ២០០៥ និង២០១៤។ ការវិភាគទិន្នន័យនេះធ្វើឡើង ដើម្បីផ្តល់ព័ត៌មានលម្អិតស៊ីជំម្រៅ និងឆ្លើយតបតាមបរិបទនៃតម្រូវការទិន្នន័យ។ វិធីសាស្ត្រក្នុងការវិភាគទិន្នន័យនេះ មានរួមបញ្ចូលការពន្យល់ពាក្យគន្លឹះ និងការវាស់វែងលក្ខណៈនៃអំពើហិង្សាដែលបង្ហាញនៅក្នុងផ្នែកទី២នៃរបាយការណ៍នេះ ។

**របកគំហើញសំខាន់ៗ**

- ច្រើនជាង ៣០% នៃស្ត្រីកម្ពុជាធ្លាប់ទទួលរងអំពើហិង្សាលើរាងកាយ លើផ្លូវភេទ លើផ្លូវចិត្ត ឬលើផ្នែកសេដ្ឋកិច្ចក្នុងជីវិត ដែលបង្កឡើងដោយដៃគូស្និទ្ធស្នាលរបស់ពួកគេ ។
- អំពើហិង្សាលើរាងកាយ និងផ្លូវភេទដែលបង្កឡើងដោយដៃគូស្និទ្ធស្នាលមានភាពត្រួតស៊ីគ្នាកម្រិតខ្ពស់។ ភាគច្រើននៃស្ត្រីដែលធ្លាប់រងអំពើហិង្សាផ្លូវភេទពីដៃគូស្និទ្ធស្នាលក៏ធ្លាប់ទទួលរងអំពើហិង្សាទាំងលើរាងកាយ និងលើផ្លូវភេទពីដៃគូស្និទ្ធស្នាលផងដែរ។
- កត្តាសំខាន់ៗដែលបណ្តាលឱ្យស្ត្រីកម្ពុជាទទួលរងអំពើហិង្សាពីដៃគូស្និទ្ធស្នាល រួមមាន៖
    - ដៃគូស្និទ្ធស្នាលស្រវឹងញឹកញាប់
    - ដៃគូស្និទ្ធស្នាលបង្ហាញពីឥរិយាបថត្រួតត្រាកម្រិតខ្ពស់
    - ស្ត្រីមានការភ័យខ្លាចដៃគូស្និទ្ធស្នាល
    - ស្ត្រី និងដៃគូស្និទ្ធស្នាលមានចំណេះដឹងទាប
    - ធ្លាប់ឃើញបទពិសោធន៍ដែលឪពុកវាយម្តាយកាលនៅក្មេង
    - មានកូនច្រើនរស់នៅក្នុងបន្ទុកគ្រួសារ
- ស្ត្រីដែលលែងលះឬរស់នៅបែកគ្នាទំនងជាហ៊ានរាយការណ៍ពីបទពិសោធន៍អំពើហិង្សាដែលជាមូលហេតុនៃការបែកបាក់គ្នាពីដៃគូស្និទ្ធស្នាល ឬស្ត្រីទាំងនោះមានសេរីភាពក្នុងការនិយាយអំពីបទពិសោធន៍អំពើហិង្សាដែលជាមូលហេតុ នាំឱ្យមានការបែកបាក់ពីដៃគូស្និទ្ធស្នាល ។
- ស្ត្រីដែលផ្តល់ចម្លើយក្នុងការអង្កេតបានស្វែងរក និងទទួលជំនួយនៅពេលមានអំពើហិង្សាភាគច្រើនពីសមាជិកគ្រួសារ មិត្តភក្តិ និងអ្នកជិតខាង ។
- តាមរយៈការវិភាគលើសមាមាត្រនៃស្ត្រីដែលធ្លាប់ទទួលរងអំពើហិង្សាបង្កឡើងដោយដៃគូស្និទ្ធស្នាល ស្ត្រីដែលធ្លាប់ទទួលរងអំពើហិង្សាបង្កឡើងដោយដៃគូស្និទ្ធស្នាលក្នុងរយៈពេល១២ខែកន្លងមក មានការថយចុះជាលំដាប់ដែលអាចសន្និដ្ឋានបានថាអំពើហិង្សាទំនងជានឹងបញ្ឈប់ ឬស្ត្រីអាចនឹងចាកចេញពីដៃគូស្និទ្ធស្នាលដែលប្រើអំពើហិង្សា។

## អនុសាសន៍

អនុសាសន៍ខាងក្រោមនេះត្រូវបានពិភាក្សាយ៉ាងលម្អិតនៅក្នុងផ្នែកទី៦នៃរបាយការណ៍នេះ។ របកគំហើញដែលបង្ហាញក្នុងរបាយការណ៍នេះបានបញ្ចូលនូវទិន្នន័យដែលបានពិពណ៌នាក្នុងរបាយការណ៍នៃការស្រាវជ្រាវថ្នាក់ជាតិស្ដីពីសុខភាព និងបទពិសោធន៍ក្នុងជីវិតរបស់ស្ត្រីនៅប្រទេសកម្ពុជាឆ្នាំ២០១៥។ ហេតុនេះអនុសាសន៍ក្នុងរបាយការណ៍នេះបានបន្សុីជាមួយអនុសាសន៍ដែលផ្ដល់ក្នុងឯកសារការស្រាវជ្រាវថ្នាក់ជាតិខាងលើ។

**ការលើកកម្ពស់សមភាពយេនឌ័រ និងពង្រឹងភាពអង់អាចដល់ស្ត្រី ៖** ទិន្នន័យដែលបានបង្ហាញខាងលើនេះបានគាំទ្រដល់ភស្តុតាងអន្តរជាតិដែលរកឃើញថានៅពេលស្ត្រីទទួលបានធនធានច្រើនឡើងភាពងាយរងគ្រោះដោយអំពើហិង្សាអំឡុងពេល១២ខែកន្លងមកហាក់មានភាពថយចុះ។

**ផ្លាស់ប្ដូរបទដ្ឋានសង្គម ឬផ្នត់គំនិតក្នុងការទទួលយកអំពើហិង្សាលើស្ត្រី ៖** ស្ត្រីប្រហែល ៥០% ដែលផ្ដល់ចម្លើយក្នុងការអង្កេតប្រជាសាស្ត្រ និងសុខភាពបានយល់ស្របថាប្ដីអាចវាយប្រពន្ធរបស់ខ្លួនដោយមានហេតុផលគ្រប់គ្រាន់តែមួយប៉ុណ្ណោះ។

**លើកកម្ពស់ភាពជាបុរសដែលគ្មានអំពើហិង្សា ឈានឆ្ពោះទៅរកសមភាព និងការគោរពគ្នា៖** ដៃគូស្និទ្ធស្នាលគឺជាអ្នកប្រព្រឹត្តអំពើហិង្សាលើរាងកាយស្ត្រី។ ស្ត្រីបានរាយការណ៍ថាអំពើហិង្សាលើរាងកាយដែលប្រព្រឹត្តដោយដៃគូស្និទ្ធស្នាលជាបុរសមានចំនួន៣ដងច្រើនជាងអ្នកប្រព្រឹត្តអំពើហិង្សាជាស្ត្រី។

**លើកកម្ពស់ផាសុកភាពក្នុងគ្រួសារ និងបរិយាកាសដែលគ្មានអំពើហិង្សាសម្រាប់កុមារ៖** ស្ត្រីដែលធ្លាប់ឃើញអំពើហិង្សារបស់ឪពុកម្ដាយតាំងពីកុមារភាព គឺងាយរងគ្រោះដោយសារអំពើហិង្សាលើរាងកាយ ឬផ្លូវភេទពីដៃគូស្និទ្ធស្នាល។

**ដោះស្រាយការសេពគ្រឿងស្រវឹង៖** ការស្រាវជ្រាវបានបង្ហាញថា កម្រិតនៃការប្រើប្រាស់គ្រឿងស្រវឹងមានទំនាក់ទំនងយ៉ាងជិតស្និទ្ធជាមួយនឹងហានិភ័យនៃការប្រព្រឹត្តអំពើហិង្សា។

**បង្កើនការវិនិយោគលើសេវាគាំទ្រ៖** ទាមទារឱ្យមានការជំរុញ និងលើកទឹកចិត្តដើម្បីឱ្យស្ត្រីទទួលបានសេវាគាំទ្រ។ ការវិនិយោគបន្ថែមគួរពិចារណាលើការបណ្ដុះបណ្ដាលដល់អ្នកផ្ដល់សេវាគាំទ្រគ្រប់វិស័យទាំងអស់ និងផ្សព្វផ្សាយឱ្យបានទូលំទូលាយអំពីសេវាគាំទ្រ និងធានាផ្ដល់នូវធនធានគ្រប់គ្រាន់សម្រាប់ការឆ្លើយតបឱ្យបានសមស្របតាមការកើនឡើងនូវតម្រូវការរបស់ស្ត្រីរងគ្រោះ។

**ជំរុញឱ្យមានយន្តការសម្របសម្រួលពេញលេញមួយក្នុងការឆ្លើយតបនិងទប់ស្កាត់អំពើហិង្សាលើស្ត្រី។**

# ផ្នែកទី១

## ១.សេចក្តីផ្តើម

### ១.១. លក្ខណៈសាវតា

ទិន្នន័យដែលប្រើប្រាស់សម្រាប់ការវិភាគក្នុងរបាយការណ៍នេះ បានដកស្រង់ចេញពីឯកសារការអង្កេតប្រជាសាស្ត្រ និងសុខភាពកម្ពុជា (អ.ប.ស.ក) ឆ្នាំ២០១៤ រួមទាំងការវិភាគអំពីនិន្នាការនៃអំពើហិង្សាដោយដៃគូស្និទ្ធស្នាល ដែលប្រើប្រាស់ទិន្នន័យអ.ប.ស.ក ឆ្នាំ២០០០ ២០០៥ និង ២០១៤។

**អ.ប.ស.ក** ជាការអង្កេតថ្នាក់ជាតិដែលផ្តល់ទិន្នន័យគ្រប់គ្រាន់គួរជឿជាក់ដើម្បីត្រួតពិនិត្យ និងវាយតម្លៃទៅលើសូចនាករផ្នែកប្រជាជន សុខភាព និងអាហារូបត្ថម្ភ[7]។ ផ្នែកអំពើហិង្សាក្នុងគ្រួសារ[8] បានផ្តល់ការវាស់វែងពីប្រេវ៉ាឡង់ និងផលវិបាកនៃអំពើហិង្សាបង្កដោយប្តីបច្ចុប្បន្ន ឬអតីត ឬដៃគូស្និទ្ធស្នាលផ្សេងទៀត[9] ក៏ដូចជាអ្នកបង្កហិង្សាផ្សេងទៀតដែលបានបង្ហាញក្នុង **អ.ប.ស.ក** ទាំង៣លើកគឺនៅឆ្នាំ២០០០ ២០០៥ និង២០១៤។ ចំពោះ **អ.ប.ស.ក**ឆ្នាំ២០១៤ ការវិភាគទិន្នន័យ និងការសរសេររបាយការណ៍បានរៀបចំឡើងក្នុងឆ្នាំ២០១៥ ដើម្បីផ្តល់ទិន្នន័យសម្រាប់វាស់វែងគោលដៅចុងអាណត្តិនៃគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍កម្ពុជាក្នុងខែកញ្ញាឆ្នាំ២០១៥ ។ ការវិភាគផ្នែកអំពើហិង្សាក្នុងគ្រួសារធ្វើឡើងតាមទម្រង់បទដ្ឋានតារាង និងការពន្យល់អំពីលទ្ធផល[10] ។ ទោះជាការវិភាគលើផ្នែកអំពើហិង្សានេះធ្វើឡើងបានយ៉ាងត្រឹមត្រូវ តែមានគំនិតជាច្រើនទៀតយល់ឃើញថាវាពិតជាសារប្រយោជន៍បន្ថែមទៀតក្នុងការវិភាគលម្អិតទិន្នន័យអំពីអំពើហិង្សាក្នុងគ្រួសារក្នុង **អ.ប.ស.ក** លើសពីទម្រង់បទដ្ឋានតារាងដែលបានកំណត់ ដើម្បីផ្តល់ទិន្នន័យស៊ីជម្រៅបកស្រាយ ទិន្នន័យទៅតាមបរិបទ។ ទិន្នន័យនេះអាចផ្តល់ការសន្និដ្ឋានសម្រាប់ការរៀបចំកម្មវិធី និង គោលនយោបាយដើម្បីស្វែងរកការគាំទ្រ និងកំណត់គោលដៅបន្ថែមទៀតក្នុងការគាំទ្រដល់ផែនការសកម្មភាពជាតិដើម្បីទប់ស្កាត់អំពើហិង្សាលើស្ត្រី[11]។ គួរកត់សម្គាល់ថាការវិភាគទិន្នន័យ ដែលមានស្រាប់នេះមិនមែនបញ្ជាក់ថាការវិភាគទិន្នន័យលើរបាយការណ៍ដើមមិនមានភាពត្រឹមត្រូវនោះទេ។ គោលបំណងនៃរបាយការណ៍នេះគឺ ដើម្បីបំពេញបន្ថែមទិន្នន័យដែលមានស្រាប់ហើយអាចប្រើប្រាស់បានកាន់តែ

[7] http://dhsprogram.com/What-We-Do/Survey-Types/DHS.cfm#sthash.2mYa0u3e.dpuf

[8] ក្នុងបាយការណ៍នេះពាក្យអំពើហិង្សាក្នុងគ្រួសារនឹងត្រូវបានប្រើប្រាស់ដើម្បីបកស្រាយពីអំពើហិង្សាលើរាងកាយ ផ្លូវភេទ ផ្លូវចិត្ត និងផ្នែកសេដ្ឋកិច្ចដែលប្រព្រឹត្តដោយប្តីទៅលើប្រពន្ធ។

[9] ក្នុងរបាយការណ៍នេះពាក្យដៃគូជិតស្និទ្ធសំដៅលើប្តីបច្ចុប្បន្ន/អតីត ឬដៃគូរួមភេទ(ដែលទំនាក់ទំនងស្រដៀងគ្នាទៅនឹងមិត្តប្រុស ឬប្តី) គូដណ្តឹង ដៃគូណាត់ជួបមិនថាពួកគេមានទំនាក់ទំនងផ្លូវភេទឬអត់។ "សង្សារ"ដែលសំដៅលើ អតិថិជនដែលមករកសេវាផ្លូវភេទជាទៀតទាត់មិនត្រូវបានរាប់បញ្ចូលក្នុងក្រុមនេះឡើយ ។

[10] វិទ្យាស្ថានជាតិស្ថិតិ អគ្គនាយកដ្ឋានបច្ចេកទេសសុខាភិបាល និងICF អន្តរជាតិ, ២០១៥ស្តីពីការអង្កេតប្រជាសាស្ត្រ និងសុខភាពកម្ពុជា២០១៤ រាជធានី ភ្នំពេញកម្ពុជានិង Rockville, Maryland, USA: វិទ្យាស្ថានជាតិស្ថិតិ អគ្គនាយកដ្ឋានបច្ចេកទេសសុខាភិបាលនិងICF អន្តរជាតិ https://dhsprogram.com/pubs/pdf/FR312/FR312.pdf

[11] ព្រះរាជាណាចក្រកម្ពុជា ២០១៤។ ផែនការសកម្មភាពជាតិស្តីពីការទប់ស្កាត់អំពើហិង្សាលើស្ត្រី ២០១៤-២០១៨ ។ បានអនុម័តដោយគណៈរដ្ឋមន្ត្រីក្នុងកិច្ចប្រជុំពេញអង្គថ្ងៃទី ៥ ធ្នូ ២០១៤ រៀបចំដោយក្រសួងកិច្ចការនារី ។

ទូលំទូលាយសម្រាប់អ្នករៀបចំគោលនយោបាយ និងស្វែងរកការគាំទ្រ ដើម្បីកាត់បន្ថយបញ្ហាប្រឈមនៃអំពើហិង្សាដែលបង្កឡើងដោយដៃគូស្និទ្ធស្នាលទៅលើស្ត្រីនៅក្នុងប្រទេសកម្ពុជាប៉ុណ្ណោះ។

### តើដឹងអ្វីខ្លះអំពីអំពើហិង្សាក្នុងគ្រួសារនៅប្រទេសកម្ពុជាពីការអង្កេតមុនៗ ?

មានឯកសារមួយចំនួនបានចងក្រងពីប្រេវ៉ាឡង់ការប្រព្រឹត្តអំពើហិង្សា និងបទពិសោធន៍នៃអំពើហិង្សាដែលបង្កឡើងដោយប្តី/ដៃគូស្និទ្ធស្នាលផ្សេងទៀត[12]នៅក្នុងប្រទេសកម្ពុជា។របាយការណ៍មួយដែលបានបោះពុម្ពផ្សាយជាលើកដំបូងដោយ Zimmerman បានវិភាគពីលក្ខណៈនៃអំពើហិង្សាក្នុងគ្រួសារ និងឫសគល់នៃអំពើហិង្សា ព្រមទាំងផលប៉ះពាល់ជាក់ស្តែងតាមរយៈការសម្ភាសន៍ស៊ីជម្រៅបែបគុណភាពជាមួយជនរងគ្រោះចំនួន៥០នាក់ និងអ្នកពាក់ព័ន្ធផ្សេងទៀតដែលស្ត្រីបានស្វែងរកជំនួយ[13]។ ការសិក្សានេះបានបង្ហាញថាស្ត្រី និងអ្នកគាំទ្របានរាយការណ៍ថា ស្ត្រីត្រូវបានគេរំលោភបំពានដោយប្រើអំពើហិង្សាយ៉ាងធ្ងន់ធ្ងរញឹកញាប់ ហើយលក្ខណៈ និងវិសាលភាពនៃអំពើហិង្សានេះមិនត្រូវបានលាតត្រដាងឡើយ។

ក្រៅពីការស្រាវជ្រាវលើកដំបូងរបស់ Zimmerman ភាគច្រើននៃការស្រាវជ្រាវពាក់ព័ន្ធនឹងការវាស់វែងអត្រាប្រេវ៉ាឡង់នៃអំពើហិង្សាលើដៃគូស្និទ្ធស្នាលនៅប្រទេសកម្ពុជាបានពឹងផ្អែកទាំងស្រុងលើទិន្នន័យស្តីពីអំពើហិង្សាក្នុងគ្រួសារនៃ**អ.ប.ស.ក** ផលិតឡើងនៅឆ្នាំ២០០០ និង២០០៥។ ឧទាហរណ៍៖ របាយការណ៍របស់ Yount និង Carrera បានបង្ហាញទិន្នន័យនៅក្នុង **អ.ប.ស.ក ឆ្នាំ** ២០០០ ថា ២៤.៧%នៃស្ត្រីធ្លាប់ទទួលរងអំពើហិង្សាលើផ្លូវចិត្ត លើរាងកាយ ឬផ្លូវភេទពីប្តីបច្ចុប្បន្ន[14]។ Yount និង Carrera បានសិក្សាពីផលប៉ះពាល់នៃចំណងអាពាហ៍ពិពាហ៍ និងបទពិសោធន៍ទទួលរងអំពើហិង្សាក្នុងគ្រួសារលើកដំបូងក្នុងជីវិត ព្រមទាំងឥរិយាបថរំលោភបំពានលើប្រពន្ធ។ ការសិក្សារកឃើញថា ស្ត្រីទទួលរងអំពើហិង្សាបានរាយការណ៍ថា ប្តី/ដៃគូរបស់គាត់បានបញ្ចប់ការសិក្សាកម្រិតខ្ពស់ ហើយពួកគាត់ធ្លាប់រស់នៅក្នុងទីប្រជុំជនតាំងពីកុមារភាព និងធ្លាប់ឃើញអំពើហិង្សាលើម្តាយរបស់ពួកគាត់ មានភាពងាយទទួលរងអំពើហិង្សាក្នុងគ្រួសារលើរាងកាយ និងផ្លូវចិត្ត[15]។

អេង (Eng) និងសហសេវិក បានប្រើប្រាស់ទិន្នន័យអំពើហិង្សាក្នុងគ្រួសារនៅក្នុងអ.ប.ស.ក ឆ្នាំ២០០៥ ដើម្បីសិក្សាពីផលប៉ះពាល់នៃការត្រួតត្រារបស់ប្តី និងភាពញឹកញាប់នៃអំពើហិង្សាក្នុងគ្រួសារទៅលើស្ត្រីដែលធ្លាប់រៀបការរួចនៅកម្ពុជា។ ការសិក្សានេះធ្វើលើស្ត្រីដែលធ្លាប់រៀបការចំនួន

[12]នៅក្នុងសេចក្តីផ្តើមនេះ មានពាក្យគន្លឹះជាច្រើនត្រូវបានប្រើប្រាស់ដើម្បីពន្យល់អំពីអំពើហិង្សាលើដៃគូស្និទ្ធស្នាល រួមមានអំពើហិង្សាក្នុងគ្រួសារ អំពើហិង្សាក្នុងទំនាក់ទំនងប្តីប្រពន្ធ និងអំពើហិង្សាលើដៃគូដែលអ្នកនិពន្ធបានប្រើប្រាស់ពាក្យទាំងនេះ ស្របតាមឯកសារដែលព័ត៌មានបានដកស្រង់មក។ ក្នុងរបាយការណ៍នេះ ពាក្យអំពើហិង្សាលើដៃគូស្និទ្ធស្នាលសំដៅលើអំពើហិង្សាដែលប្រព្រឹត្តដោយដៃគូស្និទ្ធស្នាលទៅលើស្ត្រី។

[13] Zimmerman, C. ឆ្នាំ១៩៩៥ស្តីពីចានក្នុងរាវគង់នឹងរណ្តំ៖អំពើហិង្សាក្នុងគ្រួសារនៅក្នុងប្រទេសកម្ពុជា រាជធានីភ្នំពេញ គម្រោងប្រឆាំងនឹងអំពើហិង្សា ក្នុងគ្រួសារ ១៩៩៥ លេខ xi ទំព័រ ២៦៣។

[14]ការអង្កេត **អ.ប.ស.ក** លើកមុន ២០០០ និង ២០០៥ មានតែស្ត្រីធ្លាប់រៀបការដែលមានលក្ខណៈគ្រប់គ្រាន់ចូលរួមផ្តល់ចម្លើយផ្នែកអំពើហិង្សាក្នុងគ្រួសារ។ ដូច្នេះ អំពើហិង្សាសំដៅលើអំពើហិង្សាដែលប្រព្រឹត្តដោយប្តី ឬអតីតប្តី ឬអំពើហិង្សាក្នុងទំនាក់ទំនងប្តីប្រពន្ធ។

[15]Yount, K.M. Carrera, J.S. ២០០៦ អំពើហិង្សាក្នុងគ្រួសារលើស្ត្រីធ្លាប់រៀបការនៅកម្ពុជា។ Social Forces 85(1): ទំព័រ ៣៥៤-៣៨៧។

១.៧០៧ នាក់ ដែលបានផ្តល់សម្ភាសន៍ក្នុងការអង្កេត អ.ប.ស.ក ឆ្នាំ២០០៥ លើផ្នែកអំពើហិង្សាក្នុងគ្រួសារ។ ការសិក្សានេះបង្ហាញថា ២២%នៃស្ត្រីធ្លាប់ទទួលរងអំពើហិង្សាលើរាងកាយ ផ្លូវភេទ ឬផ្លូវចិត្តតាំងពីអាយុ១៥ឆ្នាំ។ ស្ត្រីដែលធ្លាប់រងអំពើហិង្សាលើរាងកាយ និងផ្លូវភេទមានទំនាក់ទំនងទៅនឹងការប្រើឥរិយាបថត្រួតត្រាក្នុងសិទ្ធិជាប្តី ខណៈដែលអំពើហិង្សាផ្លូវចិត្តជាប់ទាក់ទងទៅនឹងភាពញឹកញាប់នៃការប្រើអំពើហិង្សា។ របាយការណ៍នោះបានបកស្រាយលើរបកគំហើញទាំងនេះ ដោយផ្តល់មតិយោបល់ថា នៅទីណាមានបុរសបង្ហាញពីភាពបិតាធិបតេយ្យនៅក្នុងគ្រួសារ ពេលនោះការពិភាក្សារបស់ស្ត្រីជាញឹកញាប់ត្រូវបានចាត់ទុកថាជាការរំលោភបំពានលើទំនៀមទំលាប់ប្រពៃណីដែលស្ត្រីត្រូវនៅស្ងៀម និងចាំទទួលការបង្គាប់បញ្ជា[16] ។

ថ្មីៗនេះនៅក្នុងឆ្នាំ២០១៥ ដោយមានការគាំទ្រពីអង្គការសុខភាពពិភពលោក(WHO) និងអង្គការសហប្រជាជាតិដើម្បីស្ត្រី (UNWomen) រាជរដ្ឋាភិបាលកម្ពុជាបានធ្វើការអង្កេតអំពីប្រេវ៉ាឡង់នៃអំពើហិង្សារួមជាមួយដៃគូពាក់ព័ន្ធនៅកម្ពុជា ដោយប្រើប្រាស់វិធីសាស្ត្រអង្កេតដែលរៀបចំដោយក្រុមការងារអន្តរប្រទេសរបស់អង្គការសុខភាពពិភពលោកស្តីពីសុខភាពនិងអំពើហិង្សាក្នុងគ្រួសារ។ អង្កេតនេះផ្តោតទៅលើស្ត្រីដែលមានអាយុពី១៥-៦៤ឆ្នាំ ខណៈដែល **អ.ប.ស.ក** ផ្តោតទៅលើស្ត្រីដែលមានអាយុពី១៥-៤៩ឆ្នាំ។ របកគំហើញសំខាន់ៗរួមមាន ក្នុងចំណោមស្ត្រីដែលធ្លាប់មានដៃគូស្និទ្ធស្នាល ១៥% បានរាយការណ៍ថា ធ្លាប់រងអំពើហិង្សាលើរាងកាយពីដៃគូស្និទ្ធស្នាល ហើយ១០.២%បានរាយការណ៍ថាធ្លាប់រងអំពើហិង្សាផ្លូវភេទដោយដៃគូស្និទ្ធស្នាល និង២០.៩% ធ្លាប់រងអំពើហិង្សាលើរាងកាយ ឬផ្លូវភេទពីដៃគូស្និទ្ធស្នាលក្នុងជីវិតរបស់ពួកគេ។

**បុរសអ្នកប្រព្រឹត្តអំពើហិង្សា ៖** ប្រទេសកម្ពុជាបានចូលរួមការសិក្សាអំពីបុរស និងអំពើហិង្សានៅអាស៊ី និងប៉ាស៊ីហ្វិកកម្រិតអន្តរប្រទេសរបស់អង្គការសហប្រជាជាតិ។ តាមការប្រើប្រាស់បច្ចេកទេសការរាយការណ៍ផ្ទាល់ខ្លួន អ្នកស្រាវជ្រាវបានស្វែងយល់អំពីការប្រើប្រាស់ទម្រង់ផ្សេងៗនៃអំពើហិង្សាលើស្ត្រីពីបុរស ជាពិសេសអំពើហិង្សាប្រព្រឹត្តដោយដៃគូស្និទ្ធស្នាល និងអ្នកក្រៅពីដៃគូស្និទ្ធស្នាល។ ការអង្កេតនេះធ្វើឡើងទៅលើប្រាំបួនតំបន់ផ្សេងគ្នានៅប្រទេសកម្ពុជា ដោយប្រើតំណាងសំណាកគំរូថ្នាក់ជាតិ (តំបន់នៅសល់ត្រូវបានបែងចែកសំណាកគំរូទីប្រជុំជន និងជនបទ)។ ក្នុងចំណោមសំណាកគំរូទាំងនោះ បុរស១៦.៤%បានរាយការណ៍ថាពួកគេធ្លាប់បានប្រើអំពើហិង្សាលើរាងកាយទៅលើដៃគូ ខណៈដែល ២០.៨% បានរាយការណ៍ថាពួកគេធ្លាប់ប្រើអំពើហិង្សាលើផ្លូវភេទទៅលើដៃគូស្និទ្ធស្នាល(រួមទាំងប្រើកម្លាំងចាប់បង្ខំរួមភេទ)។៥៤.៣%នៃបុរសបានរាយការណ៍ថា យ៉ាងហោចណាស់ពួកគេបានធ្វើសកម្មភាពមួយក្នុងការប្រព្រឹត្តិអំពើហិង្សាលើផ្លូវចិត្ត និងយ៉ាងហោចណាស់៥៣.២%បានធ្វើសកម្មភាពរំលោភបំពានមួយលើផ្នែកសេដ្ឋកិច្ច។ អ្វីដែលជាចំណុចគួរ

[16]Eng, S. Li, Y. Muslow, M. Fischer, J. ២០១០ អំពើហិង្សាក្នុងគ្រួសារទៅលើស្ត្រី៖ ការត្រួតត្រារបស់ប្តី ភាពញឹកញាប់ការពិភាក្សារបស់ប្តីប្រពន្ធ និងអំពើហិង្សារាយការណ៍ដោយស្ត្រីនៅក្នុងប្រទេសកម្ពុជា។ ព្រឹត្តប័ត្រអំពើហិង្សាក្នុងគ្រួសារ លេខ២៥ ទំព័រ ២៣៧-២៤៦។ DOI 10.1007/s10896-009-9287-7

ចាប់អារម្មណ៍ក្នុងរបាយការណ៍នេះគឺការរកឃើញពីកត្តាជំរុញឱ្យមានការប្រព្រឹត្តអំពើហិង្សាលើផ្លូវភេទ៖ "ការរាយការណ៍ជាទូទៅអំពីកត្តាជំរុញឱ្យមានការរំលោភផ្លូវភេទនៅតំបន់នៃការសិក្សាគឺទាក់ទងទៅនឹងការទទួលបានអំណាចខាងផ្លូវភេទ"(ទំព័រ ៣៩)[17]។

## ១.២. គោលបំណងនៃការអង្កេត

ជាការពិតជាក់ស្តែង ការងារដ៏មានសារៈសំខាន់មួយចំនួនត្រូវបានដំណើរការ ដូចជាការប្រមូលទិន្នន័យ និងការវាស់វែងអត្រាប្រេវ៉ាឡង់នៃអំពើហិង្សាលើដៃគូស្និទ្ធស្នាលនៅប្រទេសកម្ពុជា។ ការមានទិន្នន័យគ្រប់គ្រាន់បានផ្តល់នូវកាលានុវត្តភាពសម្រាប់វិភាគបន្ថែម ដើម្បីគាំទ្រដល់ការរៀបចំគោលនយោបាយ និងកម្មវិធីផ្សេងៗផ្អែកលើទិន្នន័យជាភស្តុតាង ។

**របាយការណ៍វិភាគទិន្នន័យដែលមានស្រាប់នេះមានគោលបំណងសំខាន់ដូចខាងក្រោម ៖**

ក. ដើម្បីផ្តល់ទិន្នន័យពេញលេញស្តីអំពីអំពើហិង្សាលើដៃគូស្និទ្ធស្នាលក្នុងការប្រៀបធៀបជាមួយរបាយការណ៍ **អ.ប.ស.ក**។ ការងារនេះធ្វើឱ្យមានភាពងាយស្រួលក្នុងការប្រៀបធៀបលទ្ធផលអំពើហិង្សាប្រព្រឹត្តដោយដៃគូស្និទ្ធស្នាលទៅនឹងការសិក្សាផ្សេងៗ ព្រមទាំងការរៀបចំរបាយការណ៍ស្តីអំពីគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព(SDG) (ប្រអប់១.១)[18]

ខ. ពិនិត្យមើលនិន្នាការនៃអំពើហិង្សាលើដៃគូស្និទ្ធស្នាលក្នុងពេលកន្លងមក ដោយប្រើប្រាស់ទិន្នន័យ **អ.ប.ស.ក** ចំនួន ៣លើក ដើម្បីស្វែងយល់ពីស្ថានភាពតាមរយៈទិន្នន័យនេះ។

គ. ផ្នែកចុងក្រោយនៃរបាយការណ៍នេះនឹងធ្វើការប្រៀបធៀប និងរបកគំហើញនៃអំពើហិង្សាជាមួយការស្រាវជ្រាវប្រេវ៉ាឡង់ថ្នាក់ជាតិនៃអំពើហិង្សាលើដៃគូស្និទ្ធស្នាលដែលប្រើប្រាស់វិធីសាស្រ្តរបស់អង្គការសុខភាពពិភពលោក (WHO) ដែលស្រាវជ្រាវក្នុងអំឡុងពេលដូចគ្នា ។

### *ប្រអប់ ១.១. សូចនាករគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពស្តីពីអំពើហិង្សាលើស្ត្រី*

**៥.២.១** សមាមាត្រស្ត្រីធ្លាប់មានដៃគូស្និទ្ធស្នាល និងក្មេងស្រីអាយុ ១៥ឆ្នាំឡើងធ្លាប់រងអំពើហិង្សាលើរាងកាយ ផ្លូវភេទ ផ្លូវចិត្តពីដៃគូស្និទ្ធស្នាលបច្ចុប្បន្ន ឬអតីតក្នុងរយៈពេល ១២ខែកន្លងមក បែងចែកតាមទម្រង់អំពើហិង្សា និងក្រុមអាយុ។

**៥.២.២** សមាមាត្រស្ត្រី និងក្មេងស្រីអាយុ ១៥ឆ្នាំឡើងធ្លាប់រងអំពើហិង្សាលើផ្លូវភេទក្រៅពីដៃគូស្និទ្ធស្នាលក្នុងរយៈពេល ១២ខែ កន្លងមក បែងចែកតាមទម្រង់អំពើហិង្សា ក្រុមអាយុ និងទីកន្លែងកើតហេតុ។

[17] Fulu, E. Warner, X. Miedema, S. Jewkes, R. Roselli, T. Lang, J. ២០១៣ ហេតុអ្វីបុរសប្រើអំពើហិង្សាលើស្ត្រី ហើយតើអាចការពាររបៀបណា? ការរកឃើញតាមបែបបរិមាណនៅពហុប្រទេសដោយអង្គការសហប្រជាជាតិស្តីពីការស្រាវជ្រាវពីបុរស និងអំពើហិង្សានៅអាស៊ី និងប៉ាស៊ីហ្វិក ក្រុងបាងកកៈ UNDP, UNFPA, UN Women and UNV.

[18]អង្គការសហប្រជាជាតិ ២០១៦៖ គោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព៖ គោលដៅទី៥ សម្រេចបាននូវសមភាពយេនឌ័រនិងការផ្តល់ភាពអង់អាចដល់ស្ត្រី និងកុមារីhttp://www.un.org/sustainabledevelopment/gender-equality/១១ កក្កដា ២០១៦។

## ១.៣. រចនាសម្ព័ន្ធនៃរបាយការណ៍

របាយការណ៍នេះត្រូវបានរៀបចំឡើងតាមផ្នែកដូចខាងក្រោម ៖

**ផ្នែកទី១៖** សេចក្តីផ្តើម

**ផ្នែកទី២៖** វិធីសាស្រ្តអង្កេតដែលប្រើប្រាស់ក្នុងផ្នែកអំពើហិង្សាក្នុងគ្រួសារនៃអ.ប.ស.ក។

**ផ្នែកទី៣៖** អំពើហិង្សាលើដៃគូស្និទ្ធស្នាលដែលបង្ហាញក្នុង អ.ប.ស.ក ឆ្នាំ២០១៩៖ ផ្នែកនេះផ្តោតលើអំពើហិង្សាលើដៃគូស្និទ្ធស្នាល ប៉ុន្តែបង្ហាញបន្ថែមពីទិន្នន័យអំពើហិង្សាដែលប្រព្រឹត្តដោយអ្នកក្រៅពីដៃគូស្និទ្ធស្នាល និងឥរិយាបថស្វែងរកជំនួយពេលទទួលរងអំពើហិង្សាពីដៃគូស្និទ្ធស្នាល និងអ្នកក្រៅពីដៃគូស្និទ្ធស្នាល។

**ផ្នែកទី៤៖** និន្នាការនៃអំពើហិង្សាលើដៃគូស្និទ្ធស្នាលកន្លងមក

**ផ្នែកទី៥៖** ប្រៀបធៀបលទ្ធផលនៃការអង្កេតរបស់អ.ប.ស.ក និងWHO លើប្រេវ៉ាឡង់នៃអំពើហិង្សាលើរាងកាយ ឬផ្លូវភេទដោយដៃគូស្និទ្ធស្នាល ។

**ផ្នែកទី៦៖** អនុសាសន៍សម្រាប់កិច្ចអន្តរាគមន៍កម្រិតគោលនយោបាយ តារាងស្ថិតិលម្អិតមានភ្ជាប់នៅក្នុងឧបសម្ព័ន្ធ

# ផ្នែកទី២

## ២. វិធីសាស្ត្រអង្កេត

ទិន្នន័យដែលបានប្រើប្រាស់សម្រាប់ការវិភាគក្នុងរបាយការណ៍នេះ ទាញចេញពីឯកសារ អ.ប.ស.កផ្នែកអំពើហិង្សាក្នុងគ្រួសារឆ្នាំ២០១៤(ផ្នែកទី៣) និងការវិភាគលើពេលវេលាដកស្រង់ចេញពី ទិន្នន័យ អ.ប.ស.ក ផ្នែកអំពើហិង្សាក្នុងគ្រួសារឆ្នាំ២០០៤, ២០០៥ និង២០១៤(ផ្នែកទី៤)។ មានភាព ខុសគ្នាតិចតួចប៉ុណ្ណោះក្នុងការប្រើប្រាស់វិធីសាស្ត្រប្រមូលទិន្នន័យរវាងឆ្នាំ២០០០ ២០០៥ និង ២០០១៤ ដែលការខុសគ្នានេះមានពន្យល់នៅក្នុងផ្នែកទី៤។

ខាងក្រោមនេះគឺជាការពន្យល់យ៉ាងសង្ខេបអំពីវិធីសាស្ត្រអង្កេត ដែលបានប្រើក្នុងការប្រមូល ទិន្នន័យអង្កេតឆ្នាំ២០១៤។ សម្រាប់សេចក្តីពន្យល់លម្អិតមានក្នុងរបាយការណ៍អ.ប.ស.ក[19] ។

### ២.១.សំណាកគំរូដែលបានជ្រើសរើស

សំណាកគំរូនៃ អ.ប.ស.កឆ្នាំ២០១៤ តំណាងឱ្យទូទាំងប្រទេស ក្នុងនោះមានសំណាកគំរូជាបុរស និងស្ត្រីដែលមានអាយុពី១៥-៤៩ឆ្នាំ។ ក្របខ័ណ្ឌសំណាកគំរូដែលបានប្រើក្នុងការអង្កេតនេះយក ចេញពីបញ្ជីជំរឿនប្រជាជនទូទៅនៅប្រទេសកម្ពុជាឆ្នាំ២០០៨ ដែលផលិតដោយវិទ្យាស្ថានជាតិស្ថិតិ ។

សំណាកគំរូត្រូវបានរៀបចំចំណាត់ថ្នាក់ជា២ដំណាក់កាលផ្សេងៗគ្នា។ ដំណាក់កាលបឋមគឺ ជ្រើសរើសសំណាកគំរូ ៦១១ មណ្ឌលសម្ភាសន៍ (ក្នុងនោះទីប្រជុំជនមាន១៨៨ និងជនបទ៤២៣ ហើយក្នុងមួយមណ្ឌលសម្ភាសន៍មានចំនួន៩៩គ្រួសារជាមធ្យម) ដែលត្រូវបានជ្រើសក្នុងលក្ខណៈ ប្រូបាបីលីតេធៀបនឹងទំហំគ្រួសារដែលមាន។ ដោយឡែកមណ្ឌលសម្ភាសន៍ដែលមានទំហំធំលើស ពី២០០គ្រួសារនឹងត្រូវបំបែកជាផ្នែកតូចៗ ហើយមណ្ឌលសម្ភាសន៍តែមួយប៉ុណ្ណោះដែលត្រូវជ្រើស ដោយចៃដន្យសម្រាប់អង្កេតនេះ ។ ដំណាក់កាលបន្ទាប់ ការអង្កេតប្រើប្រាស់ប្រព័ន្ធប្រូបាបីលីតេ ស្មើភាពដាច់ខាតសម្រាប់ជ្រើសរើសសំណាកគំរូគ្រួសារ ដោយជ្រើសរើស ២៤គ្រួសារ ពីមណ្ឌល សម្ភាសន៍នៅទីប្រជុំជន និងជនបទ២៨គ្រួសារ ។ មណ្ឌលសម្ភាសន៍ដែលមាននៅទីប្រជុំជនត្រូវបាន ជ្រើសរើសលើស(oversampling)។ មេគុណសំណាកគំរូ (weigthed) ត្រូវបានប្រើប្រាស់ក្នុងការវិភាគ ដោយប្រើមេគុណសំណាកគំរូ ដើម្បីកែតម្រូវនូវភាពខុសគ្នានៃប្រូបាបីលីតេនៃការជ្រើសរើស។ ចំនួន សំណាកគំរូសរុប ១៦,៣៥៦ គ្រួសារត្រូវបានជ្រើសរើស ហើយ១៥,៩៣៧ គ្រួសារត្រូវបានសម្ភាសន៍ និង១៥,៨២៥ (៩៩%)គ្រួសារបានផ្តល់សម្ភាសន៍សម្រាប់បញ្ជីសំណួរប្រកបដោគជ័យ។ ក្នុងចំណោម គ្រួសារដែលបានសម្ភាសន៍ទាំងនេះ ស្ត្រីចំនួន១៨,០១២ ត្រូវបានកំណត់ថាមានលក្ខណៈគ្រប់គ្រាន់ ចូលរួមក្នុងការសម្ភាសន៍(ស្ត្រីមានអាយុពី១៥-៤៩ឆ្នាំ ដែលរស់នៅក្នុងគ្រួសារជា អចិន្ត្រៃយ៍ ឬជាភ្ញៀវក្តី

[19]វិទ្យាស្ថានជាតិស្ថិតិ អគ្គនាយកដ្ឋានបច្ចេកទេសសុខាភិបាល និង ICF អន្តរជាតិ, ២០១៥. អង្កេតប្រជាសាស្ត្រ និងសុខភាពកម្ពុជា ២០១៤រាជធានី ភ្នំពេញកម្ពុជានិង Rockville, Maryland, USA: វិទ្យាស្ថានជាតិស្ថិតិ អគ្គនាយកដ្ឋានបច្ចេកទេសសុខាភិបាលនិងICFអន្តរជាតិ ។

បើបានស្នាក់នៅក្នុងគ្រួសារមុនយប់ថ្ងៃធ្វើអង្កេតត្រូវបានជ្រើសរើសសម្រាប់សម្ភាសន៍ទាំងអស់)។ ស្ត្រីចំនួន ១៧,៥៧៨ នាក់ត្រូវបានសម្ភាសន៍ក្នុងអត្រា(៩៧.៦%)។

ចំណេះដឹងអំពីអំពើហិង្សាក្នុងគ្រួសារត្រូវបានអនុវត្តន៍នៅក្នុងសំណាកគំរូរងនៃក្រុមគ្រួសារ។ មានតែស្ត្រីមួយនាក់ប៉ុណ្ណោះក្នុងមួយគ្រួសារដែលត្រូវបានជ្រើសរើសមកសម្ភាសន៍។ ជាលទ្ធផល ស្ត្រីអាយុពី១៥-៤៩ឆ្នាំ ចំនួន៤,៣០៧នាក់ (២៤.៥%) ចូលរួមផ្នែកអំពើហិង្សាក្នុងគ្រួសារ ក្នុងនោះ ៣,២៤៥នាក់(៧៥%)ធ្លាប់រៀបការ[20] ។ មេគុណអង្កេត (weighted) ត្រូវបានប្រើប្រាស់ក្នុងសំណាកគំរូរងផ្នែកអំពើហិង្សាក្នុងគ្រួសារដើម្បីធានាថា សំណាកគំរូរងអំពើហិង្សាក្នុងគ្រួសារជាតំណាងថ្នាក់ជាតិទាំងមូល និងឆ្លើយតបទៅនឹងការជ្រើសរើសប្រូបាប៊ីលីតេផ្សេងៗគ្នាសម្រាប់ស្ត្រីដែលរស់នៅក្នុងគ្រួសារអចិន្ត្រៃយ៍។ មានតែស្ត្រី២៨នាក់ (០.៦%)ក្នុងសំណាកគំរូរងប៉ុណ្ណោះដែលមិនបានសម្ភាសន៍ផ្នែកអំពើហិង្សាក្នុងគ្រួសារ ដោយសារឯកជនភាពគឺមិនត្រូវបានអនុញ្ញាត។

គួរកត់សម្គាល់ថា ការប្រមូលទិន្នន័យផ្នែកអំពើហិង្សាក្នុងគ្រួសារមានការលំបាកដែលតម្រូវឱ្យមានការបណ្តុះបណ្តាល ជាពិសេសជាងការបណ្តុះបណ្តាលទូទៅសម្រាប់ការអង្កេតអ.ប.ស.ក ដោយផ្តោតជាសំខាន់លើវិធីសាស្ត្រក្នុងការសួរសំណួរដ៏រសើប ដើម្បីធានាឱ្យបាននូវឯកជនភាព និងបង្កើតបរិយាកាសទំនាក់ទំនងល្អរវាងអ្នកសម្ភាសន៍និងអ្នកឆ្លើយតប ដើម្បីធានាសុវត្ថិភាព និងងាយស្រួលក្នុងឆ្លើយតបទៅនឹងស្ថានភាពលំបាកទាំងឡាយ ។

## ២.២. សន្ទានុក្រម និងនិយមន័យ

ផ្នែកអំពើហិង្សាក្នុងគ្រួសារបានប្រមូលទិន្នន័យអំពីអំពើហិង្សាដែលប្រព្រឹត្តដោយដៃគូស្និទ្ធស្នាល និងអំពើហិង្សាដែលប្រព្រឹត្តដោយអ្នកក្រៅពីដៃគូស្និទ្ធស្នាល ព្រមទាំងឥរិយាបថនៃការស្វែងរកជំនួយរបស់ស្ត្រីដែលធ្លាប់ទទួលរងអំពើហិង្សា។ បញ្ជីសំនួរផ្នែកអំពើហិង្សាក្នុងគ្រួសារនៃការអង្កេតឆ្នាំ២០១៤ មានភ្ជាប់នៅក្នុងឧបសម្ព័ន្ធ"គ"។

**អំពើហិង្សាក្នុងគ្រួសារ៖** អ្នកស្រាវជ្រាវមុនៗបានប្រើពាក្យ "អំពើហិង្សាក្នុងគ្រួសារ" ជំនួសដោយពាក្យ "អំពើហិង្សាលើដៃគូស្និទ្ធស្នាល"។ ការប្រើប្រាស់ពាក្យនេះនាំឱ្យមានការភ័ណ្ឌច្រឡំជាមួយពាក្យ "អំពើហិង្សាក្នុងគ្រួសារ" ដែលជាទូទៅសំដៅលើទម្រង់នៃអំពើហិង្សាណាមួយដែលកើតឡើងក្នុងចំណោមសមាជិកគ្រួសារ ឬ(សាច់ញាតិ )។ និយមន័យផ្នែកច្បាប់មិនរាប់បញ្ចូលដៃគូស្និទ្ធស្នាលនោះទេចំពោះស្ត្រីដែលមិនបានរៀបការស្របច្បាប់ ។

របាយការណ៍នេះនឹងមិនប្រើប្រាស់ពាក្យ"អំពើហិង្សាក្នុងគ្រួសារ"ទេ តែនឹងប្រើប្រាស់ពាក្យដូចខាងក្រោមដែលបង្ហាញភាពច្បាស់លាស់សម្រាប់ការវាស់វែង៖

- **អំពើហិង្សាលើដៃគូស្និទ្ធស្នាល៖**

[20] ពាក្យ"ធ្លាប់រៀបការ"សំដៅលើស្ត្រីដែលបានរៀបការហើយនៅពេលណាមួយក្នុងជីវិត។ ធ្លាប់រៀបការមិនសំដៅតែលើស្ត្រីដែលបច្ចុប្បន្នរៀបការឡើយ

អំពើហិង្សាណាមួយដែលប្រព្រឹត្តដោយដៃគូស្និទ្ធស្នាលបច្ចុប្បន្ន និងអតីត (ត្រឹមត្រូវតាមផ្លូវច្បាប់) ឬដៃគូរួមភេទ(មិនត្រឹមត្រូវតាមផ្លូវច្បាប់)។ ពាក្យនេះរាប់បញ្ចូលប្តី មិត្តប្រុស និងដៃគូរួមភេទ និងដៃគូមិនរួមភេទ។

- **អំពើហិង្សាប្រព្រឹត្តដោយអ្នកក្រៅពីដៃគូ៖**

អំពើហិង្សាណាមួយដែលបង្កឡើងដោយអ្នកប្រព្រឹត្តណាម្នាក់ដែលមិនមែនជាដៃគូស្និទ្ធស្នាល ដែលរួមបញ្ចូលសមាជិកគ្រួសារ (ម្តាយឪពុក ឬសមាជិកគ្រួសារផ្សេងទៀតរួមមាន មីង ពូ ជីដូនជីតា ជាដើម)។

- **ការវាស់វែងអំពីអំពើហិង្សា៖**

បទពិសោធន៍អំពើហិង្សាត្រូវបានវាស់វែងដោយប្រើប្រាស់កម្រងសំណួរស្តីពីឥរិយាបថពាក់ព័ន្ធនឹងប្រភេទអំពើហិង្សានីមួយៗដូចខាងក្រោម៖

- **អំពើហិង្សាលើរាងកាយដោយដៃគូស្និទ្ធស្នាល៖**

ស្ត្រីដែលធ្លាប់រៀបការត្រូវបានសួរ តើប្តីបច្ចុប្បន្ន ឬអតីត(អ្នកធ្លាប់រៀបការ) ឬដៃគូស្និទ្ធស្នាល៖

ក) រុញអ្នក ទាញដៃអ្នក ឬបោះ គប់អ្វីមួយទៅអ្នកដែរឬទេ?

ខ) ទះអ្នក?

គ) មួលដៃរបស់អ្នក ឬទាញសក់របស់អ្នក?

ឃ) ដាល់អ្នក ឬទាញសក់/ឬជាមួយនឹងអ្វីដែលអាចធ្វើឲ្យអ្នកឈឺ?

ង) ទាត់អ្នក អូសអ្នក ឬវាយអ្នក ?

ច) ព្យាយាមខ្ទប់មិនឱ្យអ្នកដកដង្ហើម ឬដុតអ្នកក្នុងគោលបំណងអ្វីមួយ?

ឆ) ព្យាយាមគំរាមកំហែងអ្នក ដោយប្រើកាំបិត កាំភ្លើង ឬអាវុធអ្វីមួយ

បើស្ត្រីឆ្លើយ "ចាស់" នូវចម្លើយណាមួយខាងលើនោះ ត្រូវបន្តសួរសំណួរអំពីភាពញឹកញាប់ (ញឹកញាប់/ម្តងម្កាល/មិនដែលសោះក្នុងរយៈពេល១២ខែកន្លងមក)ទៅតាមប្រភេទនៃសកម្មភាពក្នុងរយៈពេល១២ខែមុនអង្កេត។

- **អំពើហិង្សាលើផ្លូវភេទដោយដៃគូស្និទ្ធស្នាល៖**

ស្ត្រីដែលធ្លាប់រៀបការត្រូវបានសួរ តើប្តីបច្ចុប្បន្ន ឬអតីត(អ្នកធ្លាប់រៀបការ) ឬដៃគូស្និទ្ធស្នាលរបស់អ្នកធ្លាប់ធ្វើសកម្មភាពដូចខាងក្រោមនេះ ឬទេ?

ក) ប្រើកម្លាំងបង្ខំឱ្យរួមភេទជាមួយគាត់ (បុរស/ស្ត្រី) បើទោះបីមិនមានអារម្មណ៍ចង់រួមភេទ ?

ខ) ប្រើកម្លាំងបង្ខំឱ្យអ្នកធ្វើសម្មភាពរួមភេទណាមួយដែលអ្នកមិនចង់ធ្វើ?

គ) បង្ខំអ្នកដោយគំរាមកំហែង ឬវិធីផ្សេងទៀត ដើម្បីឱ្យអ្នកធ្វើសកម្មភាពផ្លូវភេទដែលអ្នកមិនចង់ធ្វើ?

ពេលស្ត្រីឆ្លើយ "ចាស៎"នូវចម្លើយណាមួយខាងលើត្រូវបន្តសួរសំណួរអំពីភាពញឹកញាប់ (ញឹកញាប់/ម្តងម្កាល/ មិនដែលក្នុងរយៈពេល១២ខែកន្លងមក) ទៅតាមប្រភេទនៃសកម្មភាពក្នុងរយៈពេល១២ខែមុនអង្កេត។

- **អំពើហិង្សាលើផ្លូវចិត្តដោយដៃគូស្និទ្ធស្នាល៖**

  ស្ត្រីធ្លាប់រៀបការរួចត្រូវបានសួរតើប្តីបច្ចុប្បន្ន ឬអតីត (អ្នកធ្លាប់រៀបការ) ឬដៃគូស្និទ្ធស្នាល៖

  ក) និយាយ ឬធ្វើអ្វីមួយដើម្បីបំបាក់មុខអ្នកនៅចំពោះមុខអ្នកដទៃដែរឬទេ?

  ខ) គំរាមធ្វើឱ្យអ្នកឈឺចាប់ ឬប៉ងធ្វើអំពើអាក្រក់ដាក់អ្នកឬអ្នកណាម្នាក់ដែលអ្នកយកចិត្តទុកដាក់ដែរឬទេ?

  គ) ជេរប្រមាថអ្នក ឬធ្វើឱ្យអ្នកមានអារម្មណ៍មិនល្អចំពោះខ្លួនឯងដែរឬទេ?

ពេលស្ត្រីឆ្លើយ "ចាស៎" នូវចម្លើយណាមួយខាងលើ ត្រូវបន្តសួរសំណួរអំពីភាពញឹកញាប់ (ញឹកញាប់/ម្តងម្កាល/មិនដែលក្នុងរយៈពេល ១២ខែកន្លងមក) ទៅតាមប្រភេទនៃសកម្មភាពក្នុងរយៈពេល១២ខែមុនអង្កេត។

- **ឥរិយាបថត្រួតត្រា៖**

  ស្ត្រីធ្លាប់រៀបការរួចត្រូវបានសួរ តើប្តីបច្ចុប្បន្ន ឬអតីត (អ្នកធ្លាប់រៀបការ) ឬដៃគូស្និទ្ធស្នាល៖

  ក) ប្រច័ណ្ឌ ឬខឹងបើអ្នកនិយាយជាមួយប្រុសដទៃ?

  ខ) តែងតែចោទជារឿយៗថាអ្នកមិនស្មោះត្រង់?

  គ) មិនអនុញ្ញាតឲ្យអ្នកជួបមិត្តភក្តិស្រីៗរបស់អ្នកដែរឬទេ?

  ឃ) ព្យាយាមកំណត់ការទាក់ទងជាមួយគ្រួសាររបស់អ្នក?

  ង) ទាមទារចង់ដឹងគ្រប់ពេលថាអ្នកនៅទីណា?

- **អំពើហិង្សាផ្នែកសេដ្ឋកិច្ច (ស្ថិតនៅជាផ្នែកមួយនៃឥរិយាបថត្រួតត្រា)៖**

  ស្ត្រីធ្លាប់រៀបការរួចត្រូវបានសួរ តើប្តីបច្ចុប្បន្ន ឬអតីត (អ្នកធ្លាប់រៀបការ) ឬដៃគូស្និទ្ធស្នាល៖

  ក) មិនដែលបានផ្តល់លុយ ដើម្បីចាយវាយក្នុងគ្រួសារ

  ខ) មិនទុកចិត្តអ្នកលើបញ្ហាលុយកាក់

- **អំពើហិង្សាលើរាងកាយ ឬផ្លូវភេទប្រព្រឹត្តដោយដៃគូស្និទ្ធស្នាលអតីត (មិនមែនដៃគូបច្ចុប្បន្ន ឬថ្មី)៖**

ស្ត្រីធ្លាប់រៀបការរួចត្រូវបានសួរសំណួរពីរបន្ថែមទាក់ទងនឹងអំពើហិង្សាលើដៃគូស្និទ្ធស្នាលដែលប្រព្រឹត្តដោយអតីតប្តី (ពោលគឺ មិនមែនប្តី ឬដៃគូស្និទ្ធស្នាលបច្ចុប្បន្ន ឬថ្មី)៖

ក) តើ(ប្តី/ដៃគូស្និទ្ធស្នាល)អតីត របស់អ្នកធ្លាប់បានវាយ ទះ ទាត់ ឬធ្វើអ្វីផ្សេងៗទៀតដែលធ្វើឱ្យអ្នកមានការឈឺចាប់លើរាងកាយដែរឬទេ?

ខ) តើ (ប្តី/ដៃគូស្និទ្ធស្នាល)អតីតរបស់អ្នកធ្លាប់បានប្រើកម្លាំងបង្ខំឱ្យអ្នករួមភេទតាមវិធីផ្សេងៗដែលអ្នកមិនចង់ដែរឬទេ?

- **បទពិសោធន៍នៃអំពើហិង្សាប្រព្រឹត្តដោយអ្នកក្រៅពីដៃគូ៖**

ស្ត្រីទាំងអស់ដែលចូលរួមក្នុងការអង្កេតផ្នែកអំពើហិង្សាក្នុងគ្រួសារ ត្រូវបានសួរអំពីអំពើហិង្សាលើរាងកាយ និងផ្លូវភេទដែលប្រព្រឹត្តដោយជនក្រៅពីដៃគូស្និទ្ធស្នាល។

- ចាប់ពីអ្នកមានអាយុ១៥ ឆ្នាំ តើមានអ្នកណាម្នាក់ (ក្រៅពីប្តី/ដៃគូរបស់អ្នក) បានវាយទះទាត់ធាក់ ឬបានប្រើវិធីផ្សេងទៀតដែលធ្វើឱ្យអ្នកឈឺចាប់លើរាងកាយដែរឬទេ?

ចម្លើយសម្រាប់ជ្រើសរើសរួមមាន៖

- ម្តាយ/ម្តាយចុង
- ឪពុក/ឪពុកចុង
- បងប្អូនស្រី/បងប្អូនប្រុស
- កូនស្រី/កូនប្រុស
- សាច់ញាតិផ្សេងទៀត
- អតីតប្តី/ដៃគូ
- មិត្តប្រុសបច្ចុប្បន្ន
- អតីតមិត្តប្រុស
- ម្តាយក្មេក
- ឪពុកក្មេក
- សាច់ថ្លៃផ្សេងទៀត
- គ្រូបង្រៀន
- ថៅកែ/អ្នកធ្វើការជាមួយ
- នគរបាល/ទាហាន

អ្នកប្រព្រឹត្តលើសពីម្នាក់អាចនឹងលើកឡើង។

ស្ត្រីចូលរួមក្នុងការអង្កេតផ្នែកអំពើហិង្សាត្រូវបានសួរអំពីបទពិសោធន៍ទទួលរងអំពើហិង្សាក្នុងអំឡុងពេលមានផ្ទៃពោះ និងសំណួរបន្ថែមទាក់ទងនឹងបទពិសោធន៍នៃការបង្ខំឱ្យរួមភេទ ឬធ្វើសកម្មភាពផ្លូវភេទដោយដៃគូស្និទ្ធស្នាល និងអ្នកក្រៅពីដៃគូ។

- តើមានអ្នកណាម្នាក់បានវាយទះទាត់ធាក់អ្នក ឬប្រើវិធីផ្សេងទៀតធ្វើឱ្យអ្នកឈឺចាប់លើរាងកាយដែរឬទេក្នុងអំឡុងពេលមានផ្ទៃពោះ**?**
- ក្នុងពេលណាមួយក្នុងជីវិតរបស់អ្នក ដូចជាកាលនៅជាក្មេងតូច ឬ មនុស្សពេញវ័យ តើមាននរណាម្នាក់ធ្លាប់បង្ខំអ្នកឱ្យរួមភេទ ដោយវិធីណាមួយ ឬ បង្ខំឱ្យប្រព្រឹត្តសកម្មភាពផ្លូវភេទដោយវិធីដែលអ្នកមិនចង់ដែរឬទេ?

ស្ត្រីដែលឆ្លើយ "ចាស៎" ទៅនឹងសំណួរណាមួយខាងលើត្រូវសួរបន្តថា តើអ្នកណាជាអ្នកប្រព្រឹត្តិ ? ចម្លើយសម្រាប់ជ្រើសរើសមានដូចខាងក្រោម៖

- ប្តី/ដៃគូបច្ចុប្បន្ន
- ម្តាយ/ម្តាយចុង
- ឪពុក/ឪពុកចុង
- បងប្អូនស្រី/បងប្អូនប្រុស
- កូនស្រី/កូនប្រុស
- សាច់ញាតិផ្សេងទៀត
- អតីតប្តី/ដៃគូ
- មិត្តប្រុសបច្ចុប្បន្ន
- អតីតមិត្តប្រុស
- ម្តាយក្មេក
- ឪពុកក្មេក
- សាច់ថ្លៃផ្សេងទៀត
- គ្រូបង្រៀន
- ថៅកែ/អ្នកធ្វើការជាមួយ
- នគរបាល/ទាហាន

អ្នកប្រព្រឹត្តលើសពីម្នាក់អាចនឹងលើកឡើង។

- **ការវាស់វែងឥរិយាបថក្នុងការស្វែងរកជំនួយ៖**

សម្រាប់ស្ត្រីដែលធ្លាប់ទទួលរងអំពើហិង្សា (អំពើហិង្សាលើរាងកាយ ឬផ្លូវភេទដែលប្រព្រឹត្តដោយដៃគូស្និទ្ធស្នាលបច្ចុប្បន្ន ឬអតីត ឬអ្នកក្រៅពីដៃគូ) ត្រូវបានសួរសំណួរពីឥរិយាបថក្នុងការស្វែងរកជំនួយ៖ តើអ្នកធ្លាប់បានព្យាយាមស្វែងរកការជួយដែរឬទេ? តើនរណាម្នាក់ដែលអ្នកស្វែងរកការជួយ? តើអ្នកធ្លាប់ប្រាប់នរណាម្នាក់អំពីបញ្ហាទាំងនេះដែរឬទេ?

ចម្លើយសម្រាប់ជ្រើសរើសមានដូចខាងក្រោម៖

- គ្រួសារ
- គ្រួសាររបស់ប្តី/ដៃគូ
- ប្តី/ដៃគូបច្ចុប្បន្ន ឬអតីត
- មិត្តប្រុសបច្ចុប្បន្ន/អតីត
- មិត្តភក្តិ
- អ្នកជិតខាង
- អ្នកដឹកនាំសាសនា
- វេជ្ជបណ្ឌិត/មន្ត្រីសុខាភិបាល
- នគរបាល

- អ្នកច្បាប់
- អង្គការផ្តល់សេវាសង្គម អាចជ្រើសរើសចម្លើយលើសពីមួយ។

## ២.៣. ការវិភាគទិន្នន័យ

ទិន្នន័យត្រូវបានវិភាគដោយប្រើប្រាស់កម្មវិធី SPSS ។ មេគុណសំណាកគំរូត្រូវបានប្រើប្រាស់ក្នុងការវិភាគ ដើម្បីធ្វើការកែតម្រូវភាពខុសគ្នាក្នុងការជ្រើសរើសប្រូបាប៊ីលីតេគ្រួសារ ក៏ដូចជាការជ្រើសរើសចំនួនស្ត្រីដែលមានលក្ខណៈគ្រប់គ្រាន់នៅក្នុងគ្រួសារយកមកសម្ភាសន៍ផ្នែកអំពើហិង្សាក្នុងគ្រួសារ ដោយសារការអង្កេតតម្រូវឱ្យមានស្ត្រីតែម្នាក់គត់ក្នុង១គ្រួសារ។ ការវិភាគបែបពិពណ៌នាបានប្រើប្រាស់ការគណនាជាភាគរយ និងភាពញឹកញាប់ដែលបង្ហាញជាតារាង។

អត្រាប្រេវ៉ាឡង់នៃអំពើហិង្សាក្នុងរបាយការណ៍នេះបានឆ្លុះបញ្ចាំងពីសមាមាត្រស្ត្រីដែលធ្លាប់ទទួលរងអំពើហិង្សា។ អត្រាប្រេវ៉ាឡង់នៃអំពើហិង្សាត្រូវបានវិភាគផ្អែកលើពេលវេលាផ្សេងគ្នាចំនួនពីរ៖

- ពេលវេលាណាមួយក្នុងជីវិតរបស់ស្ត្រី
- អំឡុងពេល១២ខែមុនការអង្កេត (រាប់បញ្ចូលទៅក្នុងពេលណាមួយក្នុងជីវិតរបស់ស្ត្រីផងដែរ)

ប្រអប់ខាងក្រោមសង្ខេបពីការបកស្រាយ និងការប្រើប្រាស់អត្រាប្រេវ៉ាឡង់តាមប្រភេទនៃពេលវេលា

***ប្រអប់ ២.១.ប្រៀបធៀបអត្រាប្រេវ៉ាឡង់ក្នុងជីវិត និងអំឡុងពេល១២ខែកន្លងមក៖ ការប្រើប្រាស់ និងការបកស្រាយ***

| ប្រេវ៉ាឡង់នៃអំពើហិង្សាអំឡុងពេល១២ខែកន្លងមក | |
|---|---|
| **ការបកស្រាយ** | **ការប្រើប្រាស់** |
| អត្រាប្រេវ៉ាឡង់អំឡុងពេល១២ ខែកន្លងមក បង្ហាញពីសមាមាត្រនៃស្ត្រីធ្លាប់ទទួលរងអំពើហិង្សាមួយឬច្រើនក្នុងអំឡុងពេល១២ ខែមុនការអង្កេត ហើយស្ថិតកៀកនឹងពេលវេលានៃការវាស់វែង។<br><br>វារាប់បញ្ចូលទាំងអំពើហិង្សាដែលទើបកើតថ្មីៗ និងអំពើហិង្សាដែលកើតបន្តជាច្រើនឆ្នាំមកហើយ។ បទពិសោធន៍អំពើហិង្សាអាចត្រូវបានបញ្ឈប់ក្នុងអំឡុងពេល១២ ខែកន្លងមក ឬអាចនឹងបន្ត។ | ទិន្នន័យទាំងនេះមានសារៈសំខាន់ណាស់សម្រាប់**រៀបចំផែនការសេវាកម្ម**ព្រោះវាបង្ហាញពីចំនួនស្ត្រីដែលកំពុងរស់ជាមួយអំពើហិង្សាតាមពេលវេលាជាក់លាក់ ហើយពួកគាត់អាចត្រូវការសេវាគាំទ្រ។<br><br>អត្រាប្រេវ៉ាឡង់អំឡុង១២ ខែកន្លងមកមានសារៈសំខាន់ណាស់សម្រាប់តាមដានការផ្លាស់ប្តូរ ដើម្បីបង្ហាញពីប្រសិទ្ធភាពនៃការអនុវត្តគោលនយោបាយ ឬកម្មវិធី ដោយសារថាអត្រានេះមានសារៈសំខាន់ក្នុងបង្ហាញពីការផ្លាស់ប្តូរតាមរយៈការវាស់វែងឡើងវិញក្នុងការអង្កេតនៅពីរ ឬបីឆ្នាំបន្ទាប់ខាងមុខ ។ |
| **ប្រេវ៉ាឡង់នៃអំពើហិង្សាក្នុងជីវិត** | |
| **ការបកស្រាយ** | **ការប្រើប្រាស់** |

| | |
|---|---|
| អត្រាប្រេវ៉ាឡង់ក្នុងជីវិតបានបង្ហាញពីសមាមាត្រនៃស្ត្រីបច្ចុប្បន្នដែលធ្លាប់ទទួលរងអំពើហិង្សាមួយ ឬច្រើននៅពេលណាមួយក្នុងជីវិត (តាមនិយមន័យ អត្រាប្រេវ៉ាឡង់ក្នុងជីវិតរាប់បញ្ចូលអត្រាប្រេវ៉ាឡង់វាស់វែងក្នុងអំឡុងពេល១២ ខែកន្លងមកផងដែរ)។<br><br>ដោយសារអត្រាប្រេវ៉ាឡង់អំឡុងពេល១២ខែកន្លងមកមិនបានប្រាប់ពីរយៈពេល ឬចំនួនប៉ុន្មានដង វាគ្រាន់តែបង្ហាញថាធ្លាប់កើតឡើងសូម្បីតែម្តង។ | ទិន្នន័យនេះមានសារៈសំខាន់សម្រាប់ការស្វែងរកការគាំទ្រមតិ និង យុទ្ធនាការលើកកម្ពស់ការយល់ដឹងអំពើហិង្សា ដោយសារ ទិន្នន័យ នេះបង្ហាញពីសមាមាត្រ នៃស្ត្រីដែលទទួលរងអំពើហិង្សាក្នុងជីវិត ។<br>ប្រេវ៉ាឡង់ក្នុងជីវិតមិនមានប្រយោជន៍ក្នុងការវាស់វែងប្រសិទ្ធភាពនៃការអនុវត្តគោលនយោបាយ ឬកម្មវិធីទេ ពីព្រោះវាមិនមានលក្ខណៈគ្រប់គ្រាន់សម្រាប់វាស់វែងការផ្លាស់ប្តូរក្នុងរយៈពេលខ្លី ។ ស្ត្រីម្នាក់ធ្លាប់ទទួលរងអំពើហិង្សាដែលផ្តល់ការសម្ភាសន៍កាលពី១០ឆ្នាំមុន ហើយការសម្ភាសន៍លើកទី២ នៅតែត្រូវបានបញ្ចូលក្នុងអត្រាប្រេវ៉ាឡង់ក្នុងជីវិតផងដែរ។ |

បន្ថែមពីលើការបកស្រាយនៃប្រេវ៉ាឡង់តាមប្រភេទនៃពេលវេលា សមាមាត្រនៃអត្រាប្រេវ៉ាឡង់អំឡុងពេល១២ខែកន្លងមក និងក្នុងជីវិតគឺជាការប៉ាន់ប្រមាណពីសមាមាត្រស្ត្រីដែលកំពុងរស់នៅជាមួយអំពើហិង្សាក្នុងចំណោមអ្នកធ្លាប់ទទួលរងអំពើហិង្សា។ ប្រេវ៉ាឡង់បានផ្តល់នូវព័ត៌មានថា តើមានភាពលំបាក ឬងាយស្រួលក្នុងការបញ្ឈប់អំពើហិង្សា ឬគេចផុតពីទំនាក់ទំនងបែបហិង្សា។

# ផ្នែកទី ៣

## ៣. អំពើហិង្សាលើដៃគូស្និទ្ធស្នាល

ផ្នែកនេះត្រូវបានបែងចែកជាពីរ៖ បទពិសោធន៍នៃអំពើហិង្សាលើដៃគូស្និទ្ធស្នាល និងអំពើហិង្សាផ្សេងៗទៀត។

មានតែស្ត្រីដែលធ្លាប់រៀបការ ឬមានដៃគូរួមភេទប៉ុណ្ណោះបានរាប់បញ្ចូលនៅក្នុងផ្នែកអំពើហិង្សាលើដៃគូស្និទ្ធស្នាល ខណៈពេល សំណាកគំរូស្ត្រីដែលបានជ្រើសរើសសម្រាប់ផ្នែកអំពើហិង្សាក្នុងគ្រួសារនៃការអង្កេត **អ.ប.ស.ក** រាប់បញ្ចូលទាំងអំពើហិង្សាប្រព្រឹត្តដោយអ្នកក្រៅពីដៃគូផងដែរ។ ហេតុនេះ ទំហំសំណាកគំរូដែលបានប្រើប្រាស់សម្រាប់គណនាប្រេវ៉ាឡង់មានភាពខុសគ្នាតាមផ្នែកនីមួយៗ។ ទំហំសំណាកគំរូគឺស្ត្រីដែលធ្លាប់មានដៃគូស្និទ្ធស្នាលចំនួន ៣,២៤៥នាក់[21] (ផ្នែកអំពើហិង្សាលើដៃគូស្និទ្ធស្នាល) និងស្ត្រីធ្លាប់មាន និងមិនធ្លាប់មានដៃគូចំនួន ៤,៣០៧នាក់ដែលបានចូលរួមការអង្កេតផ្នែកអំពើហិង្សាក្នុងគ្រួសារ (ផ្នែកអំពើហិង្សាប្រព្រឹត្តដោយអ្នកក្រៅពីដៃគូ) ។

### ៣.១. បទពិសោធន៍នៃអំពើហិង្សាលើដៃគូស្និទ្ធស្នាល

#### ទិដ្ឋភាពទូទៅនៃអំពើហិង្សាលើរាងកាយ ផ្លូវភេទ ផ្លូវចិត្ត និងផ្នែកសេដ្ឋកិច្ចពីដៃគូស្និទ្ធស្នាល

អង្កេតនេះបានវាស់វែងប្រភេទអំពើហិង្សាចំនួន៤ដែលប្រព្រឹត្តដោយដៃគូស្និទ្ធស្នាលរួមមាន៖ អំពើហិង្សាលើរាងកាយ ផ្លូវភេទ ផ្លូវចិត្ត និងលើផ្នែកសេដ្ឋកិច្ច។ គ្រប់ទម្រង់នៃអំពើហិង្សាទាំង៤នេះ ស្ត្រីត្រូវបានសួរថា តើសកម្មភាពដែលប្រព្រឹត្តដោយដៃគូស្និទ្ធស្នាលបច្ចុប្បន្ន ឬថ្មីបំផុតមកលើស្ត្រីក្នុងជីវិតរបស់គាត់។ គួរកត់សម្គាល់ថា ចំពោះអំពើហិង្សាលើរាងកាយ និងផ្លូវភេទ ស្ត្រីត្រូវបានសាកសួរអំពីសកម្មភាពដែលដៃគូស្និទ្ធស្នាលអតីតបានប្រព្រឹត្តមកលើរូបគាត់។

ដើម្បីអាចប្រៀបធៀបរវាងប្រភេទអំពើហិង្សាទាំងបួន យើងត្រូវធ្វើការប្រៀបធៀបអំពើហិង្សាប្រព្រឹត្តដោយដៃគូស្និទ្ធស្នាលបច្ចុប្បន្ន ឬថ្មីបំផុតក្នុងជីវិត (ព័ត៌មានអំពីអំពើហិង្សាលើផ្លូវចិត្ត និងផ្នែកសេដ្ឋកិច្ចប្រព្រឹត្តដោយដៃគូស្និទ្ធស្នាលអតីតមិនត្រូវបានប្រមូលនោះទេ)។

តារាងលម្អិតស្ដីពីប្រភេទអំពើហិង្សាត្រូវបានបែងចែកតាមលក្ខណៈប្រជាសាស្ត្រ ដែលមានភ្ជាប់ជូនក្នុងតារាងឧបសម្ព័ន្ធ ក១ និងក២។ តារាងក២ ផ្ដល់ទិន្នន័យដែលឆ្លើយតបទៅនឹងសូចនាករទី៥.២.១នៃគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព (SDG ៥.២.១)៖ "*សមាមាត្រស្ត្រីដែលធ្លាប់មានដៃគូ និងក្មេងស្រីអាយុ១៥ឆ្នាំឡើងធ្លាប់ទទួលរងអំពើហិង្សាលើរាងកាយ ផ្លូវភេទ ផ្លូវចិត្តពីដៃគូស្និទ្ធស្នាល*

[21] ៩៨.៥% នៃស្ត្រីធ្លាប់មានដៃគូដែលទើបរៀបការ ឬធ្លាប់រៀបការ។ ១.៥% ធ្លាប់មានដៃគូរស់នៅជាមួយគ្នាដូចប្ដីប្រពន្ធដោយមិនបានរៀបការ។

*បច្ចុប្បន្ន ឬអតីតអំឡុងពេល១២ខែកន្លងមក បែងចែកតាមទម្រង់អំពើហិង្សា និងតាមក្រុមអាយុ*[22]។ ដូចដែលបានបង្ហាញក្នុងប្រអប់២.១ អត្រាប្រេវ៉ាឡង់អំពើហិង្សាក្នុងអំឡុងពេល១២កន្លងមកផ្តល់ព័ត៌មានអំពីសមាមាត្រស្ត្រីធ្លាប់ទទួលរងអំពើហិង្សាពីដៃគូស្និទ្ធស្នាលនាពេលបច្ចុប្បន្ន ខណៈដែលអត្រាប្រេវ៉ាឡង់អំពើហិង្សាក្នុងជីវិតតម្រូវឱ្យយល់អំពីសមាមាត្រស្ត្រីដែលធ្លាប់ទទួលរងអំពើហិង្សាពីដៃគូស្និទ្ធស្នាលនៅពេលណាមួយក្នុងជីវិត។ អត្រាប្រេវ៉ាឡង់អំពើហិង្សាក្នុងជីវិតមានសារៈសំខាន់សម្រាប់ការស្វែងរកការគាំទ្រមតិ និងបង្កើនការយល់ដឹងពីអំពើហិង្សា ចំណែកឯអត្រាប្រេវ៉ាឡង់អំឡុងពេល១២ខែកន្លងមកមានសារៈសំខាន់សម្រាប់វាស់វែងឥទ្ធិពលនៃកិច្ចអន្តរាគមន៍ទប់ស្កាត់អំពើហិង្សាកន្លងមក។

**តារាង ៣.១. សង្ខេបអត្រាប្រេវ៉ាឡង់នៃប្រភេទអំពើហិង្សាក្នុងជីវិត និងអំឡុងពេល១២ខែកន្លងមក (ក្នុងកម្រិតគម្លាតជឿជាក់៩៥%) ក្នុងការអង្កេត អ.ប.ស.ក ឆ្នាំ២០១៤ ដែលប្រព្រឹត្តដោយដៃគូស្និទ្ធស្នាលបច្ចុប្បន្ន ឬថ្មីបំផុតក្នុងចំណោមស្ត្រីធ្លាប់មានដៃគូ (អ.ប.ស.កឆ្នាំ២០១៤)**

| ប្រភេទអំពើហិង្សា | អត្រាប្រេវ៉ាឡង់ % | កម្រិតគម្លាតជឿជាក់ 95% |
|---|---|---|
| លើរាងកាយក្នុងជីវិត | ១៦.២ | ១៤.៦-១៧.៩ |
| លើផ្លូវភេទក្នុងជីវិត | ៥.៥ | ៥.៥-៦.៧ |
| លើផ្លូវចិត្តក្នុងជីវិត | ២៤.៨ | ២២.៨-២៦.៨ |
| លើផ្នែកសេដ្ឋកិច្ចក្នុងជីវិត | ៥.៨ | ៤.៩-៦.៩ |
| លើរាងកាយ និង/ឬផ្លូវភេទក្នុងជីវិត | ១៨.២ | ១៦.៥-២០.១ |
| លើរាងកាយ ផ្លូវភេទ និង/ឬផ្លូវចិត្តក្នុងជីវិត | ២៨.៧ | ២៦.៦-៣០.៨ |
| លើរាងកាយ ផ្លូវភេទ ផ្លូវចិត្ត និង/ឬផ្នែកសេដ្ឋកិច្ចក្នុងជីវិត | ៣០.៨ | ២៨.៧-៣២.៩ |
| លើរាងកាយអំឡុង១២ខែកន្លងមក | ៩.៣ | ៨.១-១០.៧ |
| លើផ្លូវភេទអំឡុង១២ខែកន្លងមក | ៣.៩ | ៣.១-៥.០ |
| លើរាងកាយ ឬផ្លូវភេទអំឡុង១២ខែកន្លងមក | ១០.៩ | ៩.៦-១២.៥ |

**រូបភាពទី ៣.១. សមាមាត្រស្ត្រីធ្លាប់មានដៃគូបានរាយការណ៍អំពើហិង្សាក្នុងជីវិតលើរាងកាយ ផ្លូវភេទ ផ្លូវចិត្ត និង/ឬ[23]ផ្នែកសេដ្ឋកិច្ចពីដៃគូស្និទ្ធស្នាល (អ.ប.ស.ក ឆ្នាំ២០១៤)**

[22]ក្រុមជំនាញការអន្តរទីភ្នាក់ងារលើសូចនាករ SDG ២០១៦ ការចងក្រងទិន្នន័យខ្នាតធំសម្រាប់ពិនិត្យឡើងវិញលើសូចនាករសកលដែលបានស្នើឡើងក្នុងរបៀបវារៈគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពឆ្នាំ២០៣០៖ គោលដៅទី ៥ ការសម្រេចបាននូវសមភាពយេនឌ័រ និងការផ្តល់ភាពអង់អាចដល់ស្ត្រីនិងក្មេងស្រីទំព័រ៤ ពី:http://unstats.un.org/sdgs/files/metadata-compilation/Metadata-Goal-5.pdf ១១ កក្កដា ២០១៦

[23]ពាក្យ"និង/ឬ" ត្រូវបានគេប្រើនៅទូទាំងក្នុងរបាយការណ៍នេះសម្រាប់បកស្រាយពីអ្នកចូលរួមក្នុងអង្កេតទទួលរងប្រភេទអំពើហិង្សាច្រើនជាងមួយ "និង" ឬយ៉ាងហោចណាស់ទទួលរងប្រភេទអំពើហិង្សាមួយ"ឬ"។




ផ្នែកខាងក្រោមនេះនឹងបង្ហាញថាតើប្រភេទអំពើហិង្សាត្រួតស៊ីគ្នា ឬមិនត្រួតស៊ីគ្នា។ ក្នុងចំណោមស្ត្រីធ្លាប់មានដៃគូស្និទ្ធស្នាលដែលទទួលរងអំពើហិង្សាលើរាងកាយ ឬផ្លូវភេទពីដៃគូស្និទ្ធស្នាលមានតែ១១% រាយការណ៍អំពីអំពើហិង្សាលើផ្លូវភេទដែលប្រព្រឹត្តដោយដៃគូស្និទ្ធស្នាល។ ក៏ប៉ុន្តែ ភាគច្រើននៃស្ត្រី (៧៩%) ដែលទទួលរងអំពើហិង្សាលើរាងកាយបានរាយការណ៍អំពីអំពើហិង្សាលើតែផ្លូវកាយពីដៃគូស្និទ្ធស្នាល ។

**រូបភាពទី ៣.២. ភាពត្រួតគ្នានៃអំពើហិង្សាលើរាងកាយ និងផ្លូវភេទក្នុងជីវិតពីដៃគូស្និទ្ធស្នាល បច្ចុប្បន្ន ឬថ្មីបំផុតក្នុងចំណោមស្ត្រីធ្លាប់មានដៃគូ (អ.ប.ស.ក ឆ្នាំ២០១៥)**




**រូបភាពទី ៣.៣. ភាពត្រួតគ្នានៃអំពើហិង្សាលើរាងកាយ ផ្លូវភេទ និងផ្លូវចិត្តក្នុងជីវិតពីដៃគូស្និទ្ធស្នាលបច្ចុប្បន្ន ឬថ្មីបំផុតក្នុងចំណោមស្ត្រីធ្លាប់មានដៃគូ(អ.ប.ស.ក ឆ្នាំ២០១៥)**




ភាគច្រើននៃស្ត្រី (៨៥%) ធ្លាប់ទទួលរងអំពើហិង្សាលើផ្លូវភេទ ក៏ទទួលរងអំពើហិង្សាប្រភេទផ្សេងៗទៀតពីដៃគូស្និទ្ធស្នាល។ ស្ត្រី ៥៨% ធ្លាប់ទទួលរងអំពើហិង្សាលើផ្លូវភេទពីដៃគូស្និទ្ធស្នាល ក៏ទទួលរងអំពើហិង្សាលើរាងកាយ និងផ្លូវភេទពីដៃគូស្និទ្ធស្នាល។ ស្រដៀងគ្នានេះដែរ ស្ត្រី ៨២% ធ្លាប់ទទួលរងអំពើហិង្សាលើរាងកាយ ក៏ទទួលរងអំពើហិង្សាប្រភេទផ្សេងៗទៀតពីដៃគូស្និទ្ធស្នាល ភាគច្រើនគឺអំពើហិង្សាលើរាងកាយ និងផ្លូវចិត្ត ។

## អំពើហិង្សាលើរាងកាយប្រព្រឹត្តដោយដៃគូស្និទ្ធស្នាល

ស្ត្រីធ្លាប់មានដៃគូស្និទ្ធស្នាលបានទទួលរងអំពើហិង្សាលើរាងកាយក្នុងជីវិត និងអំឡុងពេល១២ខែកន្លងមកដែលបែងចែកតាមលក្ខណៈសាវតា បង្ហាញក្នុងឧបសម្ព័ន្ធ "ក" តារាង "ក៥" ។ តារាងនេះបង្ហាញពីអត្រា ប្រេវ៉ាឡង់នៃអំពើហិង្សាបែងចែកតាមក្រុមអាយុ សាសនា លំនៅដ្ឋាន ចំនួនកូនរស់នៅ កម្រិតការសិក្សាអប់រំ និងបញ្ចូភាគទ្រព្យសម្បត្តិ។ តារាងនេះក៏បង្ហាញពីទិន្នន័យ អំពីអំពើហិង្សាដែលប្រព្រឹត្តដោយដៃគូស្និទ្ធស្នាលបច្ចុប្បន្ន ឬ ថ្មីបំផុត (ដើម្បីប្រៀបធៀបជាមួយការអង្កេត **អ.ប.ស.ក**មុនៗ) និងដៃគូផ្សេងទៀត។ ដោយបញ្ចូលអតីតដៃគូស្និទ្ធស្នាល យើងនឹងទទួលបានការប៉ាន់ប្រមាណដែលមានភាពសុក្រិតខ្ពស់អំពីសមាមាត្រស្ត្រីធ្លាប់ទទួលរងអំពើហិង្សាក្នុងជីវិត ជាពិសេសស្ត្រីដែលធ្លាប់មានដៃគូច្រើនក្នុងជីវិត។

ស្ត្រីប្រហែល ១៦.២% ធ្លាប់ទទួលរងអំពើហិង្សាលើរាងកាយពីដៃគូស្និទ្ធស្នាលបច្ចុប្បន្ន ឬថ្មីបំផុត ហើយមានតែ ១៧.៦% រាយការណ៍ថាធ្លាប់បានទទួលរងអំពើហិង្សាលើរាងកាយក្នុងជីវិតពីដៃគូស្និទ្ធស្នាលផ្សេងៗ។

ក្នុងអំឡុងពេល១២ខែកន្លងមក (១២ខែមុនការសម្ភាសន៍) ស្ត្រីចំនួន ៩.៣%បានរាយការណ៍អំពីបទពិសោធន៍ទទួលរងអំពើហិង្សាលើរាងកាយពីដៃគូស្និទ្ធស្នាលបច្ចុប្បន្ន ឬថ្មីបំផុត។ ដោយសារថាមិនមានស្ត្រីរាយការណ៍ថាបានទទួលរងអំពើហិង្សាពីអតីតដៃគូស្និទ្ធស្នាលក្នុងរយៈពេល១២ខែកន្លងមក អត្រាប្រេវ៉ាឡង់គឺដូចគ្នានឹងអំពើហិង្សាប្រព្រឹត្តដោយ"ដៃគូស្និទ្ធស្នាលផ្សេងៗទៀត"។ លទ្ធផលទាំងនេះបង្ហាញថា ដៃគូស្និទ្ធស្នាលបច្ចុប្បន្ន ឬថ្មីបំផុតគឺអ្នកប្រព្រឹត្តអំពើហិង្សាលើរាងកាយក្នុងអំឡុងពេល១២ខែកន្លងមក។

*រូបភាពទី៣.៤.* បង្ហាញពីអត្រាប្រេវ៉ាឡង់នៃអំពើហិង្សាក្នុងជីវិត និងអំឡុងពេល១២ខែកន្លងមកដែលប្រព្រឹត្តដោយទាំងដៃគូស្និទ្ធស្នាលបច្ចុប្បន្ន ឬថ្មីបំផុត និងដៃគូផ្សេងទៀត បែងចែកតាមក្រុមអាយុ។

ដូចបង្ហាញក្នុង *រូបភាព៣.៤* អត្រាប្រេវ៉ាឡង់នៃអំពើហិង្សាលើរាងកាយក្នុងជីវិត ដែលប្រព្រឹត្តដោយដៃគូស្និទ្ធស្នាល (ដៃគូស្និទ្ធស្នាលបច្ចុប្បន្ន និងដៃគូផ្សេងទៀត)បានកើនឡើងតាមកំណើននៃអាយុរបស់ស្ត្រី។ នេះគឺអាស្រ័យដោយហេតុថា ស្ត្រីដែលមានអាយុច្រើនបានចំណាយពេលរស់នៅជាមួយដៃគូស្និទ្ធស្នាលរយៈពេលវែង ដែលជាកត្តានាំឱ្យអត្រា "អំពើហិង្សាក្នុងជីវិត)កើនឡើងក្នុងឆ្នាំកន្លងមក។ ការប្រៀបធៀបរវាងអំពើហិង្សាប្រព្រឹត្តដោយដៃគូស្និទ្ធស្នាលបច្ចុប្បន្ន ឬថ្មីបំផុត និងអំពើហិង្សាប្រព្រឹត្តដោយដៃគូផ្សេងៗទៀតបង្ហាញឱ្យឃើញថា ស្ត្រីដែលមានអាយុច្រើនបានរាយការណ៍ថា ធ្លាប់ទទួលរងអំពើហិង្សាពីអតីតដៃគូស្និទ្ធស្នាល តាមរយៈការបង្ហាញភាពខុសគ្នារវាងពេលវេលាពីរផ្សេងគ្នានៅក្នុងរូបភាពខាងក្រោម។

មិនមានភាពខុសគ្នារវាងអំពើហិង្សាលើរាងកាយដែលបង្កឡើងដោយ"ដៃគូស្និទ្ធស្នាលបច្ចុប្បន្ន ឬថ្មីបំផុត " និង" ដៃគូផ្សេងទៀត "ក្នុងអំឡុងពេល១២ខែកន្លងមកទេ ដោយសារមិនមានការរាយការណ៍អំពើហិង្សាបង្កឡើងដោយអតីតដៃគូស្និទ្ធស្នាលក្នុងអំឡុងពេល១២ខែកន្លងមក។ សូមបញ្ជាក់ថា អំពើហិង្សានាពេលបច្ចុប្បន្ន "ជាទូទៅត្រូវបានរាប់បញ្ចូលជាផ្នែកមួយនៃអំពើហិង្សាក្នុងជីវិត" ។ នៅក្នុងក្រុមអាយុវ័យក្មេង អត្រាប្រេវ៉ាឡង់ក្នុងអំឡុងពេល១២ខែកន្លងមក ស្ទើរតែដូចគ្នានឹងអត្រាអំពើហិង្សាក្នុងជីវិត ដែលបង្ហាញថាអំពើហិង្សាបានចាប់ផ្តើមដំបូងនៅក្នុងទំនាក់ទំនង "វ័យក្មេង" ។ អំពើហិង្សាលើរាងកាយ ដែលភាគច្រើនបង្កឡើងដោយដៃគូស្និទ្ធស្នាល មិនបានបន្តកើតឡើងទេ ដូចបង្ហាញក្នុង សមាមាត្របច្ចុប្បន្ន (ក្នុងអំឡុងពេល១២ខែកន្លងមក) ដែលជាផ្នែកមួយនៃអំពើហិង្សាក្នុងជីវិតបាន ថយចុះទៅតាមក្រុមអាយុ (៨៧% នៅក្នុងក្រុមអាយុ១៥-១៩ឆ្នាំ ទៅ៤៥% ក្រុមអាយុ ៤៥-៤៩ឆ្នាំ) ។ សមាមាត្រនៃស្ត្រីរស់នៅទទួលរងអំពើហិង្សាលើរាងកាយបង្កឡើងដោយដៃគូស្និទ្ធស្នាលនាពេល

បច្ចុប្បន្ននេះនៅទ្រឹងដដែលក្នុងក្រុមអាយុ ៣០-៤៩ ឆ្នាំ ដែលនេះបង្ហាញថាអំពើហិង្សាលើរាងកាយបង្កឡើងដោយដៃគូស្និទ្ធស្នាលនៅប្រទេសកម្ពុជា មិនត្រឹមតែកើតឡើងចំពោះក្រុមវ័យក្មេងប៉ុណ្ណោះទេ ប៉ុន្តែស្ត្រីម្នាក់ក្នុងចំណោម១០នាក់ ក្នុងក្រុមអាយុណាមួយកំពុងរស់ជាមួយអំពើហិង្សាលើរាងកាយបង្កឡើងដោយដៃគូស្និទ្ធស្នាលនាពេលបច្ចុប្បន្ននេះ។

**រូបភាពទី ៣.៤. ប្រេវ៉ាឡង់នៃអំពើហិង្សាលើរាងកាយក្នុងអំឡុងពេល១២ខែកន្លងមក និងក្នុងជីវិតពីគូស្និទ្ធស្នាលក្នុងចំណោមស្ត្រីធ្លាប់មានដៃគូបែងចែកតាមក្រុមអាយុ (អ.ប.ស.កឆ្នាំ២០១៤)**




ការរកឃើញផ្សេងទៀតដែលបង្ហាញក្នុងតារាង“ក៤” បានរៀបរាប់ពីភាពខុសគ្នានៃអំពើហិង្សាទៅតាមតំបន់នីមួយៗ។ អត្រាប្រេវ៉ាឡង់នៃអំពើហិង្សាលើរាងកាយក្នុងជីវិតដែលបង្កឡើងដោយដៃគូស្និទ្ធស្នាល មានគម្លាតពី ១៦.៥% (តំបន់វាលទំនាប) ទៅ ២២.២% (នៅតំបន់ឆ្នេរ)។ អ្វីដែលគួរឱ្យកត់សម្គាល់នោះគឺអត្រាប្រេវ៉ាឡង់អំពើហិង្សាក្នុងអំឡុងពេល១២ខែកន្លងមក មានកម្រិតទាបជាងតំបន់ផ្សេងទៀត ទោះបីជាអត្រាប្រេវ៉ាឡង់អំពើហិង្សាក្នុងជីវិតមានកម្រិតខ្ពស់នៅតំបន់ឆ្នេរ។ បំណែងចែកអំពើហិង្សាទៅតាមស្ថានភាពគ្រួសារបង្ហាញថា អត្រាប្រេវ៉ាឡង់អំពើហិង្សាមានអត្រាខ្ពស់ ជាពិសេសក្នុងចំណោមស្ត្រីលែងលះ/រស់នៅបែកគ្នា (៣៦.៦%) ដែលអាចសន្និដ្ឋានបានថា ស្ត្រីដែលលែងលះ ឬរស់នៅបែកគ្នាហ៊ានរាយការណ៍ពីបទពិសោធន៍ទទួលរងអំពើហិង្សា ដែលជាមូលហេតុនៃការបែកបាក់គ្នាពីដៃគូស្និទ្ធស្នាល ឬស្ត្រីទាំងនោះមានសេរីភាពក្នុងការនិយាយអំពីប្ដី ដែលលែងរស់នៅជាមួយគ្នាហើយ ឬក៏ហេតុផលទាំងពីរខាងលើ។

សមាមាត្រស្ត្រីដែលរាយការណ៍ថា ធ្លាប់ទទួលរងអំពើហិង្សាលើរាងកាយ ដែលបង្កឡើងដោយដៃគូស្និទ្ធស្នាលបានធ្លាក់ចុះតាមកំណើនកម្រិតសិក្សាអប់រំ និងទ្រព្យសម្បត្តិ ប៉ុន្តែសមាមាត្រនេះបានកើនឡើងតាមកំណើននៃចំនួនកូន។

អំពើហិង្សាលើរាងកាយដែលបង្កឡើងដោយដៃគូស្និទ្ធស្នាល ត្រូវបានវាស់វែងដោយសួរ

សំណួរអំពីសកម្មភាពឥរិយាបថបុគ្គលម្នាក់ៗ (តារាង "ក៧")។ ភាពញឹកញាប់នៃអំពើហិង្សាលើរាងកាយដូចជា ទះកំផ្លៀងដែលបង្កឡើងដោយដៃគូស្និទ្ធស្នាលបច្ចុប្បន្ន ឬថ្មីបំផុតមាន (១១.៩%ក្នុងជីវិត និង៦.៥%ក្នុងអំឡុង១២ខែកន្លងមក)។ តារាងនេះបានផ្តល់ព័ត៌មានស្តីពីភាពញឹកញាប់ (ញឹកញាប់ ឬម្តងម្កាល)សម្រាប់ប្រភេទអំពើហិង្សានីមួយៗ។ សម្រាប់ប្រភេទអំពើហិង្សាលើរាងកាយ ប្រហែលមួយភាគបីនៃស្ត្រីបានរាយការណ៍ថាបានកើតឡើងញឹកញាប់ ។

**រូបភាពទី ៣.៥. សកម្មភាពជាក់លាក់នៃអំពើហិង្សាលើរាងកាយក្នុងជីវិតពីដៃគូស្និទ្ធស្នាលក្នុងចំណោមស្ត្រីធ្លាប់មានដៃគូ (អ.ប.ស.ក ឆ្នាំ២០១៤)**




## អំពើហិង្សាលើផ្លូវភេទប្រព្រឹត្តដោយដៃគូស្និទ្ធស្នាល

បទពិសោធន៍អំពើហិង្សាលើផ្លូវភេទពីដៃគូស្និទ្ធស្នាលក្នុងជីវិត និងអំឡុងពេល១២ខែកន្លងមកក្នុងចំណោមស្ត្រីធ្លាប់មានដៃគូបង្ហាញក្នុងតារាងឧបសម្ព័ន្ធ "ក" តារាង "ក៥" បែងចែកតាមលក្ខណៈសាវតាដូចមានក្នុងតារាង "ក៤"។

ក្នុងចំណោមស្ត្រីធ្លាប់មានដៃគូក្នុងសំណាកគំរូនៃការអង្កេតផ្នែកអំពើហិង្សាក្នុងគ្រួសារ ស្ត្រី៥.៥% បានរាយការណ៍ថាធ្លាប់ទទួលរងអំពើហិង្សាលើផ្លូវភេទក្នុងជីវិតដែលបង្កឡើងដោយដៃគូស្និទ្ធស្នាលបច្ចុប្បន្ន ឬថ្មីបំផុត ហើយស្ត្រី (៥.៩%) បានរាយការណ៍ថាធ្លាប់ទទួលរងអំពើហិង្សាលើផ្លូវភេទក្នុងជីវិតដែលបង្កឡើង ដោយដៃគូស្និទ្ធស្នាលផ្សេងទៀត។

ក្នុងចំណោមស្ត្រីធ្លាប់មានដៃគូក្នុងសំណាកគំរូនៃការអង្កេតផ្នែកអំពើហិង្សាក្នុងគ្រួសារ ស្ត្រី៣.៩%បានរាយការណ៍ថាធ្លាប់ទទួលរងអំពើហិង្សាលើផ្លូវភេទអំឡុងពេល១២ខែកន្លងមកដែលបង្កឡើងដោយដៃគូស្និទ្ធស្នាលបច្ចុប្បន្ន ឬថ្មីបំផុត ឬដៃគូស្និទ្ធស្នាលផ្សេងទៀត។ ដូចគ្នានឹងអំពើហិង្សាលើផ្លូវកាយក្នុងអំឡុងពេល១២ខែកន្លងមក អំពើហិង្សាលើផ្លូវភេទអំឡុងពេល១២ខែកន្លងមកគឺ

ប្រព្រឹត្តដោយតែដៃគូស្និទ្ធស្នាលបច្ចុប្បន្ន ឬថ្មីបំផុតប៉ុណ្ណោះ (គ្មានអំពើហិង្សាបង្កឡើងដោយអតីតដៃគូស្និទ្ធស្នាលក្នុងអំឡុងពេល១២ខែកន្លងមកបានរាយការណ៍)។

ដូចគ្នានឹងអំពើហិង្សាលើរាងកាយដែលបង្កឡើងដោយដៃគូស្និទ្ធស្នាល អត្រាប្រេវ៉ាឡង់អំពើហិង្សាលើផ្លូវភេទបែងចែកតាមក្រុមអាយុកើនឡើងតាមកំណើននៃក្រុមអាយុ និងអត្រាប្រេវ៉ាឡង់អំពើហិង្សាលើផ្លូវភេទបង្កឡើងពីអតីតដៃគូស្និទ្ធស្នាល មានការកើនឡើងផងដែរ (ពិសេសស្ត្រីដែលមានអាយុច្រើនបានរាយការណ៍ថាធ្លាប់ទទួលរងអំពើហិង្សាលើផ្លូវភេទពីអតីតដៃគូស្និទ្ធស្នាល ដូចបង្ហាញក្នុងរូបភាពទី៣.៦)។ ចំពោះអំពើហិង្សាលើផ្លូវភេទក្នុងអំឡុងពេល១២ខែកន្លងមក ទោះបីអត្រាប្រេវ៉ាឡង់មិនមានកម្រិតខ្ពស់ក៏ដោយ ក៏ប៉ុន្តែអត្រាអំពើហិង្សាលើផ្លូវភេទសម្រាប់ក្រុមអាយុនីមួយៗគឺប្រមាណ ៤-៥% រួមទាំងក្រុមអាយុវ័យចំណាស់។អត្រាប្រេវ៉ាឡង់អំពើហិង្សាផ្លូវភេទសម្រាប់ក្រុមអាយុ ១៥-១៩ ឆ្នាំក្នុងអំឡុងពេល១២ខែកន្លងមកមានកម្រិតទាប (ប្រហែល ២%)។

**រូបភាពទី ៣.៦. ប្រេវ៉ាឡង់អំពើហិង្សាលើផ្លូវភេទក្នុងអំឡុងពេល១២ខែកន្លងមក និងក្នុងជីវិតពីដៃគូស្និទ្ធស្នាលក្នុងចំណោមស្ត្រីអត្រាធ្លាប់មានដៃគូបែងចែកតាមក្រុមអាយុ (អ.ប.ស.ក ឆ្នាំ២០១៤)**




ដូចគ្នានឹងអំពើហិង្សាលើរាងកាយ សមាមាត្រស្ត្រីបានរាយការណ៍ពីបទពិសោធន៍ទទួលរងអំពើហិង្សាលើផ្លូវភេទពីដៃគូណាមួយមានភាពខុសគ្នាខ្លាំងពីតំបន់មួយទៅតំបន់មួយទៀតគឺពី ៥.៩% (តំបន់វាលទំនាប) ទៅ២.៦% (តំបន់ឆ្នេរ)។ ស្ត្រីលែងលះ ឬរស់នៅបែកគ្នាហ៊ានរាយការណ៍អំពើហិង្សានេះ (១៦.៣%) ប្រហែលជាដោយសារអំពើហិង្សាអាចជាមូលហេតុបណ្តាលឱ្យមានការលែងលះ ឬរស់នៅបែក ឬប្រហែលជាស្ត្រីមានភាពងាយស្រួលក្នុងនិយាយអំពីដៃគូដែលលែងរស់នៅជាមួយគ្នាហើយ។

ដូចគ្នានឹងអំពើហិង្សាលើរាងកាយ សមាមាត្រស្ត្រីបានរាយការណ៍ពីបទពិសោធន៍ទទួលរងអំពើហិង្សាលើផ្លូវភេទពីដៃគូស្និទ្ធស្នាលបានកើនឡើងជាមួយនឹងកំណើននៃចំនួនកូនដែលរស់នៅ និងបានថយចុះតាមកំណើននៃកម្រិតសិក្សាអប់រំ និងស្ថានភាពបញ្ចូភាគទ្រព្យសម្បត្តិ។

ក្នុងចំណោមសកម្មភាពទាំង៣នៃអំពើហិង្សាលើផ្លូវភេទដែលបានសួរ សកម្មភាពដែលដៃគូស្និទ្ធស្នាលតែងតែប្រើគឺការប្រើកម្លាំងបង្ខំឱ្យស្ត្រីរួមភេទនៅពេលដែលគាត់មិនចង់ (៤.៦%ក្នុងជីវិត និង៣.៣%អំឡុងពេល១២ខែកន្លងមក តាមតារាង"ក៧")។ សកម្មភាពជាក់លាក់នៃអំពើហិង្សាលើផ្លូវភេទពីដៃគូស្និទ្ធស្នាលក្នុងជីវិតនឹងបង្ហាញក្នុងរូបភាពទី ៣.៧ ។

**រូបភាពទី៣.៧. សកម្មភាពជាក់លាក់នៃអំពើហិង្សាលើផ្លូវភេទក្នុងជីវិតពីដៃគូស្និទ្ធស្នាលក្នុងចំណោមស្ត្រីធ្លាប់មានដៃគូ (អ.ប.ស.កឆ្នាំ២០១៤)**




## អំពើហិង្សាលើផ្លូវចិត្ត ផ្នែកសេដ្ឋកិច្ច និងការត្រួតត្រាឥរិយាបថ

តារាង "ក៦" ផ្តល់ព័ត៌មានលម្អិតអំពីលក្ខណៈសាវតានៃស្ត្រីធ្លាប់មានដៃគូដែលទទួលរងការរំលោភបំពានលើផ្លូវចិត្ត ឬផ្នែកសេដ្ឋកិច្ច ដោយដៃគូស្និទ្ធស្នាលបច្ចុប្បន្ន ឬថ្មីបំផុត។ ស្ត្រីប្រហែលមួយភាគបួន (២៤.៨%) បានរាយការណ៍ថាធ្លាប់ទទួលរងអំពើហិង្សាផ្លូវចិត្តក្នុងជីវិត និងប្រហែល ១៧.៣%ទទួលរងអំពើហិង្សាផ្លូវចិត្តអំឡុងពេល១២ខែកន្លងមក។ អត្រានេះមានការប្រែប្រួលគួរឱ្យកត់សម្គាល់តាមតំបន់ ដែលផ្ទុយពីអំពើហិង្សាលើរាងកាយ និងផ្លូវភេទលើដៃគូស្និទ្ធស្នាលដែលបានរាយការណ៍។ ស្ត្រីនៅតំបន់វាលទំនាបបានរាយការណ៍ថាទទួលរងអំពើហិង្សាលើផ្លូវភេទមានកម្រិតខ្ពស់បំផុតក្នុងជីវិតពីដៃគូស្និទ្ធស្នាល ក៏ប៉ុន្តែការរាយការណ៍អំពីអំពើហិង្សាលើផ្លូវចិត្តក្នុងជីវិតមានកម្រិតទាបបំផុត (២២.៩%)។ ដោយឡែកនៅតំបន់ឆ្នេរ ស្ត្រីបានរាយការណ៍អំពីបទពិសោធន៍រងអំពើហិង្សាលើផ្លូវភេទពីដៃគូស្និទ្ធស្នាលមានអត្រាទាបបំផុត ក៏ប៉ុន្តែការរាយការណ៍អំពីអំពើហិង្សាលើផ្លូវចិត្តមានអត្រាខ្ពស់បំផុត(២៧.៥%)។

ស្ត្រីមានដៃគូស្និទ្ធស្នាលបានរាយការណ៍ថាទទួលរងអំពើហិង្សាផ្នែកសេដ្ឋកិច្ចតែ៥.៨% ប៉ុណ្ណោះ ទោះបីជាអត្រានេះមានកម្រិតខ្ពស់ (២២.៧%) ចំពោះស្ត្រីលែងលះ ឬរស់នៅបំបែកគ្នាក៏ដោយ។

សមាមាត្រស្ត្រីដែលបានឆ្លើយថា "ចាស៎" ចំពោះសកម្មភាពជាក់លាក់នៃអំពើហិង្សាលើផ្លូវចិត្ត និងផ្នែកសេដ្ឋកិច្ចក្នុងមួយជីវិតដូចបានបង្ហាញក្នុងរូបភាពទី៣.៨។ សកម្មភាពដែលបានរាយការណ៍ញឹកញាប់ច្រើនជាងគេគឺ ស្ត្រីទទួលរងការប្រមាថមើលងាយ ឬការធ្វើឱ្យស្ត្រីមានអារម្មណ៍មិនល្អចំពោះខ្លួនឯង។ សកម្មភាពនៃអំពើហិង្សាផ្នែកសេដ្ឋកិច្ចដែលវាស់វែងតាមវិធីសាស្ត្រទាំងពីរបែបបានបង្ហាញថាមានសមាមាត្រស្មើគ្នានឹងស្ត្រីមានដៃគូក្នុងសំណាកគំរូនៃការអង្កេតផ្នែកអំពើហិង្សាក្នុងគ្រួសារ(ប្រហែល៥%)។

**រូបភាពទី ៣.៨. សកម្មភាពជាក់លាក់នៃអំពើហិង្សាលើផ្លូវចិត្ត និងផ្នែកសេដ្ឋកិច្ចក្នុងជីវិតពីដៃគូស្និទ្ធស្នាលក្នុងចំណោមស្ត្រីធ្លាប់មានដៃគូ (អ.ប.ស.ក ឆ្នាំ២០១៨)**




ឥរិយាបថត្រួតត្រារបស់ដៃគូស្និទ្ធស្នាលបានកើតឡើងដដែលៗជាញឹកញាប់ក្នុងពេលវេលាកន្លងមក ដូចជា ការប្រើអំណាច និងការត្រួតត្រា ការបង្ខំឱ្យនៅតែឯង និងឥរិយាបថប្រច័ណ្ឌ។ មិនមានការយល់ស្របជារួមមួយថា ឥរិយាបថត្រួតត្រាជាផ្នែកមួយនៃការបន្តកើតឡើងនូវការរំលោភបំពានលើផ្លូវចិត្តនោះទេ បើទោះបីជា ក្រុមអ្នកស្រាវជ្រាវជាច្រើនចាត់ទុកថាដូច្នេះក៏ដោយ។ អ្នកស្រាវជ្រាវជាច្រើនទៀតបានចាត់ទុកថាឥរិយាបថត្រួតត្រាជាកត្តាហានិភ័យមួយចំពោះអំពើហិង្សាលើដៃគូស្និទ្ធស្នាល។ ទោះក្នុងករណីណាក៏ដោយ ឥរិយាបថត្រួតត្រាមានទំនាក់ទំនងយ៉ាងជិតស្និទ្ធទៅនឹងប្រភេទនៃអំពើហិង្សាផ្សេងទៀតដែលប្រព្រឹត្តដោយដៃគូស្និទ្ធស្នាល។ ឧបសម្ព័ន្ធ"ក" តារាង "ក៨" បង្ហាញលម្អិតពីឥរិយាបថត្រួតត្រាដែលបានប្រព្រឹត្តដោយដៃគូស្និទ្ធស្នាលបច្ចុប្បន្ន ឬថ្មីបំផុត។ ជាថ្មីម្តងទៀត ស្ត្រីដែលលែងលះ ឬរស់នៅបែកគ្នាហ៊ានរាយការណ៍ (២២.៣%)អំពីបទពិសោធន៍ទទួលរងឥរិយាបថត្រួតត្រាចំនួនបីដង និងច្រើនជាងនេះពីដៃគូស្និទ្ធស្នាលថ្មីបំផុត ច្រើនជាងស្ត្រីដែលរស់នៅជាមួយប្តី/ដៃគូ (៦.១%)។ ចំណុចមួយទៀតដែលគួរឱ្យកត់សម្គាល់ខ្លាំងគឺថាស្ត្រីដែលធ្លាប់មានភាពភ័យខ្លាចចំពោះដៃគូស្និទ្ធស្នាលស្ទើរតែគ្រប់ពេលបានរាយការណ៍ថាងាយទទួលរង

ឥរិយាបថត្រួតត្រាចំនួនបីដង ឬច្រើនជាងនេះពីដៃគូស្និទ្ធស្នាលបច្ចុប្បន្ន ឬថ្មីបំផុត(៣១.៩%) ច្រើនជាងស្ត្រីដែលរាយការណ៍ថាពួកគេមិនមានភាពភ័យខ្លាចចំពោះដៃគូស្និទ្ធស្នាលរបស់ពួកគេឡើយ (៥.៣%)។ ដូចគ្នានឹងស្ត្រីធ្លាប់រងអំពើហិង្សាលើផ្លូវចិត្ត ស្ត្រីដែលបានរាយការណ៍ថាធ្លាប់ទទួលរងឥរិយាបថត្រួតត្រាបីដង ឬច្រើនជាងនេះពីដៃគូស្និទ្ធស្នាលបច្ចុប្បន្ន ឬថ្មីបំផុតនៅតំបន់ឆ្នេរមានសមាមាត្រខ្ពស់(១៤.១%) ប៉ុន្តែសមាមាត្រនេះមានកម្រិតទាបនៅតំបន់វាលទំនាប(៥.៤%)។

ដូចបានបង្ហាញក្នុងរូបភាពទី៣.៩ ស្ត្រីដែលបានលែងលះ ឬរស់នៅបែកគ្នាទទួលរងឥរិយាបថត្រួតត្រាខ្ពស់ជាងស្ត្រីដែលបានរៀបការ ឬរស់នៅជាមួយប្តី/ដៃគូ។

**រូបភាពទី ៣.៩. សមាមាត្រស្ត្រីធ្លាប់ទទួលឥរិយាបថត្រួតត្រាជាក់លាក់ពីដៃគូស្និទ្ធស្នាលបច្ចុប្បន្ន ឬថ្មីបំផុត បែងចែកតាមស្ថានភាពអាពាហ៍ពិពាហ៍ក្នុងចំណោមស្ត្រីធ្លាប់មានដៃគូ(អ.ប.ស.កឆ្នាំ២០១៥)**




## កត្តាចម្បងៗពាក់ព័ន្ធនឹងការកើតឡើងនៃអំពើហិង្សាលើដៃគូស្និទ្ធស្នាល

អង្កេតនេះបានផ្តល់ព័ត៌មានលម្អិតមួយចំនួនពីដៃគូស្និទ្ធស្នាល ដូចជាទំនាក់ទំនងរវាងការអប់រំនិងការប្រើប្រាស់គ្រឿងស្រវឹង ទំនាក់ទំនងរវាងការអប់រំ និងក្រុមអាយុផ្សេងគ្នា ការប្រើឥរិយាបថត្រួតត្រា អំណាចធ្វើសេចក្តីសម្រេចរបស់ស្ត្រី ឥរិយាបថរបស់ស្ត្រីក្នុងការយល់ស្របចំពោះការវាយប្រពន្ធ ធ្លាប់ឃើញឪពុកវាយដំម្តាយ និងភាពភ័យខ្លាចចំពោះដៃគូស្និទ្ធស្នាល។

ការបកស្រាយលម្អិតពីប្រភេទអំពើហិង្សាផ្សេងៗគ្នា និងការរួមបញ្ចូលអំពើហិង្សាលើដៃគូស្និទ្ធស្នាលជាមួយនឹងកត្តាហានិភ័យ ឬកត្តាគាំពារនឹងបង្ហាញនៅក្នុងតារាង"ក៩"។ លទ្ធផលនេះមានភាពដូចគ្នាទៅនឹងការរកឃើញនៅបណ្តាប្រទេសផ្សេងទៀតដែរ ស្ត្រីធ្លាប់មានដៃគូដែលស្រវឹងរាល់ថ្ងៃ (៦០%) ឬដៃគូបានប្រើប្រាស់ឥរិយាបថត្រួតត្រាច្រើន (៨៦,៨%)ដែលបានរាយការណ៍អំពីបទពិសោធន៍ទទួលរងអំពើហិង្សាលើផ្លូវកាយ ផ្លូវភេទ ឬផ្លូវចិត្តមានភាគរយខ្ពស់។

ស្ត្រីដែលមានភាពភ័យខ្លាចចំពោះប្តី ឬដៃគូ ហើយទទួលរងអំពើហិង្សាលើរាងកាយ ផ្លូវភេទ ឬផ្លូវចិត្តពីដៃគូស្និទ្ធស្នាលមានភាគរយខ្ពស់ផងដែរ(៨៥.០%) ។

ស្ត្រីដែលមានដៃគូមិនទទួលបានការអប់រំ ឬទទួលបានការអប់រំ ឬធ្លាប់ឃើញឪពុកវាយដំម្តាយងាយទទួលរងអំពើហិង្សាលើរាងកាយ ផ្លូវភេទ ឬផ្លូវចិត្ត ជាងស្ត្រីទទួលការអប់រំ ឬមិនធ្លាប់ឃើញឪពុកវាយដំម្តាយ។

**រូបភាពទី៣.១០. សមាមាត្រស្ត្រីធ្លាប់មានដៃគូរាយការណ៍អំពីអំពើហិង្សាលើរាងកាយ ផ្លូវភេទ ឬផ្លូវចិត្តពីដៃគូស្និទ្ធស្នាលបច្ចុប្បន្ន ឬថ្មីបំផុត បែងចែកតាមកត្តាហានិភ័យ (អ.ប.ស.ក ឆ្នាំ២០១៤)**




## ការរងរបួសស្នាមបង្កពីអំពើហិង្សាលើរាងកាយ ឬផ្លូវភេទដែលប្រព្រឹត្តដោយដៃគូបច្ចុប្បន្ន ឬថ្មីបំផុត

ការរងរបួសស្នាមត្រូវបានធ្វើការវិភាគព្រោះការរងរបួសស្នាមជាចំណុចមួយដ៏សំខាន់បង្ហាញពីភាពធ្ងន់ធ្ងរនៃអំពើហិង្សា។ តារាង ៣.២ ផ្តល់ការបកស្រាយលើសមាមាត្រស្ត្រីធ្លាប់ទទួលរងអំពើហិង្សាលើរាងកាយ ផ្លូវភេទ ឬផ្លូវចិត្តពីដៃគូស្និទ្ធស្នាលដែលបានរាយការណ៍ថាធ្លាប់រងរបួសស្នាមដោយសារអំពើហិង្សា។ អំពើហិង្សាដែលបង្កឱ្យមានរបួសស្នាមនេះនឹងបង្ហាញតាមប្រភេទនៃអំពើហិង្សានីមួយៗ និងបញ្ចូលរួមគ្នានូវប្រភេទអំពើហិង្សាចំនួនពីរ។ មានតែ ១១% នៃស្ត្រីធ្លាប់មានដៃគូដែលទទួលរងអំពើហិង្សាលើរាងកាយ ឬផ្លូវភេទពីដៃគូស្និទ្ធស្នាល បានរាយការណ៍ថាគាត់ធ្លាប់ទទួលរងអំពើហិង្សាតែលើផ្លូវភេទ(សូមមើលផ្នែក"ទិដ្ឋភាពទូទៅនៃអំពើហិង្សា"ខាងលើ)។ លទ្ធផលនេះបង្ហាញពីភាពលំបាកក្នុងការញែកភាពរងរបួសស្នាមដែលបង្កឡើងដោយអំពើហិង្សាផ្លូវភេទចេញពីការរបួសស្នាមបង្កឡើងដោយអំពើហិង្សាលើរាងកាយ ។ ទោះជាយ៉ាងណាក៏ដោយ អត្រានៃការរងរបួសស្នាមសម្រាប់អំពើហិង្សាទាំងពីរប្រភេទនេះ (មានភាពត្រួតស៊ីគ្នា) គឺស្ទើរតែដូចគ្នា

ហើយអំពើហិង្សាលើរាងកាយគ្របដណ្តប់លើអំពើហិង្សាទាំងអស់ ដែលអាចសន្និដ្ឋានបានថាការរងរបួសស្នាមគឺបណ្តាលមកពីអំពើហិង្សាលើរាងកាយ។

គួរកត់សម្គាល់ថាយោងតាមទម្រង់សំណួរនៃអ.ប.ស.ក (មើលឧបសម្ព័ន្ធ "គ") ស្ត្រីទទួលរងអំពើហិង្សាដែលស្ថិតក្នុងអំឡុងពេលមានផ្ទៃពោះមិនត្រូវបានសួរឡើយ ប្រសិនបើរបួសស្នាមនៃអំពើហិង្សានេះកើតឡើងក្នុងអំឡុងពេលមានផ្ទៃពោះ។ សំណួរទាក់ទងអំពើហិង្សាអំឡុងពេលមានផ្ទៃពោះត្រូវបានសួរទៅស្ត្រីទាំងអស់ដែលចូលរួមក្នុងការអង្កេតផ្នែកអំពើហិង្សាក្នុងគ្រួសារ ដោយមិនគិតថាពួកគេធ្លាប់មាន ឬមិនធ្លាប់មានដៃគូ។ ក៏ប៉ុន្តែការរងរបួសស្នាមគឺសួរតែស្ត្រីដែលធ្លាប់ទទួលរងអំពើហិង្សាពីដៃគូស្និទ្ធស្នាលមិនស្ថិតក្នុងអំឡុងពេលមានផ្ទៃពោះប៉ុណ្ណោះ។

ស្ត្រីប្រហែលជា ៥០% ដែលធ្លាប់ទទួលរងអំពើហិង្សាលើរាងកាយពីដៃគូស្និទ្ធស្នាលបានរាយការណ៍ពីរបួសស្នាមមួយចំនួនដែលបណ្តាលមកពីអំពើហិង្សានេះ។ ស្ត្រីម្នាក់ក្នុងចំណោម១០នាក់បានរងរបួសស្នាមដែលចាត់ទុកថា"ធ្ងន់ធ្ងរ" រួមមានរបួសមុតជ្រៅ បាក់ឆ្អឹង ឬបាក់ធ្មេញជាដើម។

**តារាង ៣.២ ការរងរបួសស្នាមលើរាងកាយបង្កឡើងពីអំពើហិង្សាលើរាងកាយ ឬផ្លូវភេទក្នុងជីវិតដែលប្រព្រឹត្តដោយដៃគូស្និទ្ធស្នាលបច្ចុប្បន្ន ឬថ្មីបំផុតក្នុងចំណោមស្ត្រីធ្លាប់មានដៃគូ ហើយរាយការណ៍អំពីបទពិសោធន៍ទទួលរងអំពើហិង្សាលើរាងកាយ ឬផ្លូវភេទ (អ.ប.ស.ក ឆ្នាំ២០១៤)**

| ប្រភេទអំពើហិង្សា | ស្នាមកាប់ ស្នាមជាំ ឬរលាក ដែលបង្កឱ្យឈឺចាប់ | ការរងរបួសភ្នែក គ្រេច រលាត់ ផ្លោះ ភ្លាត់ ឬការរលាក | របួសយ៉ាងជ្រៅ បាក់ឆ្អឹង បាក់ធ្មេញឬ របួសធ្ងន់ធ្ងរផ្សេងទៀត | ផ្នែកណាមួយនៃការរងរបួសទាំងនេះ | ចំនួនស្ត្រីដែលបានរៀបការរួចដែលធ្លាប់ជួបអំពើហិង្សាលើរាងកាយ ឬផ្លូវភេទ |
|---|---|---|---|---|---|
| **រងអំពើហិង្សាលើរាងកាយ[1]** | ៤៥.២ | ២២.២ | ៨.៦ | ៤៩.០ | ៥៨១ |
| **រងអំពើហិង្សាលើផ្លូវភេទ** | ៤៧.៩ | ២៥.៥ | ២.៧ | ៥០.៨ | ១៧៨ |
| **រងអំពើហិង្សាលើរាងកាយ ឬផ្លូវភេទ[1]** | ៤៤.៤ | ២១.៨ | ៨.៥ | ៤៨.១ | ៥៩២ |

[1]រាប់បញ្ចូលស្ត្រីដែលរងអំពើហិង្សាតែប៉ុណ្ណោះនៅក្នុងការឆ្លើយតបទៅនឹងសំណួរដោយផ្ទាល់នៅលើអំពើហិង្សាអំឡុងពេលមានផ្ទៃពោះ

**សម្គាល់**: តារាងនេះត្រូវគ្នានឹងតារាង២០.១៤ នៅក្នុងរបាយការណ៍អង្កេតប្រជាសាស្ត្រ និងសុខភាពកម្ពុជាឆ្នាំ២០១៤

## អំពើហិង្សាអំឡុងពេលមានផ្ទៃពោះ

អំពើហិង្សាក្នុងអំឡុងពេលមានផ្ទៃពោះគឺជាធាតុមួយផ្សេងទៀតដែលឆ្លុះបញ្ចាំងពីភាពធ្ងន់ធ្ងរនៃអំពើហិង្សា។ អំពើហិង្សាបែបនេះត្រូវបានបកស្រាយថា"អំពើហិង្សាដោយចេតនាទ្វេរដង" ដែលជនប្រព្រឹត្តមានចេតនាធ្វើឱ្យស្ត្រី និងទារកក្នុងផ្ទៃទទួលរងការឈឺចាប់[24]។ ដូចដែលបានបញ្ជាក់ខាងលើ គ្រប់ស្ត្រីទាំងអស់ដែលបានចូលរួមក្នុងអង្កេត**អ.ប.ស.ក**ផ្នែកអំពើហិង្សាក្នុងគ្រួសារ (ដោយ

[24] Kelly, L. (1994) ទំនាក់ទំនងអំពើហិង្សាក្នុងគ្រួសារ និងការរំលោភបំពានលើកុមារ: Challenges for research, policy and practice. In: Mullender, A. Morely, R. eds. កុមារដែលកំពុងរស់ក្នុងអំពើហិង្សាក្នុងគ្រួសារ. London: Whiting and Birch.

មិនគិតថាពួកគេធ្លាប់មាន ឬមិនធ្លាប់មានដៃគូស្និទ្ធស្នាលនោះទេ) ត្រូវបានសួរថាតើពួកគេធ្លាប់ទទួលរងអំពើហិង្សាអំឡុងពេលមានផ្ទៃពោះដែរ ឬទេ? មានតែស្ត្រី៤នាក់ប៉ុណ្ណោះបានរាយការណ៍ថា ពួកគេមិនធ្លាប់មានដៃគូ ហើយទទួលរងអំពើហិង្សាអំឡុងពេលមានផ្ទៃពោះ។ ហេតុនេះ អំពើហិង្សាអំឡុងពេលមានផ្ទៃពោះគឺត្រូវបានវិភាគផ្តោតលើតែស្ត្រីធ្លាប់មានដៃគូស្និទ្ធស្នាលតែប៉ុណ្ណោះ ដោយសារតែអត្រាមានផ្ទៃពោះរបស់ពួកគេអាចកើតមានឡើង។

ការពិនិត្យមើលលម្អិតពីលក្ខណៈសារតានៃស្ត្រីធ្លាប់ទទួលរងអំពើហិង្សាអំឡុងពេលមានផ្ទៃពោះត្រូវបានបង្ហាញក្នុងតារាងខ.៣ នៃឧបសម្ព័ន្ធ"ខ"។ ស្ត្រីរស់នៅតំបន់ជនបទស្ទើរតែពីរដងធ្លាប់ទទួលរងអំពើហិង្សាអំឡុងពេលមានផ្ទៃពោះធៀបនឹងស្ត្រីរស់នៅទីប្រជុំជន។ ជាងនេះទៀត អត្រានៃអំពើហិង្សាអំឡុងពេលមានផ្ទៃពោះមានការកើនឡើងយ៉ាងខ្លាំង អាស្រ័យទៅលើចំនួនកូនដែលស្ត្រីមាន។ ដូចគ្នានឹងទម្រង់នៃអំពើហិង្សាផ្សេងៗទៀតដែរ សមាមាត្រស្ត្រីដែលមិនទទួលបានការអប់រំ និងស្ត្រីដែលមានស្ថានភាពជីវភាព ឬទ្រព្យសម្បត្តិទាបបានរាយការណ៍ថាទទួលរងអំពើហិង្សាអំឡុងពេលមានផ្ទៃពោះគឺមានកម្រិតខ្ពស់។

ដូចបានបង្ហាញក្នុងរូបភាពទី៣.១១ ប្រេវ៉ាឡង់នៃស្ត្រីធ្លាប់ទទួលរងអំពើហិង្សាអំឡុងពេលមានផ្ទៃពោះមានកម្រិតខ្ពស់ចំពោះស្ត្រីដែលបានលែងលះ ឬរស់នៅបែកគ្នា ជាងស្ត្រីដែលរស់នៅជាមួយប្តី/ដៃគូ។

**រូបភាពទី ៣.១១. ប្រេវ៉ាឡង់នៃអំពើហិង្សាអំឡុងពេលមានផ្ទៃពោះ បែងចែកតាមស្ថានភាពអាពាហ៍ពិពាហ៍ក្នុងចំណោមស្ត្រីដែលធ្លាប់មានដៃគូ (អ.ប.ស.កឆ្នាំ២០១៤)**




ជនប្រព្រឹត្តអំពើហិង្សាលើរាងកាយអំឡុងពេលមានផ្ទៃពោះត្រូវបានបង្ហាញក្នុងតារាង៣.៣។ ជនប្រព្រឹត្តអំពើហិង្សាញឹកញាប់បំផុតសម្រាប់អំពើហិង្សាលើរាងកាយអំឡុងពេលមានផ្ទៃពោះគឺជាប្តីបច្ចុប្បន្ន ឬអតីតប្តី ឬដៃគូផ្សេងទៀត។

**តារាង ៣.៣ ជនប្រព្រឹត្តអំពើហិង្សាលើរាងកាយអំឡុងពេលមានផ្ទៃពោះក្នុងចំណោមស្ត្រីធ្លាប់មានដៃគូ (អ.ប.ស.ក ឆ្នាំ២០១៤)**

| អ្នកប្រព្រឹត្ត | % | ចំនួនស្ត្រីរងអំពើហិង្សាអំឡុងពេលមានផ្ទៃពោះ |
|---|---|---|
| ប្តី/ដៃគូ | ២.៤ | ៧៧ |
| អតីតប្តី/ដៃគូ | ១.០ | ៣២ |
| ម្តាយ | ០.២ | ៦ |
| ឪពុក/ឪពុកចុង | ០.១ | ៥ |
| បងស្រី /ប្រុស | ០.៣ | ៩ |
| សាច់ញាតិផ្សេងទៀត | ០.១ | ៤ |
| អ្នកផ្សេងទៀត | ០.១ | ៣ |

## អំពើហិង្សាលើរាងកាយប្រព្រឹត្តដោយស្ត្រីទៅលើដៃគូស្និទ្ធស្នាល

ការបកស្រាយលម្អិតអំពីស្ត្រីប្រព្រឹត្តអំពើហិង្សាលើរាងកាយទៅលើដៃគូស្និទ្ធស្នាលនៅពេលស្ត្រីមិនត្រូវបានវាយដំដោយបែងចែកតាមលក្ខណៈសាវតានឹងបង្ហាញនៅក្នុងឧបសម្ព័ន្ធ "ក" តារាង "ក.១០"។ ស្ត្រីដែលធ្លាប់ទទួលរងអំពើហិង្សាលើរាងកាយពីដៃគូស្និទ្ធស្នាលក្នុងមួយជីវិត ឬអំឡុងពេល១២ខែកន្លងមក បានរាយការណ៍ថាពួកគេធ្លាប់ប្រើប្រាស់អំពើហិង្សាលើរាងកាយទៅលើដៃគូស្និទ្ធស្នាលបច្ចុប្បន្ន ឬថ្មីបំផុត នៅពេលដែលដៃគូមិនទាន់វាយដំធ្វើបាបលើរាងកាយរបស់ស្ត្រីមានសមាមាត្រខ្ពស់។ ស្ត្រីធ្លាប់មានដៃគូដែលរស់នៅក្នុងស្ថានភាពគ្រួសារក្រីក្រ ឬមានទ្រព្យសម្បត្តិតិចតួចបំផុតនោះបានរាយការណ៍ថា ពួកគេប្រព្រឹត្តអំពើហិង្សាលើរាងកាយទៅលើដៃគូបច្ចុប្បន្ន ឬ ថ្មីបំផុតមានភាគរយខ្ពស់ធៀបនឹងស្ត្រីស្ថិតក្នុងបញ្ចភាគទ្រព្យសម្បត្តិផ្សេងទៀត។ ស្រដៀងគ្នានេះដែរ ស្ត្រីធ្លាប់មានដៃគូ ហើយទទួលបានការអប់រំកម្រិតមធ្យមសិក្សា ឬខ្ពស់ជាងបានប្រើអំពើហិង្សាទៅលើដៃគូវិញមានភាគរយទាប។ គួរកត់សម្គាល់ថា សមាមាត្រនៃស្ត្រីធ្លាប់មានដៃគូ ដែលរាយការណ៍ថាបានវាយដំលើដៃគូស្និទ្ធស្នាលបច្ចុប្បន្ន ឬថ្មីបំផុតរបស់ពួកគេគឺមានចំនួនប្រហែលពាក់កណ្តាលនៃស្ត្រីដែលរាយការណ៍ថាបានទទួលរងការវាយដំពីដៃគូស្និទ្ធស្នាលបច្ចុប្បន្ន ឬថ្មីបំផុត(រូបភាពទី ៣.១២)។

**រូបភាពទី ៣.១២. ការប្រៀបធៀបសមាមាត្រនៃស្ត្រីវាយដំទៅលើដៃគូស្និទ្ធស្នាលបច្ចុប្បន្ន ឬថ្មីបំផុតជាមួយស្ត្រីធ្លាប់ទទួលរងអំពើហិង្សាលើរាងកាយពីដៃគូស្និទ្ធស្នាលក្នុងចំណោមស្ត្រីធ្លាប់មានដៃគូ(អ.ប.ស.ក ឆ្នាំ២០១៤)**




## ៣.២.បទពិសោធន៍អំពើហិង្សាតាមទម្រង់ផ្សេងទៀត

ផ្នែកនេះបង្ហាញពីលទ្ធផលផ្សេងៗទៀតដែលស្រង់ចេញពីផ្នែកអំពើហិង្សាក្នុងគ្រួសារៈ ជនប្រព្រឹត្តអំពើហិង្សាក្រៅពីដៃគូស្និទ្ធស្នាល (មិនមែនជាដៃគូ) និងឥរិយាបថស្វែងរកជំនួយ។ ដោយសារតែវិធីសាស្ត្រក្នុងការប្រមូលទិន្នន័យផ្នែកអំពើហិង្សាក្នុងគ្រួសារនៃការអង្កេត **អ.ប.ស.ក** ទិន្នន័យអំពីអំពើហិង្សាលើដៃគូស្និទ្ធស្នាលត្រូវបានប្រមូលក្នុងផ្នែកនេះផងដែរ។

### ទិដ្ឋភាពទូទៅនៃអំពើហិង្សាក្រៅពីដៃគូ

ការបកស្រាយលម្អិតពីលក្ខណៈសារតានៃស្ត្រីទទួលរងអំពើហិង្សាលើរាងកាយ ឬផ្លូវភេទដោយអ្នកក្រៅពីដៃគូនឹងមានបង្ហាញនៅក្នុងឧបសម្ព័ន្ធ"ខ" តារាង ខ.១ និង ខ.២។ ខណៈពេលដែលនិន្នាការនៃអត្រាប្រេវ៉ាឡង់អំពើហិង្សាក្នុងជីវិតដែលប្រព្រឹត្តដោយដៃគូស្និទ្ធស្នាលបានកើនឡើងគឺទៅតាមកំណើននៃអាយុរបស់អ្នកផ្តល់ចម្លើយ (ក្នុងរូបភាពទី៣.៤ និង៣.៦ខាងលើ) និន្នាការដូចគ្នានេះមិនបានបង្ហាញសម្រាប់អំពើហិង្សាលើរាងកាយដែលប្រព្រឹត្តដោយអ្នកក្រៅពីដៃគូតាមក្រុមអាយុឡើយ (តារាង ៣.៤)។ សូចនាករ ៥.២.២នៃគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព (SDG) តម្រូវឱ្យមានការរាយការណ៍ពី"សមាមាត្រស្ត្រី និងក្មេងស្រីអាយុ១៥ឆ្នាំឡើងធ្លាប់ទទួលរងអំពើហិង្សាលើផ្លូវភេទពីបុគ្គលផ្សេងៗ ជាជាងដៃគូស្និទ្ធស្នាលអំឡុងពេល១២ខែកន្លងមក ដោយបែងចែកតាមអាយុ និងកន្លែងកើតហេតុ"[25]។ ក៏ប៉ុន្តែ ស្ត្រីតែ០.១%នៃសំណាកគំរូនៃអំពើហិង្សាក្នុងគ្រួសារបានរាយការណ៍ថាធ្លាប់ទទួលរងអំពើហិង្សាលើផ្លូវភេទពីអ្នកក្រៅពីដៃគូអំឡុងពេល១២ខែកន្លងមក(មុនការអង្កេត)។ ដូច្នេះ ការរាយការណ៍អំពីអំពើហិង្សានេះដោយបែងចែកតាមអាយុ និងកន្លែងកើតហេតុបានឡើយ។

[25]ក្រុមជំនាញការអន្តរទីភ្នាក់ងារលើសូចនាករ SDG ២០១៦ ការចងក្រងទិន្នន័យខ្នាតធំសម្រាប់ពិនិត្យឡើងវិញលើសូចនាករសកលដែលបានស្នើឡើងក្នុងរបៀបវារៈគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពឆ្នាំ២០៣០៖ គោលដៅទី ៥ ការសម្រេចបាននូវសមភាពយេនឌ័រ និងការផ្តល់ភាពអង់អាចដល់ស្ត្រីនិងក្មេងស្រីទំព័រ៤ ពី:http://unstats.un.org/sdgs/files/metadata-compilation/Metadata-Goal-5.pdf ១១ កក្កដា ២០១៦

**តារាង ៣.៤. បទពិសោធន៍ទទួលរងទម្រង់ផ្សេងៗនៃអំពើហិង្សាក្នុងជីវិតប្រព្រឹត្តដោយអ្នកក្រៅពីដៃគូក្នុងចំណោមស្ត្រីដែលបានចូលរួមការអង្កេតផ្នែកអំពើហិង្សាក្នុងគ្រួសារ បែងចែកតាមក្រុមអាយុ(អ.ប.ស.ក ឆ្នាំ២០១៤)**

| **អាយុ** | អំពើហិង្សាលើរាងកាយ | អំពើហិង្សាលើផ្លូវភេទ | អំពើហិង្សាលើរាងកាយ និងផ្លូវភេទដោយអ្នកក្រៅពីដៃគូ | អំពើហិង្សាលើរាងកាយ ឬផ្លូវភេទដោយអ្នកក្រៅពីដៃគូ | សរុប |
|---|---|---|---|---|---|
| | % | % | % | % | |
| ១៥-១៩ | ៥.៨ | ០.៨ | ០.១ | ៦.៤ | ៧២៩ |
| ២០-២៤ | ៩.៨ | ៣.១ | ១.០ | ១១.៦ | ៦៨៧ |
| ២៥-២៩ | ៥.៤ | ២.៥ | ០.៩ | ៧.០ | ៦៤៧ |
| ៣០-៣៤ | ១២.២ | ២.២ | ១.០ | ១៣.៥ | ៨០១ |
| ៣៥-៣៩ | ១០.៥ | ០.៤ | ០.២ | ១០.៩ | ៤៥៩ |
| ៤០-៤៤ | ១១.៣ | ១.៣ | ០.៤ | ១២.២ | ៥៣៩ |
| ៤៥-៤៩ | ៦.៥ | ២.៧ | ០.៩ | ៨.៣ | ៤៤៦ |
| **សរុប** | **៨.៨** | **០.៨** | **០.៧** | **១០.១** | **៤៣០៧** |

## ជនប្រព្រឹត្តអំពើហិង្សាលើរាងកាយ

ជនប្រព្រឹត្តអំពើហិង្សាលើរាងកាយជាដៃគូស្និទ្ធស្នាល និងអ្នកក្រៅពីដៃគូទៅលើស្ត្រីដែលបានចូលរួមក្នុងការអង្កេតផ្នែកអំពើហិង្សាក្នុងគ្រួសារនឹងបង្ហាញនៅក្នុងតារាង ៣.៥ ដោយបែងចែកតាមស្ថានភាពអាពាហ៍ពិពាហ៍។ គួរកត់សម្គាល់ថា តារាងនេះបានបញ្ចូលអំពើហិង្សាដែលប្រព្រឹត្តដោយដៃគូស្និទ្ធស្នាល (ដោយសារតែវិធីសាស្ត្រនៃអ.ប.ស.កបានប្រមូលព័ត៌មានពីជនប្រព្រឹត្តអំពើហិង្សាទាំងអស់)។ តារាងនេះបង្ហាញថាប្តី/ដៃគូបច្ចុប្បន្ន ឬអតីត ជាជនប្រព្រឹត្តអំពើហិង្សាលើរាងកាយញឹកញាប់បំផុត និងអ្នកប្រព្រឹត្តបន្ទាប់គឺម្តាយបង្កើត ឬម្តាយចុង។ ព័ត៌មានទាំងនេះនឹងបង្ហាញនៅក្នុងរូបភាពទី៣.១៣។

**តារាង៣.៥. ជនប្រព្រឹត្តអំពើហិង្សាលើរាងកាយក្នុងចំណោមស្ត្រីដែលបានចូលរួមក្នុងការអង្កេតផ្នែកអំពើហិង្សាក្នុងគ្រួសារ បែងចែកតាមស្ថានភាពអាពាហ៍ពិពាហ៍(អ.ប.ស.ក ឆ្នាំ២០១៤)**

| **អ្នកប្រព្រឹត្តអំពើហិង្សាលើរាងកាយ** | **ស្ថានភាពអាពាហ៍ពិពាហ៍**<br>**ធ្លាប់រៀបការ (ចំនួន=២,៩៧៥)** | **មិនដែលរៀបការ (ចំនួន=១,០៦២)** | **ស្ត្រីទាំងអស់ (ចំនួន=៤,៣០៧)** |
|---|---|---|---|
| ប្តី/ដៃគូបច្ចុប្បន្ន | ១៦.២ | គ/ទ | ១២.២ |
| អតីតប្តី/ដៃគូ | ៥.៩ | គ/ទ | ១.៩ |
| មិត្តប្រុសបច្ចុប្បន្ន | ០.១ | ០.២ | ០.១ |
| អតីតមិត្តប្រុស | ០.០* | ០.០ | ០.០* |
| ឪពុក/ឪពុកចុង | ៣.៤ | ២.៥ | ៣.២ |

| | | | |
|---|---|---|---|
| ម្ដាយ/ម្ដាយចុង | ៥.៤ | ១.៧ | ៤.៥ |
| បងប្អូនស្រី/ប្រុស | ១.៤ | ២.០ | ១.៥ |
| កូនស្រី/កូនប្រុស | ០.១ | ០.០ | ០.០* |
| សាច់ញាតិដទៃទៀត | ១.២ | ០.៦ | ១.១ |
| ម្ដាយក្មេក | ០.០* | គ/ទ | ០.០* |
| សាច់ថ្លៃដទៃទៀត | ០.៣ | គ/ទ | ០.៣ |
| គ្រូបង្រៀន | ០.៣ | ០.២ | ០.៣ |
| ថៅកែ/អ្នករួមការងារ | ០.១ | ០.០ | ០.១ |
| នគរបាល/ទាហាន | ០.០ | ០.០* | ០.០ |
| ផ្សេងៗ | ០.៣ | ០.១ | ០.២ |
| <0.១ | | | |
| ចំនួនស្ត្រីបានរងអំពើហិង្សាលើរាងកាយចាប់ពីអាយុ១៥ឆ្នាំឡើង | ៨៤០ | ៧០ | ៩១០ |

គ/ទ= គ្មានទិន្នន័យ

**រូបភាពទី៣.១៣. ជនប្រព្រឹត្តអំពើហិង្សាលើរាងកាយក្នុងចំណោមស្ត្រីដែលបានចូលរួមការអង្កេតផ្នែកអំពើហិង្សាក្នុងគ្រួសារ បែងចែកតាមស្ថានភាពអាពាហ៍ពិពាហ៍ (អ.ប.ស.កឆ្នាំ២០១៤)**




## ជនប្រព្រឹត្តអំពើហិង្សាលើផ្លូវភេទក្រៅពីដៃគូ

គ្រប់ស្ត្រីដែលបានឆ្លើយថា"ចាស់" ខាងក្រោមសំណួរ និងត្រូវសួរបន្តថា តើអ្នកណាបង្ខំអ្នកឱ្យរួមភេទ ឬបង្ខំឱ្យប្រព្រឹត្តសកម្មភាពផ្លូវភេទណាមួយនៅលើកដំបូង ដែលកើតឡើង៖

*នៅពេលណាមួយនៅក្នុងជីវិតរបស់អ្នក ដូចជាកាលពីក្មេង ឬពេលពេញវ័យ តើធ្លាប់មានអ្នកណាម្នាក់បង្ខំអ្នកឱ្យរួមភេទតាមមធ្យោបាយណាមួយ ឬបង្ខំឱ្យអ្នកប្រព្រឹត្តសកម្មភាពផ្លូវភេទណាមួយអ្នកមិនចង់ដែរឬទេ?*

ជនប្រព្រឹត្តអំពើហិង្សាលើផ្លូវភេទនឹងបង្ហាញក្នុងតារាង៣.៦។ មិនមានជនប្រព្រឹត្តអំពើហិង្សាណាម្នាក់ត្រូវបានរាយការណ៍ច្រើនជាង១%នៃសំណាកគំរូអង្កេតឡើយ។ចំពោះស្ត្រីដែលធ្លាប់រៀបការ មិត្តភក្តិ និងសាច់ញាតិត្រូវបានរាយការណ៍ញឹកញាប់បំផុតថា ជាជនប្រព្រឹត្តអំពើហិង្សាលើផ្លូវភេទ។ ចំពោះស្ត្រីដែលមិនធ្លាប់រៀបការ មិត្តប្រុសបច្ចុប្បន្ន ឬអតីត ឬអ្នកដែលមិនស្គាល់ត្រូវបានរាយការណ៍ញឹកញាប់ថាជាជនប្រព្រឹត្តអំពើហិង្សាលើផ្លូវភេទ។

**តារាង ៣.៦. ជនប្រព្រឹត្តអំពើហិង្សាដែលបង្ខំឱ្យស្ត្រីរួមភេទជាលើកដំបូងក្នុងជីវិតក្នុងចំណោមស្ត្រីដែលធ្លាប់មានអំពើហិង្សាក្នុងគ្រួសារ បែងចែកតាមស្ថានភាពអាពាហ៍ពិពាហ៍ (អ.ប.ស.ក ឆ្នាំ២០១៤)**

| បុគ្គល | ស្ថានភាពអាពាហ៍ពិពាហ៍ | | |
|---|---|---|---|
| | ធ្លាប់រៀបការ | មិនដែលរៀបការ | ចំនួន |
| ប្តី/ដៃគូបច្ចុប្បន្ន | ០.១ | គ/ទ | ០.១ |
| អតីតប្តី/ដៃគូ | ០.១ | គ/ទ | ០.០* |
| មិត្តប្រុសបច្ចុប្បន្ន/អតីត | ០.២ | ០.៨ | ០.៣ |
| ឪពុក/ឪពុកចុង | ០.១ | ០.០ | ០.១ |
| ម្តាយ/ម្តាយចុង | ០.០ | ០.០ | ០.០ |
| សាច់ញាតិដទៃទៀត | ០.៤ | ០.១ | ០.៣ |
| សាច់ថ្លៃដទៃទៀត | ០.២ | គ/ទ | ០.២ |
| មិត្តភក្តិ/អ្នកស្គាល់គ្នា | ០.៥ | ០.៣ | ០.៤ |
| គ្រួសាររបស់មិត្តភក្តិ | ០.១ | ០.០ | ០.១ |
| នគរបាល/ទាហាន | ០.០* | ០.០ | ០.០ |
| អ្នកមិនស្គាល់មុខ | ០.៣ | ០.៦ | ០.៤ |
| ចំនួនស្ត្រីដែលធ្លាប់រងអំពើហិង្សាលើផ្លូវភេទ | ២៤១ | ២១ | ២៦២ |

[1]ស្ត្រីអាចរាយការណ៍អំពីមនុស្សច្រើនជាងម្នាក់ដែលបានប្រព្រឹត្តអំពើហិង្សា

គ/ទ = គ្មានទិន្នន័យ

សម្គាល់៖ តារាងនេះដូចគ្នាតារាង២០.៤ ក្នុងរបាយការណ៍ អ.ប.ស.ក ២០១៤

ស្ត្រីរាយការណ៍ថាត្រូវបានគេបង្ខំឱ្យរួមភេទជាលើកដំបូងភាគច្រើននៅចន្លោះអាយុ ២០-២៤ និង៣០ឆ្នាំឡើង ឬអាយុចំពោះស្ត្រីដែលធ្លាប់រៀបការ។ ចំពោះស្ត្រីដែលមិនធ្លាប់រៀបការ ភាគច្រើនបានរាយការណ៍ថាត្រូវបានបង្ខំឱ្យរួមភេទលើកដំបូងនៅអាយុ២៥ឆ្នាំឡើង(តារាង៣.៧)

**តារាង ៣.៧. អាយុរបស់ស្ត្រីត្រូវបានចាប់បង្ខំក្នុងការរួមភេទលើកដំបូងក្នុងចំណោមស្ត្រីដែលចូលរួមក្នុងការអង្កេតផ្នែកអំពើហិង្សាក្នុងគ្រួសារ បែងចែកតាមស្ថានភាពអាពាហ៍ពិពាហ៍ (អ.ប.ស.ក ឆ្នាំ២០១៤)**

| លក្ខណៈអង្កេត | ភាគរយស្ត្រីដែលរងការបង្ខំឲ្យរួមភេទលើកដំបូង តាមក្រុមអាយុ | | | | | |
|---|---|---|---|---|---|---|
| | <១០ឆ្នាំ | ១០-១៤ឆ្នាំ | ១៥-១៩ឆ្នាំ | ២០-២៤ឆ្នាំ | ២៥-២៩ឆ្នាំ | >៣០ឆ្នាំ |
| **ស្ថានភាពអាពាហ៍ពិពាហ៍** | | | | | | |
| មិនដែលរៀបការ | ០.០ | ០.០ | ០.៤ | ០.៤ | ០.៦ | ០.៦ |
| ធ្លាប់រៀបការ | ០.១ | ០.០ | ០.៣ | ២.១ | ១.៦ | ៣.០ |
| ស្ត្រីទាំងអស់ | ០.១ | ០.០ | ០.៣ | ១.៧ | ១.៣ | ២.៤ |

## ឥរិយាបថស្វែងរកជំនួយ

ស្ត្រីទាំងអស់ដែលបានរាយការណ៍អំពីបទពិសោធន៍ទទួលរងអំពើហិង្សាលើរាងកាយ ឬផ្លូវភេទពីដៃគូស្និទ្ធស្នាល ឬ អ្នកក្រៅពីដៃគូត្រូវបានសួរថា តើពួកគេបានស្វែងរកជំនួយដែរឬទេ ("គិតអំពីបញ្ហាដែលអ្នកបានជួបប្រទះ ដែលយើងបានជជែកគ្នាពីខាងលើ តើអ្នកធ្លាប់បានព្យាយាមដើម្បីស្វែងរកការជួយដែរឬទេ ? " ហើយតើអ្នកណាដែលអ្នកបានស្វែងរកជំនួយ ? ដោយសារតែរបៀបដែលសំណួរត្រូវបានរៀបចំឡើងមិនបង្កឱ្យមានភាពងាយស្រួលក្នុងការញែកចម្លើយ ដែលប្រព្រឹត្តដោយដៃគូស្និទ្ធស្នាល និងអ្នកក្រៅពីដៃគូ។ ក៏ប៉ុន្តែដោយសារតែស្ត្រីជាច្រើនធ្លាប់ទទួលរងអំពើហិង្សាពីដៃគូស្និទ្ធស្នាលច្រើនជាងអ្នកក្រៅពីដៃគូ ដែលអាចបណ្តាលស្ថានភាពនេះគ្របដណ្តប់ចម្លើយទាំងអស់។

ឥរិយាយបថស្វែងរកជំនួយចំពោះស្ត្រីដែលចូលរួមក្នុងការអង្កេតផ្នែកអំពើហិង្សាក្នុងគ្រួសារដែលទទួលរងអំពើហិង្សាពីដៃគូស្និទ្ធស្នាល ឬអ្នកក្រៅពីដៃគូទៅតាមលក្ខណៈសាវតានឹងបង្ហាញនៅក្នុងឧបសម្ព័ន្ធ"ខ" តារាង"ខ៤"។ ស្ត្រីដែលមានកូនប្រាំនាក់ ឬច្រើនជាងបានស្វែងរកជំនួយដើម្បីបញ្ឈប់អំពើហិង្សាមានភាគរយខ្ពស់ បើធៀបជាមួយស្ត្រីដែលគ្មានកូន(រូបភាពទី៣.១៤)។ គួរកត់សម្គាល់ផងដែរថា ស្ត្រីអាយុពី៤០-៤៩ឆ្នាំ(៥២.៥%)មានភាគរយខ្ពស់ដែលបានស្វែងរកជំនួយដើម្បីបញ្ឈប់អំពើហិង្សាបើធៀបជាមួយស្ត្រីអាយុ២០-២៤ឆ្នាំ(២៩%)។ នេះបង្ហាញអំពីទំនាក់ទំនងយ៉ាងខ្លាំងរវាងអាយុរបស់អ្នកឆ្លើយតប និងចំនួនកូនរស់នៅក្នុងគ្រួសារ។ ដូចដែលបានបង្ហាញ អំពើហិង្សាលើដៃគូស្និទ្ធស្នាលក្នុងជីវិតបានកើនឡើងទៅតាមអាយុ និងចំនួនកូន យើងអាចសន្និដ្ឋានបានអំពីទំនាក់ទំនងយ៉ាងជិតស្និទ្ធរវាងចំនួនបទពិសោធន៍ទទួលរងអំពើហិង្សា និងការស្វែងរកជំនួយ។

**រូបភាពទី ៣.១៤. ភាគរយស្ត្រីធ្លាប់ទទួលរងអំពើហិង្សាដោយដៃគូស្និទ្ធស្នាល ឬអ្នកក្រៅពីដៃគូបានស្វែងរកជំនួយ បែងចែកតាមចំនួនកូនរស់នៅក្នុងគ្រួសារ (អ.ប.ស.ក ឆ្នាំ២០១៤)**




ប្រភពជំនួយចម្បងៗសម្រាប់ស្ត្រីដែលធ្លាប់ទទួលរងអំពើហិង្សាលើរាងកាយ ឬផ្លូវភេទដោយដៃគូស្និទ្ធស្នាល ឬអ្នកក្រៅពីដៃគូគឺសមាជិកគ្រួសារផ្ទាល់ខ្លួន ឬអ្នកជិតខាង(តារាង៣.៨)។ ស្ត្រី ១នាក់ក្នុងចំណោម២០នាក់ធ្លាប់ទទួលរងអំពើហិង្សាលើរាងកាយ ឬ១នាក់ក្នុងចំណោម១០នាក់ធ្លាប់ទទួលរងអំពើហិង្សាលើរាងកាយ ឬផ្លូវភេទបានស្វែងរកជំនួយពីនគរបាល។ នគរបាលត្រូវបានកំណត់ថាជាប្រភពជំនួយស្ទើរតែដូចគ្នាប្តី ឬសមាជិកគ្រួសាររបស់អ្នកផ្តល់ចម្លើយ (ដែលគឺជាដៃគូរបស់ស្ត្រី)។

តារាង ៣.៨ ប្រភពស្វែងរកជំនួយរបស់ស្ត្រីដែលធ្លាប់ទទួលរងអំពើហិង្សាលើរាងកាយ ឬផ្លូវភេទពីដៃគូស្និទ្ធស្នាល ឬអ្នកក្រៅពីដៃគូ តាមប្រភេទអំពើហិង្សា(តែលើរាងកាយ តែលើផ្លូវភេទ លើរាងកាយ និងផ្លូវភេទ លើរាងកាយ ឬលើផ្លូវភេទ) (អ.ប.ស.ក ឆ្នាំ២០១៤)

| បុគ្គល | ប្រភេទអំពើហិង្សា<br>តែលើរាងកាយ | តែលើ ផ្លូវភេទ | លើរាងកាយ និងផ្លូវភេទ | លើរាងកាយ ឬផ្លូវភេទ (សរុប) |
|---|---|---|---|---|
| សមាជិកគ្រួសារខ្លួនឯង | ២៣.៣ | ២៥.៣ | ៣១.៣ | ២៤.៩ |
| គ្រួសាររបស់ប្តី/ដៃគូស្និទ្ធស្នាល | ៤.៧ | ១.១ | ៧.៦ | ៤.៩ |
| ប្តី/ដៃគូស្និទ្ធស្នាល | ០.២ | ០.០ | ០.១ | ០.២ |
| មិត្តប្រុស | ០.៨ | ២.៧ | ០.០ | ០.៣ |
| មិត្តភក្តិ | ២.៩ | ៧.២ | ៣.១ | ៣.៣ |
| អ្នកជិតខាង | ១២.៤ | ០.០ | ១៩.៣ | ១២.២ |
| មេដឹកនាំសាសនា | ០.១ | ៣.២ | ០.០ | ០.៣ |
| វេជ្ជបណ្ឌិត/បុគ្គលិកគ្រូពេទ្យ | ០.៤ | ០.០ | ០.០ | ០.៣ |
| នគរបាល | ៤.៤ | ១.៧ | ១០.៦ | ៥.៣ |

| | | | | |
|---|---|---|---|---|
| មេធាវី | ០.២ | ០.០ | ០.៨ | ០.៣ |
| អង្គការផ្នែកកិច្ចការសង្គម | ០.០ | ០.៤ | ១.០ | ០.២ |
| ផ្សេងៗ | ៦.០ | ២.៥ | ១៣.២ | ៧.០ |
| ចំនួនស្ត្រីដែលបានរងអំពើហិង្សានិងការស្វែងរកជំនួយ | ២៨១ | ៣០ | ៩៥ | ៤០៦ |

ស្ត្រីតិចជាង១% ធ្លាប់ទទួលរងអំពើហិង្សាលើរាងកាយបានរាយការណ៍ថា ពួកគេបានស្វែងរកជំនួយពីវេជ្ជបណ្ឌិត ឬបុគ្គលិកជំនាញសុខាភិបាល ។ មិនមានស្ត្រីណាម្នាក់ធ្លាប់ទទួលរងអំពើហិង្សាលើផ្លូវភេទបានរាយការណ៍ថា ពួកគេបានស្វែងរកជំនួយពីបុគ្គលិកជំនាញសុខាភិបាលទេ ។ សមាមាត្រស្ត្រីធ្លាប់ទទួលរងអំពើហិង្សាលើរាងកាយ ឬផ្លូវភេទតែងតែរងរបួសមានកម្រិតខ្ពស់ ដែលតម្រូវឱ្យមានការយកចិត្តទុកដាក់ក្នុងការព្យាបាល (សូមមើលតារាងទី ៣.២ខាងលើ)។ តាមលទ្ធផលនេះអាចឱ្យយើងសន្និដ្ឋានបានថា ការសិក្សាបន្ថែមទៀតចាំបាច់ត្រូវតែធ្វើឡើង ដើម្បីស្វែងយល់ថាហេតុអ្វីស្ត្រីមិនបានស្វែងរកជំនួយពីពេទ្យជំនាញ។ តាមការស្រាវជ្រាវថ្នាក់ជាតិស្តីពីសុខភាព និង បទពិសោធន៍ក្នុងជីវិតរបស់ស្ត្រីបានបង្ហាញថាមូលហេតុចម្បងដែលនាំឱ្យស្ត្រីទទួលរងអំពើហិង្សាមិនបានស្វែងរកជំនួយគឺដោយសារភាពភ័យខ្លាច ការខ្មាស់អៀន និងបទដ្ឋានសង្គម ហេតុនេះតម្រូវឱ្យបុគ្គលិកជំនាញសុខាភិបាលជួយដល់ស្ត្រីក្នុងការធ្វើដើម្បីគាត់មានភាពងាយស្រួល ដើម្បីបង្ហាញពីអំពើហិង្សាដែលពួកគេធ្លាប់ជួបប្រទះ។

# ផ្នែកទី ៤

## ៤. និន្នាការអំពើហិង្សាលើដៃគូស្និទ្ធស្នាលអំឡុងពេលកន្លងមក

ជាការពិតប្រទេសកម្ពុជាមានទិន្នន័យស្តីពីអំពើហិង្សាក្នុងគ្រួសារពី**អ.ប.ស.ក** ដែលបានអង្កេតចំនួន៣លើករួចមកហើយក្នុងឆ្នាំ២០០០ ២០០៥ និង២០១៤ដោយផ្តល់ឱកាសក្នុងស្វែងយល់និងពន្យល់ពីការប្រែប្រួលនៃកម្រិតអំពើហិង្សាលើដៃគូស្និទ្ធស្នាលអំឡុងពេលកន្លងមក។

### ៤.១. ភាពខុសគ្នានៃវិធីសាស្ត្រស្រាវជ្រាវ

ដូចដែលបានដឹងរួចមកហើយថាភាពខុសគ្នាក្នុងវិធីសាស្ត្រស្រាវជ្រាវទំនងជាផ្តល់លទ្ធផលខុសគ្នាក្នុងការបកស្រាយ ហើយដើម្បីបកស្រាយទិន្នន័យបានត្រឹមត្រូវ ជាដំបូងយើងត្រូវពិនិត្យមើលវិធីសាស្ត្រដែលដូចគ្នា និងភាពខុសគ្នារវាងការអង្កេតទាំង៣។ ភាពខុសគ្នាក្នុងវិធីសាស្ត្រអង្កេតនឹងសង្ខេបនៅក្នុងតារាង៤.១។

**តារាង៤.១. ការជ្រើសរើសសំណាកគំរូ និងលក្ខណៈនៃសំណាកគំរូផ្នែកអំពើហិង្សាក្នុងគ្រួសារនៃអ.ប.ស.ក. ឆ្នាំ ២០០០ ២០០៥ និង ២០១៤**

| ការពិពណ៌នា | ២០០០ និង២០០៥ | ២០១៤ |
|---|---|---|
| វិធីសាស្ត្រជ្រើសរើសសំណាកគំរូស្ត្រីសម្រាប់គ្រប់ **អ.ប.ស.ក** | ស្ត្រីអាយុពី១៥-៤៩ឆ្នាំ ជាសមាជិកគ្រួសារអចិន្ត្រៃយ៍ ឬភ្ញៀវដែលស្នាក់នៅក្នុងគ្រួសារក្នុងយប់មុនថ្ងៃអង្កេតត្រូវបានជ្រើសរើសសម្រាប់សម្ភាសន៍(ឆ្នាំ២០០០មាន ១៥,៣៥១នាក់ និងឆ្នាំ២០០៥មាន ១៦,៨២៣ នាក់) | ស្ត្រីអាយុពី១៥-៤៩ឆ្នាំជាសមាជិកគ្រួសារអចិន្ត្រៃយ៍ ឬភ្ញៀវដែលបានស្នាក់នៅក្នុងគ្រួសារក្នុងយប់មុនថ្ងៃអង្កេតត្រូវបានជ្រើសរើសសម្រាប់សម្ភាសន៍ |
| វិធីសាស្ត្រជ្រើសរើសសំណាកគំរូគ្រួសារសម្រាប់ផ្នែកអំពើហិង្សាក្នុងគ្រួសារ | សំណាកគំរូរងគ្រួសារត្រូវបានជ្រើសរើសសម្រាប់សម្ភាសន៍ផ្នែកស្ថានភាពស្ត្រី | សំណាកគំរូគ្រួសារត្រូវបានជ្រើសរើសសម្រាប់សម្ភាសន៍ផ្នែកអំពើហិង្សាក្នុងគ្រួសារ។ សូមកត់សម្គាល់ថាបុរសម្នាក់អាយុ ១៥-៤៩ឆ្នាំក្នុងគ្រួសារដែលបានជ្រើសរើសសម្រាប់សម្ភាសន៍ផ្នែកអំពើហិង្សាក្នុងគ្រួសារបានជ្រើសរើសសម្រាប់សម្ភាសន៍លើព័ត៌មានផែនការគ្រួសារ ចំណេះដឹង និងឥរិយាបថអំពីមេរោគ និងជំងឺអេដស៍ និងជំងឺឆ្លងផ្សេងៗ។ |
| ចំនួនស្ត្រីដែលបានជ្រើសរើសតែមិនត្រូវបានចាត់បញ្ចូលក្នុងការវិភាគ ដោយសារឯកជនភាពគឺមិនត្រូវបានឆ្លើយតប | ២០០០៖ មិនបានរបាយការណ៍<br>២០០៥៖ មានចំនួន ៣៤នាក់ | មានចំនួន ២៨ (០.៦%) |

| | | |
|---|---|---|
| ស្ថានភាពអាពាហ៍ពិពាហ៍របស់ស្ត្រីដែលមានលក្ខណៈគ្រប់គ្រាន់ផ្នែកអំពើហិង្សាក្នុងគ្រួសារ | ស្ត្រីអាយុ១៥-៤៩ ដែលបានទើបរៀបការ ឬធ្លាប់រៀបការពីមុន។ | ស្ត្រីអាយុពី ១៥-៤៩ឆ្នាំ ដែលទើបរៀបការ ឬធ្លាប់រៀបការពីមុន ឬមានដៃគូរួមភេទ(សំណួរស្តីពីអំពើហិង្សាលើដៃគូ និងអំពើហិង្សាដោយអ្នកក្រៅពីដៃគូ) ស្ត្រីមិនដែលរៀបការ (អំពើហិង្សាដោយអ្នកណាម្នាក់) |
| %សំណាកគំរូស្ត្រីដែលបានសម្ភាសន៍ក្នុងផ្នែកអំពើហិង្សាក្នុងគ្រួសារនៃអ.ប.ស.ក | ២០០០៖ ២៥% ក្នុងចំណោម ១៥,៣៥១នាក់<br>២០០៥៖២៥% ក្នុងចំណោម ១៦,៨២៣នាក់ | ២៥% ក្នុងចំណោម១៧,៥៧៨នាក់ (ស្ត្រី៤,៣០៧) |

លក្ខណៈវិនិច្ឆ័យនៃការជ្រើសរើសសំណាកគំរូសម្រាប់ការអង្កេតអ.ប.ស.កនីមួយៗនឹងបង្ហាញក្នុង(តារាង៤.១) លើកលែងតែលក្ខណៈវិនិច្ឆ័យនៃការជ្រើសរើសសំណាកគំរូស្ត្រីដែលចូលរួមផ្នែកអំពើហិង្សាក្នុងគ្រួសារ។ ការអង្កេតចំនួន២លើកដំបូង មានតែស្ត្រីអាយុ១៥-៤៩ឆ្នាំដែលទើបរៀបការ និងធ្លាប់រៀបការបានចូលរួមផ្នែកអំពើហិង្សា ហើយអំពើហិង្សាលើដៃគូស្និទ្ធស្នាលត្រូវបានគណនាសម្រាប់តែស្ត្រី"ដែលធ្លាប់បានរៀបការរួច"អាយុ១៥-៤៩ឆ្នាំ។ ក្នុងការអង្កេតឆ្នាំ២០១៤ រាល់ស្ត្រីដែលមានអាយុ១៥-៤៩ឆ្នាំបានចូលរួមក្នុងផ្នែកអំពើហិង្សាក្នុងគ្រួសា។ សម្រាប់ការគណនាអំពើហិង្សាលើដៃគូស្និទ្ធស្នាល ការកំណត់និយមន័យនៃអ្នកធ្លាប់មានដៃគូត្រូវបានដាក់បញ្ចូលបន្ថែមទាំងអ្នកធ្លាប់មានដៃគូរួមភេទផងដែរ។ លើសពីនេះទៀត ការអង្កេតឆ្នាំ២០១៤បានបន្ថែមស្ត្រីមិនដែលរៀបការសម្រាប់សម្ភាសន៍លើផ្នែកអំពើហិង្សាក្នុងគ្រួសារ ដើម្បីរាយការណ៍ពី"បទពិសោធន៍ធ្លាប់ទទួលរងអំពើហិង្សាតាមប្រភេទផ្សេងៗទៀត" ។

សំណួរអំពីសកម្មភាពនៃអំពើហិង្សាលើរាងកាយ និងផ្លូវភេទក៏មានភាពខុសគ្នាជាច្រើនកន្លែងរវាងការអង្កេតអ.ប.ស.កលើកដំបូងទាំងពីរ និងអង្កេតចុងក្រោយដូចមានបង្ហាញក្នុងតារាង៤.២។

**តារាង ៤.២. កម្រងសំណួរស្តីពីអំពើហិង្សាលើរាងកាយ ផ្លូវភេទ និងផ្លូវចិត្តនៃ អ.ប.ស.កផ្នែកអំពើហិង្សាក្នុងគ្រួសារ ឆ្នាំ២០០០ ២០០៥ និង២០១៤**

| ការពិពណ៌នា | ២០០០ និង២០០៥ | ២០១៤ |
|---|---|---|
| ចំនួនសំណួរអំពីអំពើហិង្សាលើរាងកាយឬផ្លូវភេទដោយដៃគូស្និទ្ធស្នាល | រាងកាយ៖ ៧សំណួរ<br>ផ្លូវភេទ៖ ២ សំណួរ | រាងកាយ៖ ៧សំណួរ<br>ផ្លូវភេទ៖ ៣ សំណួរ |
| សំណួរស្តីពីសកម្មភាពអំពើហិង្សាលើរាងកាយ | តើប្តី (ចុងក្រោយ)របស់អ្នកធ្លាប់—<br>**ក)** ច្រានអ្នក បោកអ្នក ឬគប់អ្វីមួយទៅលើអ្នកដែរ ឬទេ?<br>**ខ)** ទះអ្នក ឬមួលដៃរបស់អ្នក ឬទេ?<br>**គ)** ដាល់អ្នកដោយប្រើកណ្តាប់ដៃ | តើប្តី/ដៃគូស្និទ្ធស្នាល(ចុងក្រោយ)របស់អ្នកធ្លាប់—<br>**ក)** ច្រានអ្នក បោកអ្នក ឬគប់អ្វីមួយទៅអ្នកដែរ ឬទេ?<br>**ខ)** ទះអ្នកដែរ ឬទេ ? |

| | | |
|---|---|---|
| | ឬប្រើអ្វីមួយ បុកធ្វើឱ្យអ្នកមានការឈឺចាប់ដែរ ឬទេ?<br>**ឃ**) ទាត់ធាក់អ្នក អូសអ្នក ឬវាយបោះអ្នកដែរ ឬទេ?<br>**ង**) ព្យាយាមខ្ទប់ដង្ហើមអ្នក ឬប៉ងដុតអ្នកដែរ ឬទេ?<br>**ច**) គំរាមកំហែង ឬវាយប្រហារអ្នកដោយប្រើកាំបិតកាំភ្លើង ឬគ្រឿងសព្វាវុធផ្សេងៗទៀតដែរ ឬទេ?<br>**ឆ**)វាយប្រហារអ្នកដោយប្រើកាំបិតកាំភ្លើង ឬគ្រឿងសព្វាវុធផ្សេងៗទៀតដែរ ឬទេ? | **គ**) មួលដៃរបស់អ្នក ឬ**បោចសក់**របស់អ្នកដែរ ឬទេ?<br>**ឃ**) ដាល់អ្នកដោយប្រើកណ្ដាប់ដៃ ឬ ប្រើអ្វីមួយបុកធ្វើឱ្យអ្នកមានការឈឺចាប់ដែរ ឬទេ?<br>**ង**) ទាត់ធាក់អ្នក អូសអ្នក ឬវាយបោះអ្នកដែរឬទេ?<br>**ច**) ព្យាយាមខ្ទប់ដង្ហើមអ្នក ឬប៉ងដុតអ្នកដែរ ឬទេ?<br>**ឆ**) គំរាមកំហែង ឬវាយប្រហារអ្នកដោយប្រើកាំបិត កាំភ្លើង ឬគ្រឿងសព្វាវុធផ្សេងៗទៀតដែរ ឬទេ? |
| សំណួរស្តីពីសកម្មភាពអំពើហិង្សាលើផ្លូវភេទ | តើប្តី(ចុងក្រោយ) របស់អ្នកធ្លាប់—<br>**ក**) ប្រើកម្លាំងចាប់បង្ខំឱ្យអ្នករួមភេទជាមួយគាត់នៅពេលដែលអ្នកមិនចង់ដែរ ឬទេ?<br>**ខ**)បង្ខំឱ្យអ្នកប្រព្រឹត្តសកម្មភាពផ្លូវភេទតាមវិធីផ្សេងៗដែលអ្នកមិនចង់ដែរ ឬទេ? | តើប្តី/ដៃគូស្និទ្ធស្នាល (ចុងក្រោយ)របស់អ្នកធ្លាប់—<br>**ក**)ប្រើកម្លាំងចាប់បង្ខំឱ្យអ្នករួមភេទជាមួយគាត់នៅពេលដែលអ្នកមិនចង់ដែរ ឬទេ?<br>**ខ**)**ប្រើកម្លាំងបង្ខំ**ឱ្យអ្នកប្រព្រឹត្តសកម្មភាពផ្លូវភេទតាមវិធីផ្សេងៗដែលអ្នកមិនចង់ដែរឬទេ?<br>**គ**) **បង្ខំអ្នកដោយគំរាម** ឬដោយមធ្យោបាយផ្សេងទៀតឱ្យអ្នកប្រព្រឹត្តសកម្មភាពផ្លូវភេទតាមវិធីផ្សេងៗដែលអ្នកមិនចង់ដែរ ឬទេ? |
| តើការវាស់វែងអំពើហិង្សាលើរាងកាយ និងផ្លូវភេទអំឡុងពេល១២ខែកន្លងមកមានលក្ខណៈដូចម្តេច? | ទង្វើរបស់ប្តីបច្ចុប្បន្ន/ថ្មីបំផុត៖ តើអំពើហិង្សានេះធ្លាប់កើតឡើងទេ? តើកើតឡើងញឹកញាប់ទេអំឡុងពេល ១២ខែកន្លងមក៖ ១-២ដង ៣-៥ដង ច្រើនជាង៥ដង | ទង្វើរបស់ប្តី/ដៃគូស្និទ្ធស្នាលបច្ចុប្បន្ន ឬថ្មីបំផុត៖ តើអំពើហិង្សានេះធ្លាប់កើតឡើងទេ? តើកើតឡើងញឹកញាប់ទេអំឡុងពេល១២ខែកន្លងមក? ញឹកញាប់ ឬម្តងម្កាល?<br>សម្រាប់អតីតប្តី/ដៃគូ៖ សំណួរត្រូវបានសួរគ្រប់សកម្មភាពនៃការប្រព្រឹត្តអំពើហិង្សាលើរាងកាយ និងផ្លូវភេទ។ |
| តើការវាស់អំពើហិង្សាលើផ្លូវចិត្តមានលក្ខណៈដូចម្តេច?<br><br>សម្ភាសន៍ | តើប្តី (ចុងក្រោយ) របស់អ្នកធ្លាប់—<br>**ក**) និយាយ ឬធ្វើអ្វីមួយដើម្បីបំបាក់មុខអ្នកនៅចំពោះមុខអ្នកដទៃដែរ ឬទេ?<br>**ខ**) គំរាមធ្វើឱ្យអ្នកឈឺចាប់ ឬប៉ងធ្វើអំពើអាក្រក់ដល់នរណាម្នាក់ដែលជិតស្និទ្ធនឹងអ្នកដែរឬទេ?<br>**គ**) ប្រើពាក្យមិនល្អចំពោះអ្នកដែរឬទេ? | តើ ប្តី/ដៃគូស្និទ្ធស្នាល (ចុងក្រោយ) របស់អ្នកធ្លាប់—<br>**ក**)និយាយ ឬធ្វើអ្វីមួយដើម្បីបំបាក់មុខអ្នកនៅចំពោះមុខអ្នកដទៃដែរឬទេ?<br>**ខ**) គំរាមធ្វើឱ្យអ្នកឈឺចាប់ ឬប៉ងធ្វើអំពើអាក្រក់ដល់អ្នក ឬនរណាម្នាក់ដែលជិត ស្និទ្ធនឹងអ្នកដែរ ឬទេ?<br>**គ**) ជេរប្រមាថអ្នក ឬធ្វើឱ្យអ្នកមានអារម្មណ៍មិនល្អចំពោះខ្លួនឯងដែរឬទេ? |

| | | |
|---|---|---|
| តើអំពើហិង្សាលើដៃគូស្និទ្ធស្នាល(ដៃគូបច្ចុប្បន្ន/ថ្មីបំផុត/ដៃគូណាម្នាក់) ត្រូវបានកំណត់យ៉ាងដូចម្តេច? | ដៃគូបច្ចុប្បន្ន/ថ្មីបំផុត (រាងកាយ/ផ្លូវភេទ/ផ្លូវចិត្ត) | ដៃគូបច្ចុប្បន្ន/ថ្មីបំផុត (រាងកាយ/ផ្លូវភេទ/សេដ្ឋកិច្ច/ផ្លូវចិត្ត)<br>ដៃគូណាម្នាក់ (រាងកាយ/ផ្លូវភេទ) |

ក្នុងចំណោមភាពខុសគ្នាទាំងនេះ ការអង្កេតឆ្នាំ២០០០ និង២០០៥ បានបញ្ចូលសំណួរអំពីសកម្មភាពនៃអំពើហិង្សាលើរាងកាយដែលសួរថា តើប្តីឬដៃគូបច្ចុប្បន្ន ឬថ្មីបំផុតរបស់ពួកគេធ្លាប់បាន "ទះកំផ្លៀង ឬមួលដៃ"ដែរឬទេ? ។ ការអង្កេតឆ្នាំ២០១៤ អ្នកផ្តល់ចម្លើយត្រូវបានសួរតែ តើប្តីឬដៃគូបច្ចុប្បន្នឬថ្មីបំផុតធ្លាប់"ទះកំផ្លៀង"ដែរឬទេ?។ ការអង្កេតឆ្នាំ២០១៤នេះ បានបន្ថែមសំណួរ តើមាននរណាធ្លាប់មួលដៃរបស់គាត់ និងធ្លាប់បោចសក់របស់គាត់ដែរឬទេ?(សំណួរនេះមិនត្រូវបានសួរនៅក្នុងការអង្កេតមុនៗទេ)។ លើសពីនេះទៅទៀត ការអង្កេតឆ្នាំ២០០០ និង២០០៥ សំណួរចំនួនពីរដាច់ដោយឡែកពីគ្នាត្រូវបានសួរៈ ថាតើពួកគេធ្លាប់ត្រូវបានគំរាមកំហែងដោយប្រើកាំបិត ឬកាំភ្លើងដែរឬទេ? ឬថាតើជនប្រព្រឹត្តធ្លាប់បានប្រើកាំបិត ឬកាំភ្លើងមកលើពួកគេដែរឬទេ? ការអង្កេតឆ្នាំ២០១៤ សំណួរស្តីពីការគំរាមកំហែង ឬវាយប្រហារដោយប្រើកាំបិត ឬកាំភ្លើងត្រូវបានបញ្ចូលគ្នាតែមួយ។

ការអង្កេតឆ្នាំ២០១៤ក៏បានបន្ថែមសំណួរមួយទៀតនៅផ្នែកអំពើហិង្សាលើផ្លូវភេទ។ ការអង្កេតឆ្នាំ២០០០ និង២០០៥ ការវាស់វែងអំពើហិង្សាលើផ្លូវភេទផ្តោតលើៈ ប្តីធ្លាប់ប្រើកម្លាំងបង្ខំ ឱ្យរួមភេទនៅពេលដែលអ្នកមិនចង់ដែរឬទេ? ប្តីធ្លាប់បង្ខំឱ្យរួមភេទតាមវិធីផ្សេងៗនៅពេលដែលអ្នកមិនចង់ដែរ ឬទេ?។

ការអង្កេតឆ្នាំ២០១៤ សំណួរទាំងនេះត្រូវបានផ្លាស់ប្តូរទៅជាៈ តើប្តី/ដៃគូធ្លាប់ប្រើកម្លាំងបង្ខំឱ្យរួមភេទនៅពេលដែលអ្នកមិនចង់ដែរឬទេ? តើប្តីឬដៃគូធ្លាប់បានប្រើកម្លាំងបង្ខំឱ្យរួមភេទតាមវិធីផ្សេងៗនៅពេលដែលអ្នកមិនចង់ដែរឬទេ? តើប្តី/ដៃគូធ្លាប់បានបង្ខំឱ្យអ្នកប្រព្រឹត្តសកម្មភាពផ្លូវភេទតាមវិធីផ្សេងៗដែលអ្នកមិនចង់ដែរឬទេ?

ទន្ទឹមនឹងភាពខុសគ្នាខាងលើនេះ យើងមិនអាចបង្ហាញបានថាតើការបកប្រែជាភាសាខ្មែរមានភាពខុសគ្នា ឬស្រដៀងគ្នាពី អង្កេតមួយទៅ អង្កេតមួយទៀតនោះដែរឬទេ?

ជាចុងក្រោយ ភាពខុសគ្នាដែលសំខាន់នៅក្នុងអ.ប.ស.កចុងក្រោយគឺមានការបណ្តុះបណ្តាលយ៉ាងទូលំទូលាយស្តីពីបញ្ហាយេនឌ័រ និងអំពើហិង្សា ហើយនឹងសារៈសំខាន់នៃការសុវត្ថិភាព និងការរក្សាការសម្ងាត់សម្រាប់គុណភាពទិន្នន័យ បើធៀបទៅនឹងអង្កេត អ.ប.ស.ក មុនៗ។ ការបណ្តុះបណ្តាលនេះទទួលបានលទ្ធផលតាមរយៈការបង្ហាញ/ហ៊ាននិយាយអំពីអំពើហិង្សាមានកម្រិតខ្ពស់។

## ៤.២. ភាពខុសគ្នានៃលក្ខណៈសំណាកគំរូកន្លងមក

អាយុ សាសនា លំនៅដ្ឋាន (ជនបទ/ទីប្រជុំជន) ស្ថានភាពអាពាហ៍ពិពាហ៍ និងរាជធានី / ខេត្ត នៃអ្នកចូលរួមដែលបានជ្រើសរើសសម្រាប់ការអង្កេត អ.ប.ស.ក ផ្នែកអំពើហិង្សាក្នុងគ្រួសារមានលក្ខណៈស្រដៀងគ្នាសម្រាប់អង្កេតដែលបានធ្វើកន្លងមក (ឆ្នាំ២០០០ ២០០៥ និង ២០១៤ ឧបសម្ព័ន្ធ "គ" តារាង "គ១")។

ចំពោះស្ត្រីដែលមានកូនម្នាក់ ឬពីរនៅក្នុងការអង្កេតឆ្នាំ២០១៤គឺមានភាគរយខ្ពស់ជាងឆ្នាំ ២០០០ (៥១.៩% ធៀបនឹង៣៣.៥%) ខណៈដែលនៅឆ្នាំ២០០០ អត្រាស្ត្រីដែលមានកូន៥នាក់ឡើង គឺមានភាគរយខ្ពស់ជាងឆ្នាំ២០១៤ (២៨.០% ធៀបនឹង១១.៥%)។ សម្រាប់កម្រិតសិក្សាអប់រំវិញ សំណាកគំរូសម្រាប់អង្កេតមានការប្រែប្រួលបន្តិចបន្តួចក្នុងពេលកន្លងមក។ នៅក្នុងឆ្នាំ ២០០០ ស្ត្រីមិនបានចូលរៀនមាន ៣១% (១៥.៣%នៅឆ្នាំ២០១៤) ចំណែកឯស្ត្រីនៅកម្រិតមធ្យមសិក្សា ឬខ្ពស់ជាងមាន១២.៧% (៣១.៦%នៅឆ្នាំ២០១៤)។ ស្ទើរតែពាក់កណ្តាលនៃស្ត្រីដែលបានចូលរួមការងារក្នុងឆ្នាំ២០០០ ប៉ុន្តែមិនទទួលបានជាប្រាក់ឈ្នួល។ នៅឆ្នាំ២០១៤ ស្ត្រីមានតែ៧.៣%ដែលចូលរួមការងារអង្កេត ហើយមិនទទួលបានប្រាក់ឈ្នួល ខណៈដែលស្ត្រីភាគច្រើន(៧៦.៦%) បានចូលរួមការងារអង្កេត ហើយទទួលបានប្រាក់ឈ្នួល ។

លក្ខណៈប្រជាសាស្ត្រលម្អិតនៃស្ត្រីធ្លាប់រៀបការហើយទទួលរងអំពើហិង្សាលើរាងកាយ ឬផ្លូវភេទដោយដៃគូស្និទ្ធស្នាលមានបង្ហាញនៅក្នុងតារាង "គ២" (ឧបសម្ព័ន្ធ "គ")។

ខណៈដែលអត្រាប្រេវ៉ាឡង់អំពើហិង្សាលើរាងកាយ ឬផ្លូវភេទក្នុងជីវិតដោយដៃគូបច្ចុប្បន្ន ឬថ្មីបំផុត តាមលក្ខណៈប្រជាសាស្ត្រមានលក្ខណៈស្រដៀងគ្នាសម្រាប់ អ.ប.ស.ក ឆ្នាំ២០០០ និង ២០១៤ ហើយមានកម្រិតទាបនៅឆ្នាំ២០០៥។ អត្រាប្រេវ៉ាឡង់អំពើហិង្សារាងកាយ ឬផ្លូវភេទដោយដៃគូស្និទ្ធស្នាលបច្ចុប្បន្ន ឬថ្មីបំផុតអំឡុងពេល១២ខែកន្លងមក តាមលក្ខណៈប្រជាសាស្ត្រនឹងបង្ហាញនៅក្នុងតារាង៤.២។ គួរកត់សម្គាល់ថា អត្រាប្រេវ៉ាឡង់ក្នុងជីវិតមានភាពខុសគ្នារវាងឆ្នាំ២០០៥ និង ២០១៤ ប៉ុន្តែអត្រាប្រេវ៉ាឡង់អំឡុងពេល១២ខែកន្លងមកមានលក្ខណៈស៊ីសង្វាក់គ្នា និងមានកម្រិតទាបជាងនៅឆ្នាំ២០០០។

**តារាង ៤.៣. លក្ខណៈប្រជាសាស្ត្រនៃស្ត្រីធ្លាប់រៀបការដែលទទួលរងអំពើហិង្សាលើរាងកាយ ឬផ្លូវភេទអំឡុងពេល១២ខែកន្លងមកដោយដៃគូបច្ចុប្បន្ន ឬថ្មីបំផុតផ្នែកអំពើហិង្សាក្នុងគ្រួសារនៃអ.ប.ស.ក ឆ្នាំ២០០០ ២០០៥ និង២០១៤**

| | ២០០០ | | ២០០៥ | | ២០១៤ | |
|---|---|---|---|---|---|---|
| | ចំនួន | % (មេគុណអង្កេត) | ចំនួន | % (មេគុណអង្កេត) | ចំនួន | % (មេគុណអង្កេត) |

| | | | | | | |
|---|---|---|---|---|---|---|
| អាយុ (ចន្លោះអាយុ១០ឆ្នាំ) | | | | | | |
| ១៥-១៩ | ៤ | ៤.០ | ៥ | ៧.៥ | ៨ | ៧.៣ |
| ២០-២៩ | ៩៩ | ១៦.២ | ៥៣ | ៨.៦ | ៩០ | ៨.៧ |
| ៣០-៣៩ | ១៥៩ | ១៦.៧ | ៧០ | ១០.១ | ១៥៤ | ១៣.៣ |
| ៤០-៤៩ | ១០៣ | ១៣.៩ | ៥៦ | ៨.៤ | ១០៣ | ១១.០ |
| ***ស្ថានភាពអាពាហ៍ពិពាហ៍*** | | | | | | |
| រៀបការ/រស់នៅជាមួយគ្នា | ៣០៧ | ១៤.៨ | ១៧២ | ៩.៦ | ៣២៣ | ១០.៩ |
| លែងលះ/រស់នៅបែកគ្នា | ៣០ | ១៧.៨ | ៩ | ៦.៩ | ២១ | ១៣.៦ |
| មេម៉ាយ/ពោះម៉ាយ | ៣០ | ១៣.៨ | ៤ | ៣.៧ | ១២ | ១០.៤ |
| ***លំនៅដ្ឋាន*** | | | | | | |
| ជនបទ | ៥៤ | ១៣.៩ | ១៩ | ៦.៣ | ២៧ | ៥.៥ |
| ទីប្រជុំជន | ៣១២ | ១៥.៥ | ១៦៥ | ៩.៥ | ៣២៨ | ១១.៩ |
| ***កម្រិតសិក្សាអប់រំ*** | | | | | | |
| មិនបានចូលរៀន | ១៣៣ | ១៧.៨ | ៥២ | ១០.១ | ៨៧ | ១៧.៥ |
| បឋមសិក្សា | ២០១ | ១៤.៩ | ១២១ | ១០.១ | ២១០ | ១២.២ |
| មធ្យមសិក្សា ឬខ្ពស់ជាង | ៣២ | ១០.៥ | ១១ | ៣.៣ | ៥៩ | ៥.៨ |
| ***ស្ថានភាពការងារ*** | | | | | | |
| ការងារទទួលបានសាច់ប្រាក់ | ១៣៨ | ១៥ | ៩៩ | ៩.៧ | ២៧៨ | ១១.២ |
| ការងារមិនទទួលបានសាច់ប្រាក់ | ១៦៤ | ១៤.៧ | ៦៥ | ៩.០ | ២៩ | ១២.២ |
| គ្មានការងារ | ៦៣ | ១៧.២ | ២០ | ៦.៩ | ៤៩ | ៩.៤ |
| ***ការចេះអាន*** | | | | | | |
| មិនអាចអានបានទាំងអស់ | ១៤៨ | ១៧.៧ | ៧០ | ៩.៦ | ១៦៣ | ១៧.៣ |
| អាចអានបានប្រយោគខ្លះៗ | ១០៣ | ១៦.៦ | ៣៦ | ១០.៧ | ៨៩ | ១២.៤ |
| អាចអានបានទាំងអស់ | ១១៤ | ១២.៣ | ៧៣ | ៧.៦ | ១០៣ | ៦.៥ |
| ងងឹតភ្នែក/ភ្នែកមើលមិនច្បាស់/ផ្សេងទៀត | ១៤ | ៨.៣ | ៥ | ៨៣.៣ | ១ | ៣៣.៣ |

## ៤.៣. និន្នាការអំពើហិង្សាលើដៃគូស្និទ្ធស្នាលក្នុងរយៈពេលកន្លងមក

ស្ត្រីដែលបានរាយការណ៍អំពីបទពិសោធន៍ទទួលរងអំពើហិង្សាលើផ្លូវភេទ ឬរាងកាយលើដៃគូស្និទ្ធស្នាលបច្ចុប្បន្ន ឬថ្មីបំផុតមានភាគរយតិចនៅឆ្នាំ២០០៥ បើធៀបនឹងឆ្នាំ២០០០ ឬ២០១៤។ សមាមាត្រស្ត្រីដែលបានរាយការណ៍អំពីបទពិសោធន៍ ទទួលរងអំពើហិង្សាលើរាងកាយ ឬ ផ្លូវភេទលើដៃគូស្និទ្ធស្នាលបច្ចុប្បន្ន ឬថ្មីបំផុតមានកម្រិតខ្ពស់នៅឆ្នាំ២០០០ ធៀបនឹងឆ្នាំ២០០៥ ឬ ២០១៤ អំឡុងពេល១២ខែកន្លងមក(រូបភាពទី៤.១)។ យើងអាចផ្តល់អនុសាសន៍ថា អត្រាប្រេវ៉ាឡង់អំពើហិង្សាលើរាងកាយ ឬផ្លូវភេទលើដៃគូស្និទ្ធស្នាលក្នុងជីវិតនៅឆ្នាំ២០០៥ មានភាពមិនប្រក្រតី។

អត្រាប្រេវ៉ាឡង់ក្នុងជីវិតមិនគួរមានភាពខុសគ្នាខ្លាំងក្នុងរយៈពេលកន្លងមក ដោយសារអ្នកដែលទទួលរងអំពើហិង្សាក្នុងជីវិតនៅឆ្នាំ២០០០ ក៏ទទួលរងបទសោធន៍អំពើហិង្សានៅឆ្នាំ២០០៥ និង ២០១៤ផងដែរ (សូមមើលប្រអប់ ២.១)។ ដូច្នេះ លទ្ធផលខុសគ្នាក្នុងឆ្នាំ២០០៥គឺផ្ទុយពីការរំពឹងទុកដែលមិនអាចបកស្រាយបាននៅឡើយ។

**រូបភាពទី ៤.១. ការប្រៀបធៀបអត្រាប្រេវ៉ាឡង់អំពើហិង្សាអំឡុងពេល១២ខែកន្លងមក និងក្នុងជីវិតចំពោះតែស្ត្រីធ្លាប់មានដៃគូស្និទ្ធស្នាលបច្ចុប្បន្ន ឬដៃគូថ្មីបំផុតនៃ អ.ប.ស.ក កម្ពុជា ២០០០, ២០០៥ និង ២០១៤[26]ដែលបង្ហាញតាមបន្ទាត់លំអៀង**




ការប្រៀបធៀបការប៉ាន់ប្រមាណប្រេវ៉ាឡង់នៅឆ្នាំ២០០០ និង២០១៤បានបង្ហាញយ៉ាងច្បាស់ថាការត្រួតស៊ីគ្នានៃគម្លាតភាពជឿជាក់នៃប្រេវ៉ាឡង់អំពើហិង្សាលើរាងកាយ / ឬផ្លូវភេទ អំពើហិង្សាលើរាងកាយ និងលើផ្លូវភេទក្នុងជីវិត។ ផ្ទុយមកវិញ ការប៉ាន់ប្រមាណប្រេវ៉ាឡង់នៃអំពើហិង្សាលើរាងកាយ / ឬផ្លូវភេទ និងអំពើហិង្សាលើរាងកាយអំឡុងពេល១២ខែកន្លងមក មិនបង្ហាញពីភាពត្រួតស៊ីគ្នាឡើយ។ រូបភាពទី ៤.១ បង្ហាញថាអត្រាប្រេវ៉ាឡង់នៃអំពើហិង្សាលើរាងកាយ / ឬផ្លូវភេទ និងអំពើហិង្សាទាំងពីរប្រភេទបញ្ចូលគ្នាដោយដៃគូស្និទ្ធស្នាលអំឡុងពេល១២ខែកន្លងមកមានការថយចុះ។ ការថយចុះនេះគឺបណ្តាលមកពីការថយចុះនៃប្រេវ៉ាឡង់អំពើហិង្សាលើរាងកាយពីដៃគូស្និទ្ធស្នាលអំឡុងពេល១២ខែកន្លងមក។

[26] បន្ទាត់លំអៀងបង្ហាញក្នុងរូបភាពនេះគឺជាគម្លាតភាពជឿជាក់សម្រាប់ប៉ាន់ប្រមាណអត្រាប្រេវ៉ាឡង់នៅក្នុងជីវិត និងអំឡុងពេល១២ខែកន្លងមក។ គម្លាតភាពជឿជាក់ផ្តល់នូវការប៉ាន់ស្មានពីតំលៃពិតដែលបានកំណត់នៃការប៉ាន់ប្រមាណប្រេវ៉ាឡង់ក្នុងជីវិត និងអំឡុងពេល១២ខែកន្លងមក។កន្លែងដែលត្រួតស៊ីគ្នានៃគម្លាតភាពជឿជាក់រវាងឆ្នាំ(ឧទាហរណ៍៖ ការប៉ាន់ប្រមាណរវាងឆ្នាំ២០០០ និង២០០៥ ឬឆ្នាំ២០០៥ និង២០១៤ ឬឆ្នាំ២០០០ និង២០១៤) ហើយចំណុចនេះបង្ហាញថាមិនមានភាពខុសគ្នានៅក្នុងការប៉ាន់ប្រមាណប្រេវ៉ាឡង់នៅឆ្នាំទាំងនេះ។

ស្ត្រីដែលបានរាយការណ៍អំពីបទពិសោធន៍អំពើងហិង្សាលើរាងកាយ ឬផ្លូវភេទពីដៃគូស្និទ្ធស្នាលអំឡុងពេល១២ខែកន្លងមកមានភាគរយទាបក្នុងចំណោមស្ត្រីទាំងអស់ដែលបានរាយការណ៍។ នៅឆ្នាំ២០០០ ៨៩% នៃស្ត្រីដែលបានរាយការណ៍ធ្លាប់បានទទួលរងអំពើហិង្សាលើរាងកាយ ឬផ្លូវភេទពីដៃគូស្និទ្ធស្នាលអំឡុងពេល១២ខែកន្លងមក បានថយចុះមក ៦៦% ក្នុងឆ្នាំ២០០៥ និង ៦០% ក្នុងឆ្នាំ២០១៤។ ការថយចុះនេះគឺបណ្តាលមកពីការថយចុះនៃអត្រាអំពើហិង្សាលើរាងកាយពីដៃគូស្និទ្ធស្នាលច្រើនជាងអំពើហិង្សាលើផ្លូវភេទ ខណៈដែលនិន្នាការនេះមានលក្ខណៈផ្ទុយគ្នាក្នុងឆ្នាំ២០១៤ ។ ទោះយ៉ាងណាក៏ដោយ កត្តានេះអាចបណ្តាលមកពីការបន្ថែមសំណួរផ្សេងទៀតដែលទាក់ទងអំពើហិង្សាលើដៃគូស្និទ្ធស្នាលក្នុងការអង្កេតឆ្នាំ២០១៤ ឬអាចមកពីការបណ្តុះបណ្តាលមន្ត្រីសម្ភាសន៍មានលក្ខណៈល្អប្រសើជាង ដែលជួយឱ្យស្ត្រីងាយស្រួលក្នុងការផ្តល់ចម្លើយអំពីអំពើហិង្សាលើផ្លូវភេទដែលធ្លាប់ជួបប្រទះ។

ប្រេវ៉ាឡង់អំពើហិង្សាផ្លូវភេទលើដៃគូស្និទ្ធស្នាល (ធ្លាប់ ឬអំឡុងពេល១២ខែកន្លងមក) មានកម្រិតទាបបំផុតជាងប្រេវ៉ាឡង់អំពើហិង្សាលើរាងកាយលើដៃគូស្និទ្ធស្នាល(រូបភាពទី៤.១)។ និន្នាការឆ្ពោះទៅរកការកាត់បន្ថយសមាមាត្រពីបទពិសោធន៍អំពើហិង្សាអំឡុងពេល១២ខែកន្លងមក ទៅបទពិសោធន៍ក្នុងជីវិតបានឆ្លុះបញ្ចាំងឱ្យឃើញពីកំណើននៃស្ត្រីដែលទទួលរងអំពើហិង្សាអាចមានវិធានក្នុងការបញ្ឈប់រាល់ទម្រង់នៃអំពើហិង្សា ឬបានចាកចេញពីទំនាក់ទំនងអំពើហិង្សា។

**រូបភាពទី៤.២ ផលធៀបសមាមាត្រស្ត្រីធ្លាប់មានដៃគូស្និទ្ធស្នាលដែលទទួលរងអំពើហិង្សាលើរាងកាយ ផ្លូវភេទលើរាងកាយឬផ្លូវភេទអំឡុងពេល១២ខែកន្លងមកធៀបនឹងសមាមាត្រស្ត្រីធ្លាប់ទទួលរងអំពើហិង្សានេះក្នុងជីវិតនៃអ.ប.ស.ក២០០០ ២០០៥ និង២០១៤**




ទិន្នន័យនេះបង្ហាញថាមានការថយចុះអត្រាប្រេវ៉ាឡង់នៃអំពើហិង្សាលើរាងកាយលើដៃគូស្និទ្ធស្នាលអំឡុងពេល១២ខែកន្លងមកសម្រាប់ស្ត្រីក្នុងប្រទេសកម្ពុជា។ តាមរយៈលទ្ធផលនេះ យើងមិន

អាចកំណត់អំពីកត្តាអ្វីខ្លះដែលនាំឱ្យមានការផ្លាស់ប្តូរនេះបានទេ។ របកគំហើញពីការស្រាវជ្រាវអន្តរជាតិផ្សេងៗទៀតបង្ហាញថា ការរកប្រាក់ចំណូលបានផ្ទាល់ខ្លួនជាកត្តាជៀសផុតពីអំពើហិង្សាដែលប្រព្រឹត្តដោយដៃគូនៅក្នុងប្រទេសអភិវឌ្ឍន៍។ ជាការពិត ការប្រៀបធៀបសំណាកគំរូផ្នែកអំពើហិង្សាក្នុងគ្រួសារឆ្នាំ២០០០ និង២០១៤បានបង្ហាញថា សមាមាត្រស្ត្រីដែលចូលរួមក្នុងការអង្កេតឆ្នាំ២០១៤ជាអ្នកមានការងារដែលទទួលប្រាក់ឈ្នួលមានកម្រិតខ្ពស់ (ជាងអ្នកមានការងារដែលមិនទទួលប្រាក់ឈ្នួល)។ លើសពីនេះទៀត ស្ត្រីក្នុងសំណាកគំរូឆ្នាំ២០១៤មានកម្រិតសិក្សាប្រសើរជាងឆ្នាំ២០០០។ ដូចគ្នានេះផងដែរ តាមការស្រាវជ្រាវកម្រិតអន្តរជាតិ (បង្ហាញនៅក្នុងផ្នែកទី៣) បានបង្ហាញថា ការបង្កើនការអប់រំ និងអក្ខរកម្មបានជួយលើកកម្ពស់ភាពអង់អាចដល់ស្ត្រី និងកាត់បន្ថយអំពើហិង្សាលើដៃគូស្និទ្ធស្នាលនាពេលបច្ចុប្បន្ន។ ការសិក្សាបន្ថែមទៀតគួរស្វែងយល់ និងកំណត់ថាតើនិន្នាការវិជ្ជមានក្នុងការបង្កើនកម្រិតសិក្សាអប់រំ និងការងារអាចឆ្លុះបញ្ចាំងទៅរកការផ្លាស់ប្តូរក្នុងចំណោមស្ត្រីក្នុងប្រទេសកម្ពុជា ឬតើការផ្លាស់ប្តូរទាំងនេះត្រូវបានកំណត់នៅក្នុងការជ្រើសរើសសំណាកគំរូផ្នែកអំពើហិង្សាក្នុងគ្រួសារ។

## ៤.៤. សូចនាករ

ការប្រមូលទិន្នន័យជាទៀងទាត់ស្តីពីអំពើហិង្សាលើដៃគូស្និទ្ធស្នាលតាមរយៈការអង្កេត អ.ប.ស.កផ្នែកអំពើហិង្សាក្នុងគ្រួសារនឹងជួយក្នុងការរាយការណ៍ និងការតាមដានត្រួតពិនិត្យលើសូចនាករជាតិ និងអន្តរជាតិដែលបានកំណត់។

### គោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពរបស់អង្គការសហប្រជាជាតិ

គោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពរបស់អង្គការសហប្រជាជាតិបានកំណត់សូចនាករពីរដើម្បីវាស់វែងពីផលប៉ះពាល់ក្នុងការកាត់បន្ថយអំពើហិង្សាលើស្ត្រី (ក្នុងនោះ អំពើហិង្សាលើដៃគូស្និទ្ធស្នាលជាផ្នែកមួយដ៏សំខាន់)។ សូចនាករ ៥.២.១ *"សមាមាត្រស្ត្រីធ្លាប់មានដៃគូស្និទ្ធស្នាល និងក្មេងស្រីអាយុ១៥ឆ្នាំឡើងទទួលរងអំពើហិង្សាលើរាងកាយ ផ្លូវភេទ ផ្លូវចិត្តពីដៃគូស្និទ្ធស្នាលបច្ចុប្បន្ន ឬអតីតអំឡុងពេល១២ខែកន្លងមក បែងចែកតាមទម្រង់អំពើហិង្សា និងក្រុមអាយុ"* នឹងបង្ហាញក្នុងតារាង៤.៤។

**តារាង ៤.៤. សមាមាត្រនៃស្ត្រីធ្លាប់មានដៃគូ និងក្មេងស្រីអាយុ១៥ឆ្នាំឡើងទទួលរងអំពើហិង្សាលើរាងកាយ ផ្លូវភេទ ឬផ្លូវចិត្តពីដៃគូស្និទ្ធស្នាលបច្ចុប្បន្ន ឬអតីតអំឡុងពេល១២ខែកន្លងមក បែងចែកតាមទម្រង់នៃអំពើហិង្សា និងក្រុមអាយុ**

| ក្រុមអាយុ | ២០០០ | | | ២០០៥ | | | ២០១៤ | | |
|---|---|---|---|---|---|---|---|---|---|
| | រាងកាយ | ផ្លូវភេទ | ផ្លូវចិត្ត | រាងកាយ | ផ្លូវភេទ | ផ្លូវចិត្ត | រាងកាយ | ផ្លូវភេទ | ផ្លូវចិត្ត |
| ១៥-១៩ | ៤.០ | ១.០ | ៣.០ | ៦.០ | ១.៥ | ១៣.៦ | ៦.៥ | ១.៩ | ១៣.០ |
| ២០-២៤ | ១០.៧ | ៣.១ | ៦.១ | ៨.៦ | ១.៧ | ១៣.២ | ៧.៤ | ៣.៩ | ១២.១ |
| ២៥-២៩ | ១៨.៦ | ៣.៧ | ៧.៧ | ៧.៤ | ១.៩ | ១៣.១ | ៦.១ | ៣.៦ | ១៣.៥ |

| | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|
| ៣០-៣៤ | ១៦.០ | ៣.៤ | ៧.១ | ១០.៧ | ០.៩ | ១៤.៨ | ១១.៧ | ៣.៦ | ១៨.៨ |
| ៣៥-៣៩ | ១៦.២ | ៣.៥ | ៩.២ | ៨.៩ | ១.៣ | ១៣.៧ | ១១.១ | ៥.១ | ២០.៩ |
| ៤០-៤៤ | ១០.៣ | ១.៨ | ៧.២ | ៧.៥ | ១.៨ | ១៣.៥ | ៩.៨ | ៣.៥ | ២០.៦ |
| ៤៥-៤៩ | ១៦.៧ | ៤.២ | ៩.៩ | ៧.៥ | ២.៥ | ១៥.៤ | ១០.៣ | ៤.៩ | ១៨.៩ |

សូចនាករអំពើហិង្សាលើស្ត្រី ៥.២.២ "*សមាមាត្រស្ត្រី និងក្មេងស្រីអាយុ១៥ឆ្នាំឡើងធ្លាប់រងអំពើហិង្សាលើផ្លូវភេទប្រព្រឹត្តដោយអ្នកក្រៅពីដៃគូស្និទ្ធស្នាលអំឡុងពេល១២ខែកន្លងមកតាមទម្រង់នៃអំពើហិង្សា ក្រុមអាយុ និងទីកន្លែងកើតហេតុ*"។ ការអង្កេត អ.ប.ស.ក ផ្នែកអំពើហិង្សាក្នុងគ្រួសារឆ្នាំ២០១៤គឺជាការអង្កេតដំបូងដែលបានប្រមូលព័ត៌មានពីអំពើហិង្សាលើផ្លូវភេទដែលបង្កឡើងដោយអ្នក ក្រៅពីដៃគូ ហើយមានតែ០.១% នៃស្ត្រីបានរាយការណ៍ថាធ្លាប់ទទួលរងអំពើហិង្សាលើផ្លូវភេទបង្កឡើងដោយអ្នកក្រៅពីដៃគូអំឡុងពេល១២ខែកន្លងមក ។ ចំនួននេះតិចតួចបំផុតក្នុងការបំបែកតាមក្រុមអាយុ និងទីកន្លែងកើតហេតុ។

## ផែនការសកម្មភាពជាតិស្តីពីការទប់ស្កាត់អំពើហិង្សាលើស្ត្រី

ក្នុងផែនការសកម្មភាពជាតិស្តីពីការទប់ស្កាត់អំពើហិង្សាលើស្ត្រីរបស់រាជរដ្ឋាភិបាលកម្ពុជា យុទ្ធសាស្ត្រទី៥បានផ្តោតលើការពិនិត្យឡើងវិញ ការតាមដានត្រួតពិនិត្យនិងវាយតម្លៃសកម្មភាពត្រូវអនុវត្តន៍ដើម្បីតាមដានលើបទពិសោធន៍ទទួលរងអំពើហិង្សារបស់ស្ត្រីនៅប្រទេសកម្ពុជា។
ផែនការសកម្មភាពនេះនឹងបង្ហាញក្នុងប្រអប់ ៤.១។

សកម្មភាពដែលបានរៀបរាប់ក្នុងរបាយការណ៍នេះ គឺឆ្លើយតបទៅនឹងបញ្ជីសូចនាករនៃលទ្ធផលរំពឹងទុក។ ដូចបានបង្ហាញនៅក្នុងរបាយការណ៍នេះ ការអង្កេតអ.ប.ស.ក និងការស្រាវជ្រាវប្រេវ៉ាឡង់របស់អង្គការសុខភាពពិភពលោកនាពេលថ្មីៗនេះធ្វើឡើងដោយផ្អែកតាមបទដ្ឋានអន្តរជាតិដែលតម្រូវឱ្យមានការបណ្តុះបណ្តាលស៊ីជម្រៅដល់មន្ត្រីដែលធ្វើការសម្ភាសន៍។ លើសពីនេះទៀតការវិភាគទិន្នន័យលម្អិតនេះនឹងផ្តល់ការស្វែងយល់បន្ថែមទៅលើលទ្ធផល ដែលមានក្នុងអ.ប.ស.ក ដើម្បីផ្តល់ភាពងាយស្រួលក្នុងការរៀបចំគោលនយោបាយក្នុងការកាត់បន្ថយអំពើហិង្សាលើស្ត្រី នៅប្រទេសកម្ពុជា។

**ប្រអប់ ៤.១. សូចនាករលទ្ធផលរំពឹងទុក ១៨.២**

- ការស្រាវជ្រាវអំពីប្រេវ៉ាឡង់អន្តរប្រទេសដោយអង្គការសុខភាពពិភពលោក, ការសិក្សាអំពីប្រេវ៉ាឡង់អំពើហិង្សាលើកុមារ និងការអង្កេត អ.ប.ស.ក ២០១៤ដែលបានបោះពុម្ព និងផ្សព្វផ្សាយជាផ្លូវការ
- ការសិក្សាអំពីប្រេវ៉ាឡង់ដែលស្របតាមបទដ្ឋានជាតិ និងអន្តរជាតិ
- លទ្ធផល និងអនុសាសន៍ការអង្កេតប្រេវ៉ាឡង់ត្រូវបានពិភាក្សាក្នុងក្រុមការងារបច្ចេកទេសយេនឌ័រៈ អំពើហិង្សាទាក់ទងនឹងយេនឌ័រ (TWGG-GBV)

# ផ្នែកទី ៥

## ៥. ការប្រៀបធៀបលទ្ធផលនៃអ.ប.ស.ក និងការស្រាវជ្រាវរបស់អង្គការសុខភាពពិភពលោកស្តីពីប្រេវ៉ាឡង់អំពើហិង្សាលើរាងកាយ ឬផ្លូវភេទលើដៃគូ

ក្នុងឆ្នាំ២០១៥ អង្គការសុខភាពពិភពលោក (WHO) បានធ្វើការស្រាវជ្រាវស្តីពីអំពើហិង្សាលើស្ត្រីនៅប្រទេសកម្ពុជា។ ការស្រាវជ្រាវរបស់អង្គការសុខភាពពិភពលោក បានប្រើប្រាស់វិធីសាស្ត្រអង្កេតស្រដៀងគ្នានឹង អ.ប.ស.ក ផ្នែកអំពើហិង្សាក្នុងគ្រួសារដែលមានភាពងាយស្រួលក្នុងការប្រៀបធៀបប៉ាន់ប្រមាណប្រេវ៉ាឡង់អំពើហិង្សាលើដៃគូស្និទ្ធស្នាលក្នុងអ.ប.ស.ក។ រូបភាពទី ៥.១ បង្ហាញពីការប្រៀបធៀបការប៉ាន់ប្រមាណអំពើហិង្សាលើរាងកាយ ឬផ្លូវភេទលើដៃគូក្នុងជីវិត។ លទ្ធផលនៃការអង្កេតទាំងពីរបានបង្ហាញថា ស្ត្រីកម្ពុជាប្រមាណ១នាក់ ក្នុងចំណោម៥នាក់ធ្លាប់ទទួលរងអំពើហិង្សាលើរាងកាយ ឬផ្លូវភេទក្នុងជីវិតពីដៃគូស្និទ្ធស្នាលណាម្នាក់។ ចំណែកឯ ការស្រាវជ្រាវរបស់អង្គការសុខភាពពិភពលោកបង្ហាញថា ស្ត្រីដែលធ្លាប់ទទួលរងអំពើហិង្សាលើរាងកាយពីដៃគូស្និទ្ធស្នាលណាម្នាក់អំឡុងពេល១២ខែកន្លងមកមានភាគរយទាប ហើយស្ត្រីដែលធ្លាប់ទទួលរងអំពើហិង្សាផ្លូវភេទពីដៃគូស្និទ្ធស្នាលមានភាគរយខ្ពស់ជាងការអង្កេតអ.ប.ស.ក។

ចំណុចសំខាន់មួយទៀត គឺការប្រៀបធៀបភាគរយស្ត្រីធ្លាប់ទទួលរងអំពើហិង្សាក្នុងជីវិតពីដៃគូស្និទ្ធស្នាលអំឡុងពេល១២ខែកន្លងមក នៃការស្រាវជ្រាវរបស់អង្គការសុខភាពពិភពលោក និង អ.ប.ស.ក។ ទិន្នន័យពីអ.ប.ស.ក ឆ្នាំ២០១៤បង្ហាញថា ស្ត្រីជាងពាក់កណ្តាល (៥៥%) ធ្លាប់ទទួលរងអំពើហិង្សាលើរាងកាយក្នុងជីវិតពីដៃគូស្និទ្ធស្នាល បានទទួលរងអំពើហិង្សាអំឡុងពេល១២ខែកន្លងមកផងដែរ ។ ផ្ទុយទៅវិញ ស្ត្រីតែមួយភាគបី (៣៨%) ធ្លាប់បានទទួលរងអំពើហិង្សាលើរាងកាយក្នុងជីវិតពីដៃគូស្និទ្ធស្នាលបានរាយការណ៍ ពីការទទួលរងអំពើហិង្សានេះអំឡុងពេល១២ខែកន្លងមកនេះ នៅក្នុងការស្រាវជ្រាវរបស់អង្គការសុខភាពពិភពលោកឆ្នាំ ២០១៥ ។ ភាពខុសគ្នានៃការប៉ាន

ប្រមាណប្រេវ៉ាឡង់រវាងការអង្កេតទាំងពីរអាចបណ្តាលមកពីភាពខុសគ្នាតិចតួច នៃលក្ខណៈសំណាកគំរូ។ ឧទាហរណ៍៖ លទ្ធផល អ.ប.ស.ក បង្ហាញថាទិន្នន័យស្ត្រីធ្លាប់ទទួលរងអំពើហិង្សាលើរាងកាយក្នុងជីវិតពីដៃគូអំឡុងពេល១២ខែកន្លងមក នៅទីប្រជុំជន (៣៨%) មានភាគរយទាបជាងស្ត្រីនៅជនបទ(៦០%) (ឧបសម្ព័ន្ធ "ក" តារាង ក៤)។

**រូបភាពទី ៥.១. អត្រាប្រេវ៉ាឡង់អំពើហិង្សាលើរាងកាយ ឬផ្លូវភេទ៖ ប្រៀបធៀបលទ្ធផល អ.ប.ស.ក ២០១៤ និងការស្រាវជ្រាវប្រេវ៉ាឡង់ថ្នាក់ជាតិ (អង្គការសុខភាពពិភពលោក ឆ្នាំ២០១៥)**




យោងតាមការប្រៀបធៀបលទ្ធផល អ.ប.ស.ក និងអង្គការសុខភាពពិភពលោក Jansen សង្កេតឃើញថា ទោះបីអត្រាប្រេវ៉ាឡង់អំពើហិង្សាលើរាងកាយ និងផ្លូវភេទក្នុងជីវិតពីដៃគូមានភាពស្រដៀងគ្នារវាងការស្រាវជ្រាវរបស់អង្គការសុខភាពពិភពលោក និងអ.ប.ស.កក៏ដោយ ក៏នៅតែមានភាពខុសគ្នាខ្លះៗរវាងអត្រាអំពើហិង្សាលើរាងកាយ និងផ្លូវភេទ បើយោងតាមការវាស់វែងនៃការអង្កេតនីមួយៗ ។ ការវាស់វែងអំពើហិង្សាលើរាងកាយពីដៃគូក្នុងអ.ប.ស.ក មានអត្រាខ្ពស់ជាង (១៦.២% អ.ប.ស.ក ធៀបនឹង ១៥% អង្គការសុខភាពពិភពលោក)។ ចំណែកឯ អំពើហិង្សាលើផ្លូវភេទវាស់វែងដោយអ.ប.ស.ក មានអត្រាទាបជាង(៥.៥%អ.ប.ស.ក ធៀបនឹង៩.៨% អង្គការសុខភាពពិភពលោក) ។ ភាពខុសគ្នានេះ អាចបណ្តាលមកពីការប្រើពាក្យខុសគ្នានៅក្នុងកម្រងសំណួរអង្កេតទាំងពីរ ។ អំពើហិង្សាលើផ្លូវភេទត្រូវបានវាស់វែងដោយកម្រងសំណួររបស់អង្គការសុខភាពពិភពលោកទាក់ទងជាមួយនឹងការបង្ខិតបង្ខំរួមភេទ និងធ្វើសកម្មភាពផ្លូវភេទ ចំណែកឯ អ.ប.ស.ក វាស់វែងពីការប្រើកម្លាំងបង្ខិតបង្ខំឱ្យរួមភេទ និងធ្វើសកម្មភាពផ្លូវភេទ (ពោល គឺ អំពើហិង្សាលើរាងកាយបានពាក់ព័ន្ធភាគច្រើនទៅនឹងអំពើហិង្សាលើផ្លូវភេទត្រូវបានវាស់វែងដោយ អ.ប.ស.ក ដោយសារតែអ្នកឆ្លើយតបបានរាយការណ៍ថា ត្រូវបានប្រើកម្លាំបង្ខិតបង្ខំឱ្យរួមភេទ។ ទាំងនេះបានបង្ហាញពីភាពត្រួតស៊ីគ្នានៃអំពើហិង្សាលើរាងកាយ និងផ្លូវភេទពីដៃគូស្និទ្ធស្នាលដែលបានវាស់វែងក្នុងអង្កេតនីមួយៗ(រូបភាពទី៥.២)។ រូបភាពទី៥.២ក. បង្ហាញពីភាពត្រួតស៊ីគ្នានៃអំពើហិង្សាលើរាងកាយ និង ផ្លូវភេទក្នុងជីវិតពីដៃគូស្និទ្ធស្នាលវាស់វែងដោយអង្គការសុខភាពពិភពលោក។ រូបភាពទី៥.២ខ បង្ហាញពីភាពត្រួតស៊ីគ្នានៃអំពើហិង្សាលើរាងកាយ និងផ្លូវភេទក្នុងជីវិតពីដៃគូស្និទ្ធស្នាល វាស់វែងដោយ អ.ប.ស.ក ឆ្នាំ២០១៤។ រូបភាពនេះក៏បង្ហាញផងដែរថា ក្នុងចំណោមស្ត្រីដែលធ្លាប់ទទួលរងអំពើហិង្សាលើរាងកាយ ផ្លូវភេទ ឬអំពើហិង្សាលើរាងកាយ និងផ្លូវភេទ

សមាមាត្រស្ត្រីរាយការណ៍អំពីអំពើហិង្សាលើផ្លូវភេទក្នុងការអង្កេតរបស់អង្គការសុខភាពពិភពលោក មានកម្រិតខ្ពស់ជាងនៅក្នុងអង្កេតអ.ប.ស.ក។

**រូបភាពទី៥.២ក. ភាពត្រួតស៊ីគ្នានៃអំពើហិង្សាលើរាងកាយ និងផ្លូវភេទក្នុងជីវិតពីដៃគូស្និទ្ធស្នាលក្នុងចំណោមស្ត្រីធ្លាប់មានដៃគូដែលបានរាយការណ៍ថាធ្លាប់ទទួលរងអំពើហិង្សាលើរាងកាយ និង/ឬផ្លូវភេទពីដៃគូស្និទ្ធស្នាល (អង្គការសុខភាពពិភពលោក ឆ្នាំ២០១៥)[27]**




**រូបភាពទី ៥.២ខ. ភាពត្រួតស៊ីគ្នានៃអំពើហិង្សាលើរាងកាយ និងផ្លូវភេទពីដៃគូស្និទ្ធស្នាលក្នុងជីវិតក្នុងចំណោមស្ត្រីធ្លាប់មានដៃគូដែលបានរាយការណ៍ថាធ្លាប់ទទួលរងអំពើហិង្សាលើរាងកាយ និង/ឬផ្លូវភេទ ពីដៃគូស្និទ្ធស្នាល(អ.ប.ស.ក ឆ្នាំ២០១៤)**




ដូចដែល Jansen បានបញ្ជាក់ការប៉ាន់ប្រមាណអត្រាប្រេវ៉ាឡង់នៃបទពិសោធន៍អំពើហិង្សាដែលបានរាយការណ៍គឺទទួលបានតែកម្រិតអប្បបរមាប៉ុណ្ណោះ[28]។

[27] ក្រសួងកិច្ចការនារីកម្ពុជា, ការស្រាវជ្រាវថ្នាក់ជាតិស្តីពីសុខភាព និងបទពិសោធន៍ក្នុងជីវិតរបស់ស្ត្រីនៅប្រទេសកម្ពុជា២០១៥, អង្គការសុខភាពពិភពលោក, UN Women Cambodia, រាជរដ្ឋាភិបាលកម្ពុជា. Accessed from http://asiapacific.unwomen.org/en/digital-library/publications/2015/11/national-survey-on-women-s-health-and-life-experiences-in-cambodia#view ១២ កក្កដា ២០១៦។

[28] Jansen, H. A. F. M. 2015 អំពើហិង្សាលើរាងកាយនិង/ឬផ្លូវភេទលើដៃគូនៅប្រទេសកម្ពុជា ២០០០ -២០០៥-២០១៤/15. រាជធានីភ្នំពេញ ខែវិច្ឆិកា ២០១៥។ ការិយាល័យ UNFPA អាស៊ី និងប៉ាស៊ីហ្វិក។

ការប្រៀបធៀបជាមួយការស្រាវជ្រាវរបស់អង្គការសុខភាពពិភពលោកបានបន្ថែមការយល់ដឹងកាន់តែប្រសើរនូវចំណុចមួយចំនួននៃការស្វែងរកជំនួយក្នុងការប្រមូលព័ត៌មានហាក់មានកំណត់នៅក្នុងការអង្កេត អ.ប.ស.ក។ ដូចបង្ហាញក្នុងតារាង "២៤" ស្ត្រី៤២.៦%ធ្លាប់ទទួលរងអំពើហិង្សានៅក្នុងការអង្កេត អប.ស.ក (ដោយដៃគូ ឬនរណាម្នាក់ផ្សេងទៀត)បានរាយការណ៍ថាទៅស្វែងរកជំនួយ ហើយស្ត្រី១៨.៨%បានរាយការណ៍ថាពួកគេមិនបានទៅស្វែងរកជំនួយ ប៉ុន្តែបានប្រាប់ទៅអ្នកផ្សេងទៀត ។ ក្នុងការអង្កេតរបស់អង្គការសុខភាពពិភពលោក ស្ត្រី៥១%ដែលធ្លាប់ទទួលរងអំពើហិង្សាលើរាងកាយ ឬផ្លូវភេទពីដៃគូស្និទ្ធស្នាលបានប្រាប់ទៅអ្នកផ្សេងទៀតអំពីអំពើហិង្សាដែលខ្លួនធ្លាប់ជួបប្រទះ។ ក្នុងចំណោមស្ត្រីដែលធ្លាប់ទទួលរងអំពើហិង្សាលើរាងកាយ ឬផ្លូវភេទពីដៃគូស្និទ្ធស្នាលក្នុងការអង្កេតរបស់អង្គការសុខភាពពិភពលោក ស្ត្រី៤៧% បានរាយការណ៍ថាមានអ្នកផ្សេងទៀតបានព្យាយាមជួយពួកគេ ។ ភាពខុសគ្នានៃការរាយការណ៍ពីឥរិយាបថស្វែងរកជំនួយគឺពាក់ព័ន្ធមួយផ្នែកទៅនឹងប្រើភាគបែងខុសគ្នាដើម្បីគណនាភាគរយ។ ក្នុង អ.ប.ស.ក ស្ត្រីទាំងអស់ដែលធ្លាប់ទទួលរងអំពើហិង្សាត្រូវបានប្រើជាភាគបែងសម្រាប់គណនា ខណៈការអង្កេតរបស់អង្គការសុខភាពពិភពលោកប្រើប្រាស់តែលើស្ត្រីដែលធ្លាប់ទទួលរងអំពើហិង្សាលើរាងកាយ ឬ ផ្លូវភេទពីដៃគូស្និទ្ធស្នាលប៉ុណ្ណោះ ។ ប្រសិនបើ ការវិភាគទិន្នន័យតែលើស្ត្រីដែលធ្លាប់ទទួល រងអំពើហិង្សាលើរាងកាយ ឬផ្លូវភេទពីដៃគូស្និទ្ធស្នាល ស្ត្រីដែលស្វែងរកជំនួយក្នុង អ.ប.ស.ក មាន ៥១%។

ទិន្នន័យស្តីពីការស្វែងរកជំនួយមានភាពស្រដៀងគ្នា រវាងការអង្កេតរបស់អង្គការសុខភាពពិភពលោក និងអ.ប.ស.ក។ ប្រភពនៃការស្វែងរកជំនួយភាគច្រើនគឺពីសមាជិកគ្រួសារ។ ក្នុងការអង្កេតទាំងពីរ ប្រភពនៃការស្វែងរកជំនួយភាគច្រើន គឺពីសមាជិកគ្រួសារ ។ ការស្វែងរកជំនួយពីសេវាគាំទ្រជាផ្លូវការមានតិចតួចបំផុត។ ក្នុងចំណោមជំនួយពីសេវាគាំទ្រជាផ្លូវការ ការរកជំនួយពីនគរបាលគឺច្រើនជាងសេវាគាំទ្រជាផ្លូវការផ្សេងទៀត។ លទ្ធផលនេះមិនបានបញ្ជាក់ពីសារៈសំខាន់នៃកម្លាំងនគរបាល ដែលទទួលបានការបណ្តុះបណ្តាលគ្រប់គ្រាន់ ដើម្បីធានាថាពួកគេអាចផ្តល់នូវសេវាគាំទ្រសមស្របនៅពេលមានអំពើហិង្សាលើរាងកាយ និងឬ ផ្លូវភេទពីដៃគូស្និទ្ធស្នាលកើតឡើង។

រូបភាពទី៥.៣ បង្ហាញការបកស្រាយអំពីមូលហេតុស្វែងរក និងមិនស្វែងរកជំនួយក្នុងការអង្កេតរបស់អង្គការសុខភាពពិភពលោក២០១៥។ មូលហេតុភាគច្រើននៃការស្វែងរកជំនួយ គឺស្ត្រីមិនអាចទ្រាំបាននឹងអំពើហិង្សា។ ផ្ទុយមកវិញ មូលហេតុភាគច្រើននៃអ្នកមិនបានស្វែងរកជំនួយដោយសារពួកគេគិតថាអំពើហិង្សាកើតឡើងជារឿងធម្មតា មិនធ្ងន់ធ្ងរ ឬភាពអៀនខ្មាស ឬអាមាស់។

ការរកឃើញទាំងនេះបានឆ្លុះបញ្ចាំងពីសារៈសំខាន់ដែលទាក់ទងនឹងបទដ្ឋានសង្គមក្នុងការទទួលយកអំពើហិង្សាក្នុងទំនាក់ទំនងដៃគូស្និទ្ធស្នាល។

**តារាង៥.១. មូលហេតុនៃការស្វែងរកជំនួយ និងមិនស្វែងរកជំនួយចំពោះស្ត្រីដែលធ្លាប់ទទួលរងអំពើហិង្សាលើរាងកាយ ឬផ្លូវភេទពីដៃគូស្និទ្ធស្នាលក្នុងការអង្កេតរបស់អង្គការសុខភាពពិភពលោក ឆ្នាំ២០១៥[29]**

| មូលហេតុនៃការស្វែងរកជំនួយ (ចំនួន=១៥៣) | ចំនួន | % | មូលហេតុមិនស្វែងរកជំនួយ (ចំនួន=៤៨១) | ចំនួន | % |
|---|---|---|---|---|---|
| មានការលើកទឹកចិត្តពីមិត្តភក្តិ/គ្រួសារ | ៣៧ | ២៤.២ | មិនដឹង | ៥៩ | ១២.៣ |
| មិនអាចទ្រាំតទៅទៀត | ៧៥ | ៤៩ | ភ័យខ្លាចការគំរាមកំហែង/ផលវិបាក | ៣០ | ៦.២ |
| រងរបួសយ៉ាងធ្ងន់ធ្ងរ | ១៩ | ១២.៤ | អំពើហិង្សាធម្មតា/មិនធ្ងន់ធ្ងរ | ១៩៣ | ៤០.១ |
| គំរាមសម្លាប់នាង | ១៥ | ៩.៨ | ខ្មាស់គេ/ខ្មាស់អៀន | ១៣៩ | ២៨.៩ |
| ឃើញកុមាររងទុក្ខវេទនា | ២៨ | ១៨.៣ | ការភ័យខ្លាចមានការផ្តាច់ទំនាក់ទំនង | ២៩ | ៦.០ |
| ដេញចេញពីផ្ទះ | ៨ | ៥.២ | ការភ័យខ្លាចបាត់បង់កូន | ៥៨ | ១២.១ |
| ខ្លាចនាងសម្លាប់ប្តី/ដៃគូ | ៦ | ៣.៩ | នាំឈ្មោះអាក្រក់ចូលគ្រួសារ | ៤៤ | ៩.១ |
| ខ្លាចប្តី/ដៃគូសម្លាប់នាង | ១៧ | ១១.១ | មិនដឹងថាជ្រើសរើសអ្វី | ៥ | ១.០ |
| ខ្លាចប្តី/ដៃគូវាយ ឬប្រើអំពើហិង្សាលើនាងទៀត | ៣៦ | ២៣.៥ | ផ្សេងៗ | ៥៨ | ១២.១ |

[29]ក្រសួងកិច្ចការនារីកម្ពុជា, ការស្រាវជ្រាវថ្នាក់ជាតិស្តីពីសុខភាព និងបទពិសោធន៍ក្នុងជីវិតរបស់ស្ត្រីនៅប្រទេសកម្ពុជា២០១៥, អង្គការសុខភាពពិភពលោក, UN Women Cambodia, រាជរដ្ឋាភិបាលកម្ពុជា. Accessed from http://asiapacific.unwomen.org/en/digital-library/publications/2015/11/national-survey-on-womens-health-and-life-experiences-in-cambodia#view ១២ កក្កដា ២០១៦។

# ផ្នែកទី ៦

## ៦. យោបល់ និងអនុសាសន៍ទាក់ទងនឹងគោលនយោបាយ

ទិន្នន័យនៅក្នុងរបាយការណ៍នេះ គឺជាការវិភាគទិន្នន័យដែលមានស្រាប់នៃការអង្កេត អ.ប.ស.ក ២០១៤ លើផ្នែកអំពើហិង្សាក្នុងគ្រួសារ រួមទាំងការវិភាគពីនិន្នាការនៃអំពើហិង្សាលើដៃគូស្និទ្ធស្នាល ដោយប្រើប្រាស់ទិន្នន័យពី អ.ប.ស.ក ឆ្នាំ២០០០ ២០០៥ និង២០១៤។ ជារួមលទ្ធផលនៃការវិភាគនេះនឹងបំពេញបន្ថែមនូវតម្រូវការក្នុងការអនុវត្តផែនការសកម្មភាពជាតិស្តីពីការទប់ស្កាត់អំពើហិង្សាលើស្ត្រីដែលរៀបចំដោយក្រសួងកិច្ចការនារី និងអនុម័តដោយកិច្ចប្រជុំពេញអង្គរបស់គណៈរដ្ឋមន្ត្រីនៅថ្ងៃទី ៥ខែ ធ្នូ ឆ្នាំ២០១៤។ ស្ត្រីនៅក្នុងប្រទេសជាង ៣០% ធ្លាប់ទទួលរងអំពើហិង្សាលើរាងកាយ ផ្លូវភេទ ឬផ្លូវចិត្តក្នុងជីវិតពីដៃគូស្និទ្ធស្នាល។ ស្ត្រីស្ទើរម្នាក់ក្នុងចំណោមស្ត្រី ៥នាក់ (១៩.៦%) នៃស្ត្រីកម្ពុជាធ្លាប់ទទួលរងអំពើហិង្សាលើរាងកាយ ផ្លូវភេទ ឬផ្លូវចិត្តពីដៃគូស្និទ្ធស្នាលអំឡុងពេល១២ខែកន្លងមកនៃអ.ប.ស.កឆ្នាំ២០១៤ ។ អំពើហិង្សាពីដៃគូស្និទ្ធស្នាលនៅតែជាបញ្ហាសុខភាពយ៉ាងសំខាន់សម្រាប់ស្ត្រីនៅប្រទេសកម្ពុជា។

លទ្ធផលដែលបានបង្ហាញក្នុងរបាយការណ៍នេះ បានបញ្ចូលនូវទិន្នន័យដែលបានពិពណ៌នាក្នុងរបាយការណ៍នៃការស្រាវជ្រាវថ្នាក់ជាតិស្តីពីសុខភាព និងបទពិសោធន៍ក្នុងជីវិតរបស់ស្ត្រីក្នុងប្រទេសកម្ពុជា (២០១៥)។ ហេតុនេះ អនុសាសន៍ក្នុងរបាយការណ៍បានបន្សុីជាមួយអនុសាសន៍ដែលផ្តល់ក្នុងឯកសារការស្រាវជ្រាវថ្នាក់ជាតិខាងលើ។

### លើកកម្ពស់សមភាពយេនឌ័រ និងផ្តល់ភាពអង់អាចដល់ស្ត្រីៈ

ទិន្នន័យដែលបានបង្ហាញក្នុងរបាយការណ៍នេះ និងការស្រាវជ្រាវថ្នាក់ជាតិស្តីពីសុខភាព និងបទពិសោធន៍ក្នុងជីវិតរបស់ស្ត្រីក្នុងប្រទេសកម្ពុជា(២០១៥) បានគាំទ្រដល់ភស្តុតាងអន្តរជាតិដែលរកឃើញថានៅពេលស្ត្រីទទួលបានធនធានច្រើនឡើង ភាពងាយរងគ្រោះដោយអំពើហិង្សាអំឡុងពេល១២ខែកន្លងមកហាក់មានភាពថយចុះ។ ការផ្តល់ឱកាសដល់ស្ត្រី រួមមាន ការធានាឱ្យស្ត្រីទទួលបានការអប់រំគ្រប់គ្រាន់ និងមានការងារទទួលប្រាក់ចំណូលព្រមទាំងការពន្យារកំណើត ។ អត្រាប្រេវ៉ាឡង់នៃអំពើហិង្សាលើរាងកាយ និងផ្លូវភេទលើដៃគូស្និទ្ធស្នាលអំឡុងពេល១២ខែកន្លងមកមានការថយចុះចន្លោះឆ្នាំ ២០០០និង ២០១៤ ហើយការថយចុះនេះមានទំនាក់ទំនងនឹងសមាមាត្រស្ត្រីចូលរួមក្នុងអង្កេតដែលបានបញ្ចប់ការសិក្សាកម្រិតមធ្យមសិក្សា ឬខ្ពស់ជាងនិងសមាមាត្រស្ត្រីដែលមានកូន៥នាក់ ឬច្រើនកំពុងរស់នៅក្នុងគ្រួសារ ឬមានការងារដែលមិនទទួលបានប្រាក់ឈ្នួលមានកម្រិតទាប។

### ការផ្លាស់ប្តូរបទដ្ឋានសង្គម ឬផ្នត់គំនិតក្នុងការទទួលយកអំពើហិង្សាលើស្ត្រីៈ

ជាង៥០%នៃស្ត្រីដែលផ្តល់ចម្លើយក្នុងការអង្កេតប្រជាសាស្ត្រ និងសុខភាព បានយល់ស្របថាប្តីអាចវាយប្រពន្ធរបស់ខ្លួនដោយមានហេតុផលត្រឹមតែមួយប៉ុណ្ណោះ។ លទ្ធផលស្រដៀងគ្នានេះដែរ

បានបង្ហាញនៅក្នុងការស្រាវជ្រាវថ្នាក់ជាតិស្តីពីសុខភាព និងបទពិសោធន៍ក្នុងជីវិតរបស់ស្ត្រីនៅក្នុងប្រទេសកម្ពុជា។ មូលហេតុចម្បងដែលស្ត្រីមិនបានស្វែងរកជំនួយដោយសារពួកគេគិតថាអំពើហិង្សាកើតឡើងជារឿងធម្មតា។ ចំណុចទាំងនេះបានបញ្ជាក់ក្នុងផែនការសកម្មភាពជាតិ ដែលតម្រូវឱ្យដោះស្រាយការទទួលយកអំពើហិង្សាលើស្ត្រីដែលប្រព្រឹត្តដោយបុរស និងក្មេងប្រុសនៅក្នុងប្រទេសកម្ពុជា។ លទ្ធផលក្នុងរបាយការណ៍នេះបង្ហាញថា ចំណុចដែលយកចិត្តទុកដាក់គឺការផ្លាស់ប្តូរគំនិតរបស់ស្ត្រី និងក្មេងស្រី។

## លើកកម្ពស់ភាពជាបុរសដែលគ្មានអំពើហិង្សាឈានឆ្ពោះទៅរកសមភាព និងការគោរពគ្នា៖

ដៃគូស្និទ្ធស្នាលគឺជាអ្នកប្រព្រឹត្តអំពើហិង្សាលើរាងកាយស្ត្រី។ ស្ត្រីបានរាយការណ៍ថាអំពើហិង្សាលើរាងកាយដែលប្រព្រឹត្តដោយដៃគូស្និទ្ធស្នាលជាបុរសមានចំនួន៣ ដងច្រើនជាងអ្នកប្រព្រឹត្តអំពើហិង្សាជាស្ត្រី។ លើសពីនេះទៅទៀត នៅពេលដែលដៃគូស្និទ្ធស្នាលប្រើឥរិយាបថត្រួតត្រាស្ត្រីមានភាពភ័យខ្លាចខ្លាំង និងទទួលរងអំពើហិង្សាលើរាងកាយ ឬផ្លូវភេទ។ ការលើកកម្ពស់ភាពជាបុរសដែលគ្មានអំពើហិង្សាគឺជាមធ្យោបាយបន្ថែមក្នុងការកាត់បន្ថយទស្សនៈសង្គមដែលទទួលយកការប្រើអំពើហិង្សាលើស្ត្រី។

**លើកកម្ពស់ផាសុកភាពក្នុងគ្រួសារ និងបរិយាកាសដែលគ្មានអំពើហិង្សាសម្រាប់កុមារ៖** ស្ត្រីដែលធ្លាប់ឃើញអំពើហិង្សារបស់ឪពុកម្តាយតាំងពីកុមារភាព ងាយរងគ្រោះដោយសារអំពើហិង្សាលើរាងកាយ ឬផ្លូវភេទពីដៃគូស្និទ្ធស្នាល។ អនុសាសន៍នេះគឺបន្ថែមទៅលើចំណុចទាំងពីរខាងលើ ដែលបង្ហាញឱ្យឃើញថាការផ្លាស់ប្តូរបទដ្ឋានសង្គម ឬផ្នត់គំនិត និងភាពជាបុរសគ្មានអំពើហិង្សាមានឥទ្ធិពលវិជ្ជមានលើបរិយាកាសគ្រួសារ។ អនុសាសន៍នីមួយៗគឺពឹងផ្អែកគ្នាទៅវិញទៅមក។ កុមារដែលចិញ្ចឹមបីបាច់ក្នុងគ្រួសារគ្មានអំពើហិង្សា ពេលធំឡើងគឺមិនងាយទទួលយកបទដ្ឋានសង្គម ឬផ្នត់គំនិតដែលទទួលយកការប្រព្រឹត្តអំពើហិង្សាលើស្ត្រី និងងាយយល់ដឹង ហើយប្រកាន់ភ្ជាប់នូវភាពអហិង្សា។

## ដំណោះស្រាយការសេពគ្រឿងស្រវឹង៖

ការស្រាវជ្រាវនេះបានបង្ហាញថា កម្រិតនៃការប្រើប្រាស់គ្រឿងស្រវឹងខ្ពស់មានទំនាក់ទំនងយ៉ាងជិតស្និទ្ធជាមួយនឹងហានិភ័យនៃការប្រព្រឹត្តអំពើហិង្សា តាមរយៈសំណាកគំរូនៃការអង្កេតនេះ និងការស្រាវជ្រាវថ្នាក់ជាតិស្តីពីសុខភាព និងបទពិសោធន៍ក្នុងជីវិតរបស់ស្ត្រីក្នុងប្រទេសកម្ពុជា (២០១៥)។ ការសិក្សាកម្រិតអន្តរជាតិបានបង្ហាញពីទំនាក់ទំនងរវាងការកាត់បន្ថយការប្រើប្រាស់គ្រឿងស្រវឹង និងបទពិសោធន៍អំពើហិង្សាលើដៃគូ ស្និទ្ធស្នាល។ លើសពីនេះទៀត អំពើហិង្សាលើរាងកាយគឺមានភាពធ្ងន់ធ្ងរនៅពេលមានការប្រើប្រាស់គ្រឿងស្រវឹង ទោះបីជាការប្រើប្រាស់គ្រឿងស្រវឹងអាចមិនមែនជាមូលហេតុបង្កឱ្យមានអំពើហិង្សា។

### បង្កើនការវិនិយោគលើសេវាគាំទ្រ៖

ទាមទារឱ្យមានការជំរុញ និងលើកទឹកចិត្តដើម្បីឱ្យស្ត្រីទទួលបានសេវាគាំទ្រ។ ខណៈពេលព័ត៌មានអំពីមូលហេតុដែលស្ត្រីស្វែងរក ឬមិនស្វែងរកជំនួយពេលទទួលរងអំពើហិង្សាពីដៃគូស្និទ្ធស្នាលមានតិចតួច លទ្ធផលបានបង្ហាញថា ស្ត្រីស្វែងរកសេវាគាំទ្រផ្លូវការដូចជា នគរបាល អ្នកផ្តល់សេវាសុខាភិបាលនិងអ្នកផ្តល់ប្រឹក្សាយោបល់គឺមានចំនួនតិចតួចប៉ុណ្ណោះ។ ជាការពិត គ្រប់ស្ថាប័នពាក់ព័ន្ធទាំងអស់ដែលផ្តល់សេវាជំនួយ ឬគាំទ្រដល់គ្រួសារ (រួមទាំងស្ថាប័នផ្តល់សេវាអប់រំ) គួរមានធនធានគ្រប់គ្រាន់ ដើម្បីឆ្លើយតបទៅនឹងអំពើហិង្សាដែលបានរាយការណ៍។ ការវិនិយោគបន្ថែមទៀតគួរពិចារណាលើការបណ្តុះបណ្តាលដល់អ្នកផ្តល់សេវាគាំទ្រគ្រប់វិស័យទាំងអស់ និងផ្សព្វផ្សាយឱ្យបានទូលំទូលាយអំពីសេវាគាំទ្រ និងធានាឱ្យមានធនធានគ្រប់គ្រាន់សម្រាប់ការឆ្លើយតបឱ្យបានសមស្របតាមការកើនឡើងនូវតម្រូវការរបស់ស្ត្រីរងគ្រោះ។

ការស្រាវជ្រាវថ្នាក់ជាតិស្តីពីសុខភាព និងបទពិសោធន៍ក្នុងជីវិតរបស់ស្ត្រីបានលើកឡើងនូវចំណុចសំខាន់ៗពាក់ព័ន្ធនឹងសុខភាព និងផលវិបាកទាក់ទងនឹងអំពើហិង្សាលើដៃគូស្និទ្ធស្នាល។ ទោះបីលទ្ធផលនៃសុខភាព និងអំពើហិង្សាមិនបានដាក់បញ្ចូលទៅក្នុងការអង្កេត អ.ប.ស.ក ភាពស្រដៀងគ្នានៃការប៉ាន់ប្រមាណអាត្រាប្រេវ៉ាឡង់រវាងការអង្កេតទាំងពីរបានបង្ហាញអំពីតម្រូវការឱ្យមានយន្តការសម្របសម្រួលដ៏ពេញលេញមួយក្នុងការឆ្លើយតប និងទប់ស្កាត់អំពើហិង្សាលើស្ត្រី។

ជាចុងក្រោយ ការធ្វើការអង្កេតប្រជាសាស្ត្រ និងសុខភាពបែបនេះនឹងផ្តល់ភាពងាយស្រួលក្នុងការប្រៀបធៀបប្រេវ៉ាឡង់នៃអំពើហិង្សាកន្លងមក និងឆ្លើបតបទៅនឹងអនុសាសន៍នៅក្នុងការស្រាវជ្រាវថ្នាក់ជាតិស្តីពីសុខភាព និងបទពិសោធន៍ក្នុងជីវិតរបស់ស្ត្រីដែលជំរុញឱ្យមានការស្រាវជ្រាវបន្ថែម តាមដានត្រួតពិនិត្យ និងវាយតម្លៃ។ ក៏ប៉ុន្តែ ទម្រង់នៃការអង្កេត អ.ប.ស.ក ផ្នែកអំពើហិង្សាក្នុងគ្រួសារមិនបានផ្តល់ឱ្យមានការយល់ដឹងទូលំទូលាយអំពីឥរិយាបថក្នុងការស្វែងរកជំនួយរបស់ស្ត្រីដែលទទួលរងអំពើហិង្សា។ ទម្រង់កម្រងសំណួរបច្ចុប្បន្ន មិនបានបង្ហាញពីទំនាក់ទំនងរវាងឥរិយាបថស្វែងរកជំនួយ និងអំពើហិង្សាលើដៃគូស្និទ្ធស្នាលឡើយ។ លើសពីនេះទៀត មិនមានសំណួរបញ្ជាក់បន្ថែម អំពីមូលហេតុក្នុងការស្វែងរក ឬមិនស្វែងរកជំនួយ។ ការឆ្លើយតបទៅនឹងសំណួរបែបនេះបានផ្តល់ដំណោះស្រាយចំពោះឧបសគ្គទាក់ទងនឹងការស្វែងរកជំនួយ។ ជម្រើសក្នុងការប្រមូលទិន្នន័យបែបនេះគឺដោយដាក់បញ្ចូលទៅក្នុងការអង្កេត អ.ប.ស.ក ផ្នែកអំពើហិង្សាក្នុងគ្រួសារ ឬផ្ទៀងផ្ទាត់លទ្ធផលរបស់ អ.ប.ស.ក ជាមួយអង្កេតប្រជាជនដូចជាការស្រាវជ្រាវថ្នាក់ជាតិស្តីពីសុខភាព និងបទពិសោធន៍ក្នុងជីវិតរបស់ស្ត្រី ។

# តារាងឧបសម្ព័ន្ធស្ថិតិ

## ឧបសម្ព័ន្ធ (ក) ៖ តារាងលម្អិតនៃអំពើហិង្សាលើដៃគូស្និទ្ធស្នាល

**តារាងក១៖ ប្រេវ៉ាឡង់នៃអំពើហិង្សាលើរាងកាយ ផ្លូវភេទ ផ្លូវចិត្ត រាងកាយឬផ្លូវភេទ និងរាងកាយ ឬផ្លូវភេទ ឬផ្លូវចិត្តពីដៃគូស្និទ្ធស្នាលបច្ចុប្បន្ន បែងចែកតាមលក្ខណៈប្រជាសាស្ត្រ**

| | អំពើហិង្សាលើរាងកាយដោយដៃគូ | អំពើហិង្សាលើផ្លូវភេទដោយដៃគូ | អំពើហិង្សាលើផ្លូវចិត្តដោយដៃគូ | អំពើហិង្សាលើរាងកាយឬផ្លូវភេទដោយដៃគូ | អំពើហិង្សាលើរាងកាយ ផ្លូវភេទឬផ្លូវចិត្តដោយដៃគូ |
|---|---|---|---|---|---|
| | បច្ចុប្បន្ន/ថ្មីបំផុត | | | | |
| | % | % | % | % | % |
| **អាយុ** | | | | | |
| ១៥-១៩ | ៧.៤ | ១.៩ | ១៣.៨ | ៧.៤ | ១៤.៨ |
| ២០-២៤ | ១១.៧ | ៤.៨ | ១៥.២ | ១៤.៣ | ១៩.៣ |
| ២៥-២៩ | ១១.១ | ៤.២ | ១៨.៧ | ១៣.០ | ២២.៤ |
| ៣០-៣៤ | ១៧.២ | ៤.៨ | ២៦.៣ | ១៨.៥ | ៣០.៧ |
| ៣៥-៣៩ | ១៩.៤ | ៦.៩ | ៣០.០ | ២៣.៩ | ៣៤.៦ |
| ៤០-៤៤ | ២០.៤ | ៦.៣ | ៣១.៤ | ២១.៦ | ៣៤.៤ |
| ៤៥-៤៩ | ២០.១ | ៧.៥ | ៣០.៣ | ២២.០ | ៣៤.៥ |
| **សាសនា** | | | | | |
| ព្រះពុទ្ធ | ១៦.២ | ៥.៥ | ២៤.៨ | ១៨.២ | ២៨.៧ |
| មូស្លីម | ១៧.៦ | ១.៣ | ២៧.០ | ១៨.៩ | ២៩.៣ |
| គ្រីស្ត | ៣.០ | ១២.៥ | ១៥.៦ | ១៥.៦ | ១៨.២ |
| ផ្សេងទៀត/គ្មាន | ២៣.៣ | ៤.៧ | ២៣.៣ | ២៣.៣ | ៣២.៦ |
| **លំនៅដ្ឋាន** | | | | | |
| ទីប្រជុំជន | ១២.៣ | ៣.៩ | ១៨.២ | ១៣.៥ | ២៣.១ |
| ជនបទ | ១៦.៩ | ៥.៧ | ២៥.៩ | ១៩.១ | ២៩.៦ |
| **រាជធានី/ខេត្ត** | | | | | |
| បន្ទាយមានជ័យ | ១៣.៨ | ៤.៩ | ១៩.៤ | ១៤.៦ | ២៣.៦ |
| កំពង់ចាម | ២០.៤ | ៥.០ | ៣៤.៧ | ២២.២ | ៣៥.៤ |
| កំពង់ឆ្នាំង | ៩.២ | ៥.៥ | ១៦.៥ | ១១.៩ | ២១.៨ |
| កំពង់ស្ពឺ | ១៥.២ | ៣.៤ | ១៩.៣ | ១៥.៦ | ២៣.៩ |
| កំពង់ធំ | ១៣.១ | ២.០ | ១៧.៦ | ១៣.១ | ១៩.០ |
| កណ្ដាល | ១៣.៩ | ១៦.៩ | ២២.៨ | ២៣.៦ | ២៨.៣ |
| ក្រចេះ | ២០.២ | ៧.៤ | ២៥.៥ | ២១.១ | ៣១.៦ |
| ភ្នំពេញ | ១១.៣ | ៣.៧ | ១៥.៦ | ១២.៦ | ២២.៣ |
| ព្រៃវែង | ១០.៤ | ២.០ | ៨.០ | ១១.២ | ១៣.៦ |
| ពោធិ៍សាត់ | ១១.០ | ២.០ | ២៤.០ | ១១.០ | ២៦.០ |
| សៀមរាប | ២៨.៦ | ១០.៧ | ៥៥.៤ | ៣១.៦ | ៥៨.២ |
| ស្វាយរៀង | ៨.៥ | ០.៨ | ១៣.៦ | ៨.៥ | ១៦.៩ |
| តាកែវ | ២០.១ | ៥.៧ | ៣២.៥ | ២០.៦ | ៣៥.៦ |
| ឧត្តរមានជ័យ | ១៥.៩ | ៦.៣ | ១៧.៥ | ១៧.៥ | ១៩.០ |

| | | | | | |
|---|---|---|---|---|---|
| បាត់ដំបង/ប៉ៃលិន | ១២.៨ | ៥.៦ | ២២.២ | ១៧.៥ | ២៦.៤ |
| កំពត/កែប | ២២.១ | ១.៣ | ២៨.៤ | ២២.៧ | ៣២.៣ |
| ព្រះសីហនុ/កោះកុង | ២០.០ | ៥.៣ | ២៦.៧ | ២១.៣ | ៣០.៧ |
| ព្រះវិហារ/ស្ទឹងត្រែង | ២៥.៣ | ១២.៦ | ៤៤.៨ | ២៩.៩ | ៥១.២ |
| មណ្ឌលគិរី/រតនគិរី | ១៤.៣ | ១.៣ | ១៧.១ | ១៤.៣ | ២៣.៤ |
| **តំបន់** | | | | | |
| ទំនាបកណ្តាល | ១៥.១ | ៥.៨ | ២២.៩ | ១៧.៥ | ២៦.៨ |
| ទន្លេសាប | ១៥.៨ | ៥.៧ | ២៧.១ | ១៨.០ | ៣០.១ |
| មាត់សមុទ្រ/ឆ្នេរ | ២១.៤ | ២.២ | ២៧.៥ | ២២.៣ | ៣១.៩ |
| ខ្ពង់រាបនិងភ្នំ | ១៧.៩ | ៥.៥ | ២៤.៦ | ១៩.០ | ៣០.០ |
| **ស្ថានភាពអាពាហ៍ពិពាហ៍** | | | | | |
| មិនដែលរៀបការ | គ/ទ | | | | |
| រៀបការ/រស់នៅជាមួយគ្នា | ១៤.៩ | ៤.៨ | ២៣.៩ | ១៦.៩ | ២៧.៦ |
| លែងលះ/រស់នៅបែកគ្នា | ៣៥.១ | ១៥.៧ | ៣៩.៦ | ៣៨.៣ | ៤៦.៨ |
| មេម៉ាយ ពោះម៉ាយ | ២៣.៥ | ៧.៩ | ២៧.២ | ២៤.៦ | ៣១.៦ |
| **ចំនួនកូនរស់** | | | | | |
| ០ | ៨.១ | ២.០ | ៨.១ | ៨.១ | ១២.៧ |
| ១-២ | ១៣.៣ | ៤.៨ | ២០.៣ | ១៥.៥ | ២៣.៩ |
| ៣-៤ | ១៨.៨ | ៦.៦ | ៣០.២ | ២១.១ | ៣៤.៤ |
| ៥+ | ២៦.៨ | ៧.៨ | ៣៨.៩ | ២៨.២ | ៤៣.៤ |
| **ស្ថានភាពការងារ** | | | | | |
| ការងារទទួលបានប្រាក់ឈ្នួល | ១៥.១ | ៥.៤ | ២២.៨ | ១៧.៣ | ២៦.៨ |
| ការងារមិនទទួលប្រាក់ឈ្នួល | ២៦.៩ | ៨.៨ | ៤១.៨ | ២៧.៧ | ៤៥.០ |
| មិនមានការងារ | ១៦.៧ | ៤.២ | ២៦.១ | ១៨.៤ | ៣០.៥ |
| **ការសិក្សាអប់រំ** | | | | | |
| មិនបានរៀន | ២៤.៨ | ៧.៩ | ៣១.១ | ២៦.៩ | ៣៨.០ |
| បឋមសិក្សា | ១៧.៨ | ៥.៤ | ២៩.២ | ១៩.៩ | ៣២.៦ |
| មធ្យមសិក្សានិងខ្ពស់ជាង | ៩.៣ | ៤.៥ | ១៤.២ | ១១.៣ | ១៧.៧ |
| **បញ្ចភាគទ្រព្យសម្បត្តិ** | | | | | |
| ក្របំផុត | ២៣.៧ | ៧.៣ | ៣១.៨ | ២៥.៨ | ៣៧.២ |
| ក្រ | ១៨.៧ | ៦.៦ | ៣០.៣ | ២១.១ | ៣៣.០ |
| មធ្យម | ១៦.៤ | ៣.៩ | ២៣.៨ | ១៧.៨ | ២៧.៤ |
| មាន | ១៣.៥ | ៥.៣ | ២៣.២ | ១៥.២ | ២៦.៣ |
| មានបំផុត | ៩.៤ | ៤.៥ | ១៥.៥ | ១១.៩ | ២០.៦ |
| **សរុប** | **១៦.២** | **៥.៥** | **២៤.៨** | **១៨.២** | **២៨.៧** |

* ប្រេវ៉ាឡង់អំពើហិង្សាប្រព្រឹត្តដោយអតីតដៃគូមិនបានរាយការណ៍ក្នុងតារាងនេះទេ ដោយសារតែអំពើហិង្សាលើផ្លូវចិត្តប្រព្រឹត្តដោយអតីតដៃគូមិនបានវាស់វែងនៅក្នុងអ.ប.ស.ក ឆ្នាំ២០១៤

តារាង ក២៖ ប្រេវ៉ាឡង់នៃអំពើហិង្សាលើរាងកាយ ផ្លូវភេទ ផ្លូវចិត្ត រាងកាយឬផ្លូវភេទ និងរាងកាយ ឬផ្លូវភេទ ឬ ផ្លូវចិត្តពីដៃគូស្និទ្ធស្នាលបច្ចុប្បន្នអំឡុងពេល១២ខែកន្លងមក បែងចែកតាមលក្ខណៈប្រជាសាស្ត្រ

| | អំពើហិង្សាលើរាងកាយដោយដៃគូ | អំពើហិង្សាលើផ្លូវភេទដោយដៃគូ | អំពើហិង្សលើផ្លូវចិត្តដោយដៃគូ | អំពើហិង្សាលើរាងកាយ ឬផ្លូវភេទដោយដៃគូ | អំពើហិង្សាលើរាងកាយ ផ្លូវភេទឬផ្លូវចិត្តដោយដៃគូ |
|---|---|---|---|---|---|
| | បច្ចុប្បន្ន/ថ្មីបំផុត | | | | |
| | % | % | % | % | % |
| **អាយុ** | | | | | |
| ១៥-១៩ | ៦.៥ | ១.៩ | ១៣.០ | ៧.៣ | ១៤.៨ |
| ២០-២៤ | ៧.៤ | ៣.៩ | ១២.១ | ៩.៨ | ១៥.០ |
| ២៥-២៩ | ៦.១ | ៣.៦ | ១៣.៥ | ៧.៨ | ១៥.៣ |
| ៣០-៣៤ | ១១.៧ | ៣.៦ | ១៤.៨ | ១២.៨ | ១២.៥ |
| ៣៥-៣៩ | ១១.១ | ៥.១ | ២០.៩ | ១៤.១ | ២៣.៤ |
| ៤០-៤៤ | ៩.៨ | ៣.៥ | ២០.៦ | ១១.២ | ២២.៩ |
| ៤៤-៤៩ | ១០.៣ | ៤.៩ | ១៨.៩ | ១១.០ | ២០.៧ |
| **សាសនា** | | | | | |
| ព្រះពុទ្ធ | ៩.២ | ៤.៧ | ១៧.២ | ១០.៩ | ១៩.៥ |
| មូស្លីម | ១៤.៩ | ០.០ | ២១.៦ | ១៤.៩ | ២១.៦ |
| គ្រីស្តសាសនា | ០.០ | ៣.០ | ១៥.២ | ៣.០ | ១៥.៦ |
| ផ្សេងទៀត/គ្មានព័ត៌មាន | ១៦.៣ | ២.៣ | ១៦.៣ | ១៦.៣ | ២៣.៨ |
| **ទីលំនៅដ្ឋាន** | | | | | |
| ទីប្រជុំជន | ៤.៧ | ២.៩ | ១២.៣ | ៥.៥ | ១៣.៥ |
| ជនបទ | ១០.២ | ៤.១ | ១៨.២ | ១១.៩ | ២០.៧ |
| **រាជធានី/ខេត្ត** | | | | | |
| បន្ទាយមានជ័យ | ១៣.៨ | ៤.៩ | ១៧.៧ | ១៤.៦ | ២២.០ |
| កំពង់ចាម | ១៨.៤ | ៤.៨ | ៣២.៤ | ២០.០ | ៣៣.៦ |
| កំពង់ឆ្នាំង | ៣.៧ | ២.៨ | ១០.៩ | ៥.៥ | ១៤.៧ |
| កំពង់ស្ពឺ | ៧.៦ | ២.១ | ១២.៦ | ៨.០ | ១៣.៤ |
| កំពង់ធំ | ៨.៥ | ១.៣ | ១៣.៧ | ៨.៥ | ១៤.៤ |
| កណ្ដាល | ៨.៤ | ១៣.៥ | ១៣.១ | ១៦.០ | ១៩.៨ |
| ក្រចេះ | ១០.៦ | ៥.៣ | ១៧.០ | ១៣.៨ | ២២.១ |
| ភ្នំពេញ | ៣.៣ | ៣.០ | ១១.៧ | ៤.៣ | ១២.៧ |
| ព្រៃវែង | ៤.០ | ១.២ | ៣.៦ | ៤.៨ | ៦.៨ |
| ពោធិ៍សាត់ | ៧.០ | ១.០ | ១៦.០ | ៧.០ | ១៨.០ |
| សៀមរាប | ១៥.៨ | ៧.៧ | ៣៧.៨ | ១៨.៩ | ៣៩.៨ |
| ស្វាយរៀង | ៥.១ | ០.៨ | ៧.៦ | ៥.១ | ៨.៥ |
| តាកែវ | ៩.៣ | ២.៦ | ១៥.៥ | ៩.៣ | ១៨.០ |
| ឧត្តរមានជ័យ | ១៤.១ | ៦.៣ | ១៥.៩ | ១៥.៩ | ១៧.៥ |
| បាត់ដំបង/ប៉ៃលិន | ៦.០ | ១.៣ | ១៣.២ | ៦.៨ | ១៥.០ |
| កំពត/កែប | ៨.៤ | ១.៣ | ១៨.២ | ៩.១ | ១៩.៤ |
| ព្រះសីហនុ/កោះកុង | ៨.០ | ៤.០ | ១៤.៧ | ៨.០ | ១៦.០ |
| ព្រះវិហារ/ស្ទឹងត្រែង | ១១.៥ | ៦.៩ | ២៦.៤ | ១៦.១ | ២៩.៩ |

| | | | | | |
|---|---|---|---|---|---|
| មណ្ឌលគិរី/រតនគិរី | ៧.៨ | ១.៣ | ១៣.០ | ៧.៨ | ១៦.៩ |
| **តំបន់** | | | | | |
| ទំនាបកណ្តាល | ៩.៣ | ៤.៧ | ១៦.៧ | ១១.៤ | ១៩.១ |
| ទន្លេសាប | ៩.៨ | ៣.៥ | ១៩.០ | ១១.០ | ២១.២ |
| មាត់សមុទ្រ/ឆ្នេរ | ៨.៣ | ១.៧ | ១៧.០ | ៩.២ | ១៨.៣ |
| ខ្ពង់រាបនិងភ្នំ | ៨.៩ | ៣.៤ | ១៥.៩ | ១០.៥ | ១៨.៣ |
| **ស្ថានភាពអាពាហ៍ពិពាហ៍** | | | | | |
| មិនដែលរៀបការ | គ/ទ | | | | |
| រៀបការ/រស់នៅជាមួយគ្នា | ៩.១ | ៣.៩ | ១៧.៦ | ១០.៩ | ១៩.៩ |
| លែងលះ/រស់នៅបែកគ្នា | ១២.៤ | ៥.២ | ១៤.៩ | ១៣.៦ | ១៦.២ |
| មេម៉ាយ ពោះម៉ាយ | ១០.៤ | ៣.៥ | ១២.៣ | ១០.៤ | ១៥.៧ |
| **ចំនួនកូនរស់** | | | | | |
| ០ | ៥.១ | ១.៥ | ៧.១ | ៥.៦ | ៩.១ |
| ១-២ | ៨.០ | ៣.៩ | ១៤.៦ | ១០.០ | ១៦.៨ |
| ៣-៤ | ១០.៥ | ៣.៧ | ២០.៨ | ១១.៤ | ២២.៨ |
| ៥+ | ១៤.៧ | ៥.៩ | ២៦.០ | ១៦.៩ | ២៩.២ |
| **ស្ថានភាពការងារ** | | | | | |
| ការងារទទួលប្រាក់ឈ្នួល | ៩.៤ | ៤.២ | ១៦.៥ | ១១.២ | ១៨.៨ |
| ការងារមិនបានប្រាក់ឈ្នួល | ១០.៥ | ៥.៥ | ២៧.៤ | ១២.២ | ៣០.៣ |
| មិនមានការងារ | ៨.៤ | ១.៩ | ១៦.៥ | ៩.៤ | ១៨.៨ |
| **ការសិក្សាអប់រំ** | | | | | |
| មិនបានរៀន | ១៥.២ | ៦.៥ | ២២.៤ | ១៧.៥ | ២៦.១ |
| បឋមសិក្សា | ១០.៧ | ៣.៧ | ២០.៩ | ១២.២ | ២៣.០ |
| មធ្យមសិក្សា និងខ្ពស់ជាង | ៤.២ | ៣.១ | ៨.៩ | ៥.៨ | ១០.៧ |
| **បញ្ចភាគទ្រព្យសម្បត្តិ** | | | | | |
| ក្របំផុត | ១៥.៨ | ៦.១ | ២៣.៦ | ១៨.៣ | ២៧.០ |
| ក្រ | ១១.៣ | ៤.៧ | ២២.៩ | ១៣.០ | ២៥.០ |
| មធ្យម | ៩.៩ | ២.៨ | ១៦.៤ | ១១.១ | ១៨.៨ |
| មាន | ៦.៥ | ៣.២ | ១៥.៥ | ៧.៦ | ១៧.៣ |
| មានបំផុត | ៣.៦ | ៣.១ | ៩.០ | ៥.៤ | ១០.៧ |
| **សរុប** | **៩.៣** | **៣.៩** | **១៧.៣** | **១០.៩** | **១៩.៦** |

* * ប្រេវ៉ាឡង់អំពើហិង្សាប្រព្រឹត្តដោយអតីតដៃគូមិនបានរាយការណ៍ក្នុងតារាងនេះទេ ដោយសារតែអំពើហិង្សាលើផ្លូវចិត្តប្រព្រឹត្តដោយអតីតដៃគូមិនបានវាស់វែងនៅក្នុងអ.ប.ស.ក ឆ្នាំ២០១៤។ តារាងនេះត្រូវនឹងសូចនាករ ៥.២.១។

**តារាងក៣៖ ប្រភេទអំពើហិង្សាលើដៃគូស្និទ្ធស្នាលក្នុងចំណោមស្ត្រីធ្លាប់មានដៃគូ បែងចែកតាមដៃគូបច្ចុប្បន្ន ឬថ្មីបំផុត(អ.ប.ស.ក ឆ្នាំ២០១៤)**

| ប្រភេទអំពើហិង្សា | អត្រាប្រេវ៉ាឡង់% | ចន្លោះជឿជាក់ ៩៥% |
|---|---|---|
| អំពើហិង្សាលើរាងកាយក្នុងមួយជីវិត | ១៦.២ | ១៤.៦-១៧.៩ |
| អំពើហិង្សាលើផ្លូវភេទក្នុងមួយជីវិត | ៥.៥ | ៥.៥-៦.៧ |
| អំពើហិង្សាលើផ្លូវចិត្តក្នុងមួយជីវិត | ២៤.៨ | ២២.៨-២៦.៨ |
| អំពើហិង្សាផ្នែកសេដ្ឋកិច្ចក្នុងមួយជីវិត | ៥.៨ | ៤.៩-៦.៩ |
| អំពើហិង្សាលើរាងកាយ និង/ឬផ្លូវភេទក្នុងមួយជីវិត | ១៨.២ | ១៦.៥-២០.១ |
| អំពើហិង្សាលើរាងកាយ ផ្លូវភេទនិង/ឬផ្លូវចិត្តក្នុងមួយជីវិត | ២៨.៧ | ២៦.៦-៣០.៨ |
| អំពើហិង្សាលើរាងកាយ ផ្លូវភេទផ្លូវចិត្តនិង/ឬផ្នែកសេដ្ឋកិច្ចក្នុងមួយជីវិត | ៣០.៨ | ២៨.៧-៣២.៩ |
| អំពើហិង្សាលើរាងកាយអំឡុងពេល១២ខែកន្លងមក | ៩.៣ | ៨.១-១០.៧ |
| អំពើហិង្សាលើផ្លូវភេទអំឡុងពេល១២ខែកន្លងមក | ៣.៩ | ៣.១-៥.០ |
| អំពើហិង្សាលើរាងកាយ ឬផ្លូវភេទអំឡុងពេល១២ខែកន្លងមក | ១០.៩ | ៩.៥-១២.៤ |

**តារាង ក៤៖បទពិសោធន៍អំពើហិង្សាលើរាងកាយក្នុងជីវិត និងអំឡុងពេល១២ខែកន្លងមកក្នុងចំណោមស្ត្រីធ្លាប់មានដៃគូ បែងចែកតាមលក្ខណៈសាវតា (អ.ប.ស.ក ឆ្នាំ២០១៤)**

| លក្ខណៈអង្កេត | ស្ត្រីធ្លាប់រងអំពើហិង្សាលើរាងកាយពីដៃគូក្នុងជីវិត | | ស្ត្រីធ្លាប់រងអំពើហិង្សាលើរាងកាយពីដៃគូអំឡុងពេល១២ខែកន្លងមក | | សរុប |
|---|---|---|---|---|---|
| | ដៃគូបច្ចុប្បន្ន/ថ្មីបំផុត[1] | ដៃគូណាមួយ[2] | ដៃគូបច្ចុប្បន្ន/ថ្មីបំផុត[1] | ដៃគូណាមួយ[2] | ចំនួន |
| | % | % | % | % | |
| **អាយុ** | | | | | |
| ១៥-១៩ | ៧.៤ | ៧.៤ | ៦.៥ | ៦.៥ | ១០៨ |
| ២០-២៤ | ១១.៧ | ១២.៤ | ៧.៤ | ៧.៤ | ៤៦១ |
| ២៥-២៩ | ១១.១ | ១១.៦ | ៦.១ | ៦.១ | ៥៧៧ |
| ៣០-៣៤ | ១៧.២ | ១៨.៣ | ១១.៧ | ១១.៧ | ៧២៦ |
| ៣៥-៣៩ | ១៩.៤ | ២១.៤ | ១១.១ | ១១.១ | ៤៣៥ |
| ៤០-៤៤ | ២០.៤ | ២២.០ | ៩.៨ | ៩.៨ | ៥០៩ |
| ៤៥-៤៩ | ២០.១ | ២៣.៣ | ១០.៣ | ១០.៣ | ៤២៩ |
| **សាសនា** | | | | | |
| ព្រះពុទ្ធ | ១៦.២ | ១៧.៦ | ៩.២ | ៩.២ | ៣,០៩៥ |
| មូស្លីម | ១៧.៦ | ១៧.៦ | ១៤.៩ | ១៤.៩ | ៧៥ |
| គ្រឹស្តសាសនា | ៣.០ | ៣.១ | ០.០ | ០.០ | ៣២ |
| ផ្សេងទៀត/គ្មានព័ត៌មាន | ២៣.៣ | ២៣.៣ | ១៦.៣ | ១៦.៣ | ៤៣ |
| **ទីលំនៅដ្ឋាន** | | | | | |
| ទីប្រជុំជន | ១២.៣ | ១៥.១ | ៤.៧ | ៤.៧ | ៤៨៩ |
| ជនបទ | ១៦.៩ | ១៨.០ | ១០.២ | ១០.២ | ២,៧៥៦ |
| **រាជធានី/ខេត្ត** | | | | | |

| | | | | | |
|---|---|---|---|---|---|
| បន្ទាយមានជ័យ | ១៣.៨ | ១៤.៦ | ១៣.៨ | ១៣.៨ | ១២៣ |
| កំពង់ចាម | ២០.៤ | ២២.០ | ១៨.៤ | ១៨.៤ | ៤៤១ |
| កំពង់ឆ្នាំង | ៩.២ | ១១.១ | ៣.៧ | ៣.៧ | ១០៩ |
| កំពង់ស្ពឺ | ១៥.២ | ១៦.០ | ៧.៦ | ៧.៦ | ២៣៨ |
| កំពង់ធំ | ១៣.១ | ១៤.៤ | ៨.៥ | ៨.៥ | ១៥៣ |
| កណ្តាល | ១៣.៩ | ១៣.៩ | ៨.៤ | ៨.៤ | ២៣៧ |
| ក្រចេះ | ២០.២ | ២០.២ | ១០.៦ | ១០.៦ | ៩៥ |
| ភ្នំពេញ | ១១.៣ | ១៥.០ | ៣.៣ | ៣.៣ | ៣០១ |
| ព្រៃវែង | ១០.៤ | ១០.៨ | ៤.០ | ៤.០ | ២៥០ |
| ពោធិ៍សាត់ | ១១.០ | ១៤.០ | ៧.០ | ៧.០ | ១០១ |
| សៀមរាប | ២៨.៦ | ៣០.១ | ១៥.៨ | ១៥.៨ | ១៩៦ |
| ស្វាយរៀង | ៨.៥ | ១០.២ | ៥.១ | ៥.១ | ១១៨ |
| តាកែវ | ២០.១ | ២០.១ | ៩.៣ | ៩.៣ | ១៩៤ |
| ឧត្តរមានជ័យ | ១៥.៩ | ១៥.៩ | ១៤.១ | ១៤.១ | ៦៣ |
| បាត់ដំបង/ប៉ៃលិន | ១២.៨ | ១៦.២ | ៦.០ | ៦.០ | ២៣៤ |
| កំពត/កែប | ២២.១ | ២២.៦ | ៨.៤ | ៨.៤ | ១៥៤ |
| ព្រះសីហនុ/កោះកុង | ២០.០ | ២១.៣ | ៨.០ | ៨.០ | ៧៥ |
| ព្រះវិហារ/ស្ទឹងត្រែង | ២៥.៣ | ២៧.៦ | ១១.៥ | ១១.៥ | ៨៧ |
| មណ្ឌលគិរី/រតនគិរី | ១៤.៣ | ១៤.៣ | ៧.៨ | ៧.៨ | ៧៧ |
| **តំបន់** | | | | | |
| ទំនាបកណ្តាល | ១៥.១ | ១៦.៥ | ៩.៣ | ៩.៣ | ១,៥៤០ |
| ទន្លេសាប | ១៥.៨ | ១៧.៨ | ៩.៨ | ៩.៨ | ៩៧៩ |
| មាត់សមុទ្រ/ឆ្នេរ | ២១.៤ | ២២.២ | ៨.៣ | ៨.៣ | ២២៩ |
| ខ្ពង់រាបនិងភ្នំ | ១៧.៩ | ១៨.៥ | ៨.៩ | ៨.៩ | ៤៩៦ |
| **ស្ថានភាពអាពាហ៍ពិពាហ៍** | | | | | |
| មិនដែលរៀបការ | គ/ទ | | គ/ទ | | |
| រៀបការ/រស់នៅជាមួយគ្នា | ១៤.៩ | ១៦.៤ | ៩.១ | ៩.១ | ២,៩៧៧ |
| លែងលះ/រស់បែកគ្នា | ៣៥.១ | ៣៦.៦ | ១២.៤ | ១២.៤ | ១៥៤ |
| មេម៉ាយ ពោះម៉ាយ | ២៣.៥ | ២៣.៥ | ១០.៤ | ១០.៤ | ១១៤ |
| **ចំនួនកូនរស់** | | | | | |
| ០ | ៨.១ | ៨.១ | ៥.១ | ៥.១ | ១៩៧ |
| ១-២ | ១៣.៣ | ១៤.៦ | ៨.០ | ៨.០ | ១,៦៨៣ |
| ៣-៤ | ១៨.៨ | ២០.១ | ១០.៥ | ១០.៥ | ៩៩២ |
| ៥+ | ២៦.៨ | ២៩.៥ | ១៤.៧ | ១៤.៧ | ៣៧៣ |
| **ការសិក្សាអប់រំ** | | | | | |
| មិនបានរៀន | ២៤.៨ | ២៦.៥ | ១៥.២ | ១៥.២ | ៩៩៥ |
| បឋមសិក្សា | ១៧.៨ | ១៩.៤ | ១០.៧ | ១០.៧ | ១,៧២៥ |
| មធ្យមសិក្សានិងខ្ពស់ជាង | ៩.៣ | ១០.១ | ៤.២ | ៤.២ | ១,០២៥ |

| | | | | | |
|---|---|---|---|---|---|
| បញ្ហាភាគទ្រព្យសម្បត្តិ | | | | | |
| ក្របំផុត | ២៣.៧ | ២៥.៤ | ១៥.៨ | ១៥.៨ | ៦២០ |
| ក្រ | ១៨.៧ | ២០.៣ | ១១.៣ | ១១.៣ | ៦៧៦ |
| មធ្យម | ១៦.៤ | ១៧.៥ | ៩.៩ | ៩.៩ | ៧៦៧ |
| មាន | ១៣.៥ | ១៤.៧ | ៦.៥ | ៦.៥ | ៦៥៩ |
| មានបំផុត | ៩.៤ | ១៧.៦ | ៣.៦ | ៣.៦ | ៦៧០ |
| **សរុប** | ១៦.២ | ១៧.៦ | ៩.៣ | ៩.៣ | ៣២៤៥ |

[1]សម្រាប់ដៃគូបច្ចុប្បន្ន/ថ្មីបំផុតដែលបង្ហាញដើម្បីធ្វើការប្រៀបធៀប

[2]សម្រាប់ដៃគូណាមួយដែលពាក់ព័ន្ធសូចនាកររបស់អង្គការសហប្រជាជាតិស្តីពីអំពើហិង្សាលើស្ត្រី

## តារាងក៥៖ បទពិសោធន៍អំពើហិង្សាលើផ្លូវភេទក្នុងជីវិត និងអំឡុងពេល១២ខែកន្លងមកក្នុងចំណោមស្ត្រីធ្លាប់មានដៃគូ បែងចែកតាមលក្ខណៈសាវតា (អ.ប.ស.ក ឆ្នាំ២០១៤)

| លក្ខណៈអង្កេត | ស្ត្រីធ្លាប់រងអំពើហិង្សាលើផ្លូវភេទពីដៃគូក្នុងជីវិត | | ស្ត្រីធ្លាប់រងអំពើហិង្សាលើផ្លូវភេទពីដៃគូ អំឡុងពេល១២ខែកន្លងមក | | សរុប |
|---|---|---|---|---|---|
| | ដៃគូបច្ចុប្បន្ន/ថ្មីបំផុត[1] | ដៃគូណាមួយ[2] | ដៃគូបច្ចុប្បន្ន/ថ្មីបំផុត[1] | ដៃគូណាមួយ[2] | ចំនួន |
| | % | % | % | % | |
| **អាយុ** | | | | | |
| ១៥-១៩ | ១.៩ | ១.៩ | ១.៩ | ១.៩ | ១០៨ |
| ២០-២៤ | ៤.៨ | ៤.៨ | ៣.៩ | ៣.៩ | ៤៦១ |
| ២៥-២៩ | ៤.២ | ៤.៣ | ៣.៦ | ៣.៦ | ៥៧៧ |
| ៣០-៣៤ | ៤.៨ | ៥.១ | ៣.៦ | ៣.៦ | ៧២៦ |
| ៣៥-៣៩ | ៦.៩ | ៧.១ | ៥.១ | ៥.១ | ៤៣៥ |
| ៤០-៤៤ | ៦.៣ | ៧.៣ | ៣.៥ | ៣.៥ | ៥០៩ |
| ៤៤-៤៩ | ៧.៥ | ៨.៤ | ៤.៩ | ៤.៩ | ៤២៩ |
| **សាសនា** | | | | | |
| ព្រះពុទ្ធ | ៥.៥ | ៥.៩ | ៤.៧ | ៤.១ | ៣,០៩៥ |
| មូស្លីម | ១.៣ | ១.៣ | ០.០ | ០.០ | ៧៥ |
| គ្រឹស្ត | ១២.៥ | ១២.៥ | ៣.០ | ៣.០ | ៣២ |
| ផ្សេងទៀត/គ្មានព័ត៌មាន | ៤.៧ | ៤.៧ | ២.៣ | ២.៣ | ៤៣ |
| **ទីលំនៅដ្ឋាន** | | | | | |
| ទីប្រជុំជន | ៣.៩ | ៤.៥ | ២.៩ | ២.៩ | ៤៨៩ |
| ជនបទ | ៥.៧ | ៦.១ | ៤.១ | ៤.១ | ២,៧៥៦ |
| **រាជធានី/ខេត្ត** | | | | | |
| បន្ទាយមានជ័យ | ៤.៩ | ៦.៥ | ៤.៩ | ៤.៩ | ១២៣ |
| កំពង់ចាម | ៥.០ | ៥.៤ | ៤.៨ | ៤.៨ | ៤៤១ |
| កំពង់ឆ្នាំង | ៥.៥ | ៥.៥ | ២.៨ | ២.៨ | ១០៩ |
